ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- សិល្បៈនៃការផ្សះផ្សា និងការជាសះស្បើយរបួសផ្លូវចិត្ត
- ការទទួលបាននូវយុត្តិធម៌ និងការផ្សះផ្សាជាតិនៅកម្ពុជា

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១២២ ខែកុម្ភៈ ឆ្នាំ២០១០

# ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១២២ ខែកុម្ភៈ ឆ្នាំ២០១០


## មាតិកា


◆សិល្បៈនៃការផ្សះផ្សា និងការជាសះស្បើយរបួសផ្លូវចិត្ត ........................ ១

**ផ្នែកឯកសារ**

◆ពីកុមារនៅក្រោមរបបខ្មែរក្រហមទៅជាអ្នកអប់រំ ........................ ២

◆ខឹម សឹម ៖ ក្មេងកំព្រាដោយខ្មែរក្រហម ........................ ៤

◆សោមនស្ស ភិរម្យ ៖ ដឹងពីរបបខ្មែរក្រហមតាមរយៈ ........................ ៨

◆ថាច់ ចូវ ៖ អតីតសិស្សរបស់ ខៀវ សំផន ........................ ៩

◆សេង ពិសិដ្ឋនារី ៖ បាត់បង់ឪពុកដោយមិនដឹងពីមូលហេតុ ........................ ១២

◆សេក សុខា គ្រូបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ........................ ១៥

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆តើមានអ្វីកើតឡើងបន្ទាប់? ........................ ២២

◆វេទិកាប្រវត្តិសាស្ត្រនៃគម្រោងអប់រំអំពើ ........................ ២៦

**ផ្នែកច្បាប់**

◆វិសាលភាពនៃអំណាចរបស់អង្គជំនុំជម្រះវិសាមញ្ញ ........................ ៣០

◆ការទទួលបាននូវយុត្តិធម៌ និងការផ្សះផ្សាជាតិនៅ ........................ ៤១

**វេទិកាពិភាក្សាសាធារណៈ**

◆ប្រវត្តិរូបមេដឹកនាំខ្មែរក្រហម ........................ ៥២

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆រឿងពិតរបស់គ្រួសារខ្ញុំ ........................ ៥៨




ល្ខោននិយាយរឿង «ទម្ងាយភាពស្ងប់ស្ងាត់»




## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ០២៩១ពម/៩៩

ចុះថ្ងៃទី២ ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



**ស្នេរលេខនេះ ៖** ស សេងគា, អេលីហ្សាបែត ដូ, ម៉ាឃីតា ស្មីត, អាន ហាញឌុល, ម៉ារីឌីត ឌីន, ណាតាហ្សា បាច់, អានី ស្តុបហ្វុត, ចេង ហុង **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** គាត លក្ខិណា, សោម ប៊ុនថន, ស៊ិន សុធីតា, **អ្នកបកប្រែៈ** ជា ផល្លា, ទេស ម៉ារីម **និពន្ធនាយកទូទៅៈ** ឆាំង យុ **ជំនួយការនិពន្ធនាយកៈ** ញាណ សុជាតិ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** ម៉ម សុផាត Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រៈ*

# សិល្បៈនៃការផ្សះផ្សា និងការជាសះស្បើយរបួសផ្លូវចិត្ត

មានភាពស្ងប់ស្ងាត់នៅក្នុងប្រទេសកម្ពុជាជាយូរណាស់មក ហើយទាក់ទងនឹងរបបខ្មែរក្រហម ភាពស្ងប់ស្ងាត់ដែលបានបន្សល់ទុកជាច្រើនទសវត្សរ៍ ហើយស្ថិតនៅក្នុងចិត្តប្រកបដោយភាពភ័យខ្លាច ការឈឺចាប់និងរឿងនយោបាយ ។ ទោះបីជាយ៉ាងណាក៏ដោយ នៅរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះមានកិច្ចខិតខំប្រឹងប្រែងយ៉ាងច្រើនដើម្បីបញ្ចប់ភាពស្ងប់ស្ងាត់នេះ នៅក្នុងទម្រង់ជាការស្វែងរកយុត្តិធម៌តាមផ្លូវច្បាប់ កម្មវិធីចុះផ្សព្វផ្សាយតាមមូលដ្ឋាន និងការបង្រៀននៅតាមវិទ្យាល័យទូទាំងព្រះរាជាណាចក្រកម្ពុជា ពីអំពើប្រល័យពូជសាសន៍ ។ ខណៈពេលដែលយុទ្ធសាស្ត្រនីមួយៗមានសារៈសំខាន់សម្រាប់ដំណើរការធ្វើឲ្យប្រទេសកម្ពុជាប្រសើរឡើង វានៅតែត្រូវការយុទ្ធសាស្ត្រដែលផ្តោតទៅលើផ្នែកអារម្មណ៍ និងស្មារតី ទាក់ទងនឹងការផ្សះផ្សា និងការជាសះស្បើយរបួសផ្លូវចិត្ត ។

នេះគឺជាឱកាសដែលសិល្បៈ អាចធ្វើវិភាគទានដ៏មានសារៈសំខាន់បំផុតនៅក្នុងសង្គមខ្មែរយើង ។ ប្រជាជនខ្មែរមានសិល្បៈដែលប្រកបទៅដោយមនោសញ្ចេតនាដ៏ជ្រាលជ្រៅនៅក្នុងខ្លួន ហើយនេះគឺជាដំណើរជីវិតរបស់ប្រជាជនខ្មែរម្នាក់ៗ ។ ខ្មែរក្រហមបានសម្លាប់អ្នកសិល្បៈជាច្រើន ប៉ុន្តែមិនអាចសម្លាប់ទេពកោសល្យសិល្បៈ និងមនោសញ្ចេតនារបស់ប្រជាជនខ្មែរបានទេ ។ សិល្បៈគឺជាដួងព្រលឹងរបស់ប្រជាជនខ្មែរ ។ រឿង «ទម្លាយភាពស្ងប់ស្ងាត់» ដែលផលិតដោយអម្រិតាសិល្បៈ និងដឹកនាំដោយ អាន ម៉ារី ព្រីន គឺជាការសម្តែងដ៏អស្ចារ្យបំផុតមួយតាំងពីរបបខ្មែរក្រហមបានដួលរលំនៅក្នុងឆ្នាំ១៩៧៩ ។

វាគឺជាការសម្តែងអំពីប្រជាជនខ្មែរ ការឈឺចាប់ កំហឹង និងការលើកទឹកចិត្តឲ្យគិតពីអនាគត មិនថាក្នុងកាលៈទេសៈណាក៏ដោយ ។ ជនរងគ្រោះនៃរបបខ្មែរក្រហម គឺជាប្រជាជនដែលប៉ះទង្គិចផ្លូវចិត្ត រស់នៅក្នុងសង្គមមួយដែលបែកបាក់ ហើយគឺជាមនុស្សដែលវិញ្ញាណកំពុងតែហោះហើរ ។ ខ្ញុំបានរកឃើញវិញ្ញាណរបស់យើងនោះ នៅក្នុងការសម្តែងដែលមានចំណងជើងថា «ទម្លាយភាពស្ងប់ស្ងាត់» ។ ការសម្តែងនេះមានសារៈសំខាន់ចំពោះប្រជាជនខ្មែរបានទស្សនានិងស្តាប់ ។ វានឹងជួយស្តារសេចក្តីថ្លៃថ្នូរ និងមនុស្សធម៌ ហើយធ្វើឲ្យសីលធម៌របស់យើងកាន់តែប្រសើរឡើង ។ វាក៏នឹងជួយឲ្យកូនចៅរបស់យើងដឹងពីប្រទេសយើងកាន់តែច្បាស់ ។ ខ្ញុំសង្ឃឹមថា ការសម្តែងនៅពេលអនាគតនឹងដូចគ្នាទៅនឹងការសម្តែងនិងផ្សព្វផ្សាយតាមវិទ្យុនៅពេលនេះគឺមានតួនាទីសំខាន់ក្នុងការស្តារសង្គមខ្មែរឡើងវិញ ។


ការសម្តែងល្ខោនរឿង “ទម្លាយភាពស្ងប់ស្ងាត់” នៅខេត្តតាកែវ

ល្ខោននិយាយរឿង «ទម្លាយភាពស្ងប់ស្ងាត់» ចាប់ផ្តើមសម្តែងជាថ្មីម្តងទៀត ហើយជូនសាធារណជននៅខេត្តកំពត និងតាកែវ នៅក្នុងខែកុម្ភៈនេះ ។ កម្មវិធីវិទ្យុនឹងចាក់ផ្សាយនៅក្នុងខែមេសាខាងមុខនេះដែរ ។ **ឆាំង យុ**

# ពីកុមារនៅក្រោមរបបខ្មែរក្រហមទៅជាអ្នកអប់រំ

ក្នុងវ័យកុមារ តែម គឹមគុន ក៏ដូចជាក្មេងដទៃទៀតដែរ ត្រូវឪពុកម្តាយបញ្ជូនឲ្យទៅសាលារៀនដោយសង្ឃឹមថានឹងទទួលបានចំណេះដឹង និងការងារខ្ពង់ខ្ពស់ទៅថ្ងៃអនាគត ។ គឹមគុន បានចូលរៀននៅសាលាបឋមសិក្សាកុមារី (បច្ចុប្បន្នសាលាបឋមសិក្សាចតុមុខ) ស្ថិតនៅខាងជើងវិមានឯករាជ្យ ក្នុងទីក្រុងភ្នំពេញ ។ នៅឆ្នាំ១៩៧២ បន្ទាប់ពី គឹមគុន រៀនដល់ថ្នាក់ទី៩ (សង្គមចាស់) ឪពុករបស់គាត់ដែលជាអតីតគ្រូបង្រៀននៅសាលាបឋមសិក្សាក្នុងខេត្តព្រៃវែង ក្រោយមកផ្លាស់មកធ្វើជាទាហាន លន់ នល់ មានតួនាទីក្នុងកងកាំភ្លើងធំប្រចាំនៅអ្នកលឿង ព្រោះតែមិនពេញចិត្តនឹងរបបកុម្មុយនីស្តរបស់ខ្មែរក្រហមនោះបានត្រូវស្លាប់ដោយសារគ្រាប់ផ្លោងធ្លាក់ចំ ។ មួយរយៈក្រោយមក ម្តាយរបស់ គឹមគុន បាននាំគាត់និងប្អូនប្រុសពីរនាក់ទៀតទៅរស់នៅទីរួមខេត្តបាត់ដំបងជាមួយនឹងឪពុកមាដែលជាមន្ត្រីរដ្ឋការផ្នែកអយស្ម័យយានរហូតដល់របបសាធារណរដ្ឋខ្មែររបស់ លន់ នល់ ដួលរលំ ។

នៅពេលខ្មែរក្រហមឡើងកាន់អំណាចភ្លាម គ្រួសាររបស់ គឹមគុន ត្រូវខ្មែរក្រហមជម្លៀសទៅ ភូមិបាយដំរាំ ស្រុកបាណន់ ខេត្តបាត់ដំបង ។ ដំបូងអង្គការបានរៀបចំឲ្យគ្រួសារ គឹមគុន ស្នាក់នៅជាមួយគ្រួសារអ្នកនៅមូលដ្ឋានរំដោះដែលមានប្តីឈ្មោះ សេង និងប្រពន្ធឈ្មោះ ណម ។ រយៈពេលបីខែក្រោយមក អង្គការបានផ្លាស់គ្រួសារ គឹមគុន ឲ្យទៅរស់នៅក្នុងទ្រុងមាន់បណ្តោះអាសន្ន បន្ទាប់មកទើបអង្គការសង់ខ្ទមមួយនៅក្បែរនោះឲ្យគ្រួសារគាត់




រស់នៅ ។ នៅទីនោះ អង្គការបានបំបែកគ្រួសារ គឹមគុន ទាំងអស់ដោយចាត់តាំងឲ្យម្តាយរបស់គាត់ដែលជាស្ត្រីមេម៉ាយទៅសមរភូមិមុខ ចំណែក គឹមគុន និងប្អូនត្រូវទៅនៅក្នុងកងកុមារនៅក្រឡឹងដុំ ដែលមាន សំអឿន ជាប្រធានកងចល័តកុមារ និង ណាង ជាអនុប្រធាន និង សេង ជាប្រធានសហករណ៍ ហើយប្អូនពៅដែលនៅតូចត្រូវអង្គការបញ្ជូនឲ្យទៅមណ្ឌលកុមាររបស់អង្គការ ។

នៅក្នុងកងកុមារ គឹមគុន ត្រូវធ្វើការងារគ្រប់បែបយ៉ាង ដោយដំបូងប្រធានកងបានចាត់តាំងឲ្យគាត់រើសអាចម៍គោ ក្រោយមកឲ្យទៅរែកដី ជីកប្រឡាយ ហើយពេលទំនេរពីការងារត្រូវទៅជួយរែកអង្ករមកដាក់នៅរោងបាយ ជញ្ជូនកណ្តាប់ និងរកខសដោយទទួលរបបអាហារតែពីរពេលប៉ុណ្ណោះក្នុងមួយថ្ងៃ ។ រៀងរាល់ថ្ងៃ គឹមគុន មិនបានចូលរៀនទេ និងត្រូវធ្វើការរយៈពេល៧-៨ម៉ោង ស្ទើរតែគ្មានពេលសម្រាក ។ ចំពោះកុមារដែលរឹងរូសមិនចង់ទៅធ្វើការ ឬលួចរត់ទៅផ្ទះ នៅពេលប្រធានកងចាប់បាននឹងត្រូវទទួលទណ្ឌកម្មដោយយកទៅចងនឹងដើមញ្ញៃព្រួចវាយនឹងរំពាត់ថ្មោង បន្ទាប់មកយកទៅដាក់ឲ្យអង្គ្រងខាំ ហើយពេលខ្លះប្រធានកងយកអាវភ្លៀង (របៀបថង់ប្លាស្ទិច) មករុំមុខរយៈពេលប្រហែលប្រាំនាទីដើម្បីឲ្យថប់ដង្ហើម ។ ទោះបីជាបានសម្លាប់ក៏ដោយ ក៏ការធ្វើទារុណកម្មបែបនេះបានធ្វើឲ្យកុមារឈ្មោះ ចឹក និងឈ្មោះ ស៊ីណា ដែលលួចរត់មកផ្ទះមានការភ័យខ្លាចដែរ ហើយក៏រត់គេចទៅពួននៅដីដំបូកមួយរហូតដល់ស្លាប់ដោយសារជំងឺព្រោះមិនមានអាហារហូប ។ ឃើញបែបនោះ គឹមគុន មិនដែលហ៊ានលួចមកលេងផ្ទះទេ ហើយគាត់បានជួបនឹងម្តាយតែពីរដងប៉ុណ្ណោះក្នុងមួយឆ្នាំ ដោយសារតែម្តាយរបស់គាត់បានសុំអនុញ្ញាតពីអង្គការមកមើលកូនៗនៅពេលមានប្រារព្ធពិធីបុណ្យខួបធំៗ ។ នៅពេលជួបកូនម្តងៗ ម្តាយរបស់ គឹមគុន តែងតែលួចសម្រក់ទឹកភ្នែកដោយសារក្តីនឹករឭកហើយងូតទឹកឲ្យគឹមគុននិងប្អូនហើយពេលខ្លះបានលួចយកដំឡូងដែលគាត់លាក់ទុកយកមកឲ្យគាត់ហូបទៀតផង ។ មួយរយៈក្រោយមក ដោយសារគ្មានអាហារហូបគ្រប់គ្រាន់និងធ្វើ

ការងារហួសកម្លាំង ហើយរស់នៅក្នុងតំបន់គ្រុនចាញ់បណ្ដាលឲ្យ គីមគុន និងប្អូនរបស់គាត់ ព្រមទាំងកុមារនៅក្នុងកងជាច្រើននាក់ កើតជំងឺខាន់លឿង ។ នៅទីនោះ ដោយគ្មានថ្នាំពេទ្យសម្រាប់ព្យាបាល ទើបអង្គការបានប្រើវិធីព្យាបាលដោយយក ប៉ុយ (អំបោះ) លាប ជាមួយនឹងកំបោរ រួចហើយដុតភ្លើងឲ្យឆេះយកមកអុចលើពោះ របស់អ្នកជំងឺ ។ ក្រោយមក ក៏ផ្ដល់ថ្នាំបុស ឈើព្រៃ និងថ្នាំអាចម៍ទន្សាយឲ្យលេបបន្ថែម ហើយអនុញ្ញាតឲ្យឈប់សម្រាករយៈពេល បីសប្ដាហ៍និងមានចែករបបអង្ករសម្រាប់ហូបផង ។ មួយរយៈ ក្រោយមក កុមារជាច្រើនដែលមានជំងឺបានជាសះស្បើយ ។

នៅឆ្នាំ១៩៧៨ នៅពេលដែលកម្មាភិបាលភូមិភាគនិរតី ចូលមកគ្រប់គ្រងតំបន់ដែលគ្រួសាររបស់ គីមគុន រស់នៅ កម្មា-ភិបាលទាំងនោះបានប្រាប់ឲ្យ គីមគុន និងប្អូនដែលនៅក្នុងកងជាមួយគ្នាត្រឡប់ទៅផ្ទះវិញ ដោយសារតែឃើញគាត់ពីរនាក់បងប្អូន នៅតូចពេក ។ គីមគុន និងប្អូនបានដើរត្រឡប់ទៅរស់នៅផ្ទះដែល ស្ថិតនៅក្នុងភូមិបាយដំរាំវិញដែលនៅទីនោះ គាត់ត្រូវដើររើស អាចម៍គោ បេះត្រកួន និង រកបន្លែឲ្យចុងភៅផងដែរ ។ នៅភូមិបាន មួយរយៈ ប្អូនរបស់ គីមគុន ម្នាក់ទៀតដែលនៅកងផ្សេងមានជំងឺ ក៏បានត្រឡប់មកផ្ទះវិញដែរ ហើយចំណែកម្ដាយរបស់គាត់ត្រូវ ពស់ចឹកបណ្ដាលឲ្យចុកចាប់យ៉ាងខ្លាំងត្រូវអង្គការបញ្ជូនមកនៅផ្ទះ ដែរ ។ គីមគុន បានជួបម្ដាយ និងប្អូនសាជាថ្មីទៀត ។

នៅថ្ងៃមួយ អ្នកភូមិម្នាក់បានឲ្យ គីមគុន ជួយរវៃឌីណាម៉ូរក ប៉ុស្តិ៍វិទ្យុដើម្បីស្ដាប់ព័ត៌មាន ។ ពេលនោះវិទ្យុបាន ផ្សព្វផ្សាយថា កងទ័ពវៀតណាមបានវាយបែកទីក្រុងបាត់ដំបង ហើយខ្មែរក្រហម បានកៀរប្រជាជនទាំងអស់នៅក្នុងតំបន់ដែលគាត់រស់នៅឲ្យទៅភ្នំ សំពៅ ។ ដោយដឹងពីសភាពការណ៍មុន និងមានកូនច្រើនពិបាក ធ្វើដំណើរឲ្យបានលឿន ទើបម្ដាយរបស់ គីមគុន បាននាំគាត់និង ប្អូនៗរត់ពួនក្នុងទឹកបឹងដើម្បីគេចខ្លួនមួយគ្រាសិន បន្ទាប់មកទើប ដើរត្រឡប់ទៅភូមិបាយដំរាំ និងទៅតំបន់ដែលកងទ័ពរណសិរ្ស និង កងទ័ពវៀតណាមរំដោះវិញ ។ គ្រួសាររបស់ គីមគុន បានត្រឡប់ មករស់នៅជួបជុំជាមួយនឹងឪពុកមាក្នុងទីរួមខេត្តបាត់ដំបង មួយ រយៈក្រោយមកដោយឮដំណឹងថាសាច់ញាតិដែលរស់នៅខេត្ត ព្រៃវែងបានស្លាប់អស់ ហើយនៅរស់តែមីងពីរនាក់ប៉ុណ្ណោះ ទើប ម្ដាយរបស់ គីមគុន សម្រេចចិត្តទៅរស់នៅស្រុកកំណើតក្នុងខេត្ត ព្រៃវែងវិញ ។ ដោយឃើញទីនោះមានស្ថិរភាព ហើយមានសាលា រៀនត្រឹមត្រូវ គីម គុន បានចូលរៀនបន្តនៅថ្នាក់ទី៤ ។ គីមគុន បាន ប្រឡងបញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិនៅថ្នាក់ទី១១ (បច្ចុប្បន្ន ថ្នាក់ទី១២) នៅខេត្តព្រៃវែង បន្ទាប់មក គុន រៀនបន្តនៅភ្នំពេញ ទៀត ។ គីមគុន ទទួលបានអាហារូបករណ៍ផ្នែកអក្សរសាស្ត្រពីរដ្ឋា ភិបាលទៅសិក្សានៅប្រទេសឡាវនិងត្រូវរៀនភាសារុស្ស៊ីផង ។ ការសិក្សាជាភាសារុស្ស៊ីមិនមានការលំបាកប៉ុន្មានទេចំពោះ គីមគុន ព្រោះគាត់ធ្លាប់រៀនភាសានេះតាំងពីនៅថ្នាក់វិទ្យាល័យម្ល៉េះ ហើយ សាលាតម្រូវឲ្យ គីមគុន រៀនភាសារុស្ស៊ីមួយឆ្នាំមុននឹងអនុញ្ញាត ឲ្យចូលរៀនថ្នាក់បរិញ្ញាប័ត្រឆ្នាំទី១ ។ នៅឆ្នាំ១៩៩៤ គីមគុន បាន បញ្ចប់ការសិក្សាហើយត្រឡប់មកប្រទេសកម្ពុជាវិញ និងបានចូល ធ្វើការនៅនាយកដ្ឋានស្រាវជ្រាវគរុកោសល្យ ហើយត្រូវក្រសួង អប់រំចាត់តាំងឲ្យគាត់ធ្វើជាគណៈកម្មការសរសេរសៀវភៅជា ភាសាខ្មែរក្រោមការបណ្ដុះបណ្ដាលពីមូលនិធិអង្គការសហប្រជាជាតិ ដើម្បីកុមារ (UNICEF) រយៈពេល៥ឆ្នាំ ។ គីមគុន បានសរសេរ សៀវភៅជាភាសាខ្មែរសម្រាប់សិស្សថ្នាក់ទី ៣ ទី៤ និងទី៥និង សរសេរសៀវភៅតម្រង់ទិសដៅសម្រាប់គ្រូបង្រៀននិងសៀវភៅ សិក្សាសង្គម សម្រាប់ថ្នាក់ទី៨និងទី១០ និងជាអនុប្រធាន ការិយាល័យផែនការទទួលបន្ទុករៀបចំផែនការ ។ នៅឆ្នាំ ២០០៩ គីមគុន បានក្លាយទៅជាគ្រូបង្គោលថ្នាក់ជាតិបង្រៀនប្រវត្តិសាស្ត្រ កម្ពុជាប្រជាធិបតេយ្យពី ឆ្នាំ(១៩៧៥-១៩៧៩) ។

គីមគុន បញ្ជាក់ថា កម្មវិធីបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជា ប្រជាធិបតេយ្យនៅពេលនេះគឺជាពេលល្អបំផុតព្រោះវាស្របនឹង ពេលដែលសាលាក្ដីខ្មែរក្រហមកំពុងតែដំណើរការកាត់ទោស ។ លើសពីនេះទៅទៀត ការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមនេះ បានធ្វើឲ្យក្មេងជំនាន់ក្រោយយល់ដឹងកាន់តែច្រើនពីផលប៉ះពាល់ នៃរបបនេះមកលើប្រជាជនកម្ពុជានិងទប់ស្កាត់កុំឲ្យរបបដ៏ឃោរ ឃៅនោះកើតមានម្ដងទៀត ។ តាមរយៈបទពិសោធន៍ទាំងនេះ នឹងធ្វើក្មេងជំនាន់ក្រោយចេះរស់នៅដោយការអត់ឱនអធ្យាស្រ័យ គ្នា ឈប់ប្រើអំពើហិង្សានិងលែងប្រកាន់ពូជសាសន៍ដែលនឹងនាំ ទៅរកការអភិវឌ្ឍប្រទេសជាតិទាំងមូល ។ **ផា ផល្លា**

# ទឹម សឹមៈ ក្មេងកំព្រាដោយខ្មែរក្រហម

ទឹម សឹម កើតនៅភូមិទួលចំបក់ ឃុំសង្កែ ស្រុករំដួល ខេត្តស្វាយរៀង។ សឹម កំព្រាឪពុកម្តាយតាំងពីអាយុ១៣ឆ្នាំ ហើយគាត់បានទៅស្នាក់នៅនិងរៀនសូត្រជាមួយព្រះសង្ឃនៅក្នុងវត្តថ្មី។ នៅឆ្នាំ១៩៨៩ សឹម បានប្រឡងជាប់គ្រូមធ្យមសិក្សាបឋមភូមិផ្នែកប្រវត្តិវិទ្យា។ បន្ទាប់ពីប្រលងបញ្ចប់គ្រូមធ្យមសិក្សានៅឆ្នាំ១៩៩១ សឹម បានចេញមកបង្រៀននៅអនុវិទ្យាល័យកំពង់ចក (បច្ចុប្បន្នវិទ្យាល័យកំពង់ចក) ដែលជាសាលាគាត់ធ្លាប់រៀនពីមុនមក។ នៅឆ្នាំ២០០៩ ក្រសួងអប់រំបានជ្រើសរើស សឹម ឲ្យធ្វើជាគ្រូបង្គោលបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។

សឹម មានបងប្អូនចំនួន៦នាក់ មានឪពុកឈ្មោះ ទឹម សៀង និងម្តាយឈ្មោះ ទឹម ភឿន ជាកសិករ។ នៅក្នុងអំឡុងទសវត្សរ៍៦០ សឹម បានចូលរៀននៅថ្នាក់ទី១២សង្គមចាស់ (បច្ចុប្បន្នថ្នាក់ទី១) នៅសាលាបឋមសិក្សាវត្តថ្មី។ នៅពេលចប់ម៉ោងសិក្សានៅក្នុងថ្នាក់ឬថ្ងៃវិស្សមកាល សឹម មិនដែលបានសម្រាកទេ គឺគាត់ត្រូវជួយរែកទឹកដាក់ពាក់ប្រមូលជីដាក់ស្រែ ឃ្វាលគោ និងជួយដកស្ទូង ឪពុកម្តាយថែមទៀត។


ទឹម សឹម

នៅឆ្នាំ១៩៧៤ ខ្មែរក្រហមបានមកឃោសនាតាមផ្ទះប្រជាជនក្នុងស្រុករំដួលនិងបានវាយប្រយុទ្ធជាមួយទាហានឆ្មាខ្មៅរបស់ លន់ នល់ និងទាហាន ធីវគី របស់វៀតណាមខាងត្បូង។ ខ្មែរក្រហមបានដណ្តើមកាន់កាប់ភូមិមួយចំនួននិងបានចាត់តាំងប្រធានក្រុម ប្រធានកង និងប្រធានភូមិ ដើម្បីធ្វើការងារសាមគ្គីប្រវាស់ដៃនិងការពារភូមិ។ ចំណែកមន្ត្រីរដ្ឋការ និងគ្រូបង្រៀននៅតាមសាលាជាច្រើនចាប់ផ្តើមមានការភ័យខ្លាចខ្មែរក្រហមចាប់ខ្លួន ហើយគ្រូមួយចំនួនក៏បានរត់ភៀសខ្លួនទៅនៅទីរួមខេត្តស្វាយរៀងស្ទើរអស់។ ដោយសារមិនមានគ្រូមកបង្រៀនដូចពេលមុនៗ សឹម ត្រូវឈប់រៀននៅត្រឹមថ្នាក់ទី១០ចាស់ (ថ្នាក់ទី៣ថ្មី) ហើយមកជួយធ្វើស្រែឪពុកម្តាយវិញ។

នៅក្រោយពេលខ្មែរក្រហមវាយកាន់កាប់បានទីរួមខេត្តស្វាយរៀងទាំងមូល សឹម ដែលទើបមានអាយុ១១ឆ្នាំ ត្រូវខ្មែរក្រហមចាត់តាំងឲ្យដើររើសអាចម៍គោក្របីដាក់ស្រែនិងជួយដឹកព្រែកជាមួយបងៗរបស់គាត់នៅក្នុងកងចល័ត។ ឪពុករបស់ សឹម ដែលមានវ័យចាស់ត្រូវខ្មែរក្រហមចាត់តាំងឲ្យចូលក្នុងកងតាៗធ្វើការងារវេញខ្សែ និងធ្វើបង្គី ចំណែកម្តាយរបស់គាត់ ខ្មែរក្រហមចាត់តាំងឲ្យចូលក្នុងកងយាយៗធ្វើការងារស្រាលៗ មើលក្មេងតូចៗ។ រយៈពេលបីខែក្រោយមក ខ្មែរក្រហមចាប់ផ្តើមដើរប្រមូលចាន ឆ្នាំង រទេះ គោ ក្របី នៅតាមផ្ទះរបស់ប្រជាជនមកដាក់ជារបស់សមូហភាពនិងចាត់តាំងឲ្យប្រជាជនក្នុងភូមិត្រពាំងរុនទាំងអស់ហូបបាយរួម។

បងប្រុសរបស់ សឹម ម្នាក់ដែលធ្វើជាទាហាន លន់ នល់ ដែលមិនដឹងពីសភាពការណ៍ក្នុងភូមិបានត្រឡប់មកផ្ទះវិញក៏ត្រូវកងទ័ពខ្មែរក្រហមចាប់យកទៅដាក់នៅមន្ទីរសន្តិសុខស្វាយរលំស្ថិតនៅក្នុងវត្តពាមអម្ពិល ឃុំកំពង់អម្ពិល ស្រុករំដួល។ មួយរយៈ

ក្រោយមក បងប្រុសរបស់ សឹម បានដោះខ្លួនរួចពីមន្ទីរសន្តិសុខ រួចភៀសខ្លួនទៅនៅប្រទេសវៀតណាម ប៉ុន្តែប្រធានសហករណ៍បានមកឃោសនាប្រាប់ឪពុកម្តាយរបស់ សឹម និងអ្នកភូមិថា បងប្រុសរបស់ សឹម ត្រូវកងការពារនៅមន្ទីរសន្តិសុខបាញ់សម្លាប់ហើយ ។ ដំណឹងនេះបានធ្វើឲ្យឪពុកម្តាយ បងប្អូននិង សឹម ភិតភ័យ និងតក់ស្លុតយ៉ាងខ្លាំង ។

រយៈពេលបីខែក្រោយមក ដោយសារកងទ័ពខ្មែរក្រហមមិនសូវមានការយាមការពារតឹងរ៉ឹងនៅក្នុងភូមិត្រពាំងរុនទាំងមូល ទើបនៅពេលយប់ងងឹតមួយ បងប្រុសរបស់ សឹម បានចូលក្នុងភូមិដើម្បីលួចនាំយកប្រពន្ធរបស់គាត់ទៅរស់នៅប្រទេសវៀតណាមជាមួយគ្នា ។ នៅថ្ងៃបន្ទាប់ក្រោយពីបានទទួលដំណឹងនេះ ខ្មែរក្រហមបានចាប់ខ្លួនឪពុករបស់ សឹម យកទៅដាក់នៅមន្ទីរសន្តិសុខស្ថិតក្នុងភូមិត្រពាំងរុន អស់រយៈពេលជាច្រើនខែ ដោយចោទថាបានលាក់បាំងខ្លាំងនិងមិនរាយការណ៍ប្រាប់អង្គការ ។ នៅខណៈនោះដោយសារឪពុករបស់ សឹម មានការស្រឡាញ់រាប់អានច្រើនពីសំណាក់ប្រជាជននៅក្នុងឃុំ ទើបមានប្រជាជនមកពីភូមិទួលចំបក់ និងភូមិត្រពាំងរុនដែលសរុបទាំងអស់មានចំនួន១០០ គ្រួសារបានមក ផ្តិតមេដៃធានាដោយអះអាងថា ឪពុករបស់ សឹម មិនបានដឹងរឿងរ៉ាវនេះទេ ព្រោះកូនប្រសា (ប្រពន្ធរបស់បងប្រុសរបស់ សឹម) មិនបានរស់នៅជាមួយឪពុកគាត់ឡើយ ។ ខ្មែរក្រហមបានស្តាប់ហេតុផលនេះ ហើយក្រោយមកបានដោះលែងឪពុករបស់ សឹម ឲ្យមានសេរីភាពវិញ ប៉ុន្តែអង្គការបានគំរាមថា ប្រសិនបើមានសមាជិកក្នុងគ្រួសាររត់គេចខ្លួនម្តងទៀតគេនឹងមិនអនុគ្រោះទៀតឡើយ ។

នៅរដូវប្រាំង ឆ្នាំ១៩៧៧ កងទ័ពវៀតណាមបានវាយចូលដល់ស្រុករំដួល ឪពុកម្តាយ បងប្អូន របស់ សឹម និងអ្នកភូមិជាច្រើនគ្រួសារទៀតបានភៀសខ្លួនទៅស្រុកស្វាយជ្រំដោយសារភ័យខ្លាចនឹងការបាញ់ផ្លោង និងការទម្លាក់គ្រាប់បែក ។ ចំណែកប្រជាជនមួយចំនួនដែលចាកចេញពីភូមិមិនទាន់ត្រូវកងទ័ពវៀតណាមកៀរយកទៅប្រទេសវៀតណាមទាំងអស់ ។ ភ្លាមនោះ ខ្មែរក្រហមបានត្រឡប់ចូលមកក្នុងភូមិម្តងទៀត ហើយចាប់ប្រជាជនរាប់រយនាក់ដែលកំពុងរៀបចំខោអាវនៅក្នុងផ្ទះដើម្បីគេចខ្លួនចេញពីការវាយប្រយុទ្ធនេះយកទៅបាញ់សម្លាប់រួចទម្លាក់ចូលក្នុងអណ្តូងដោយចោទថា ជាពួកក្បាលយួនខ្លួនខ្មែរ ។ ចំណែកប្រជាជនដែលនៅសេសសល់ទាំងប៉ុន្មានត្រូវខ្មែរក្រហមកៀរយកទៅដាក់នៅកន្លែងឃុំឃាំងបឹងកែក ក្នុងស្រុកស្វាយជ្រំ ។

គ្រួសាររបស់ សឹម ដែលមានសមាជិក៧នាក់ ត្រូវខ្មែរក្រហមចាត់តាំងឲ្យទៅរស់នៅក្នុងវត្តសូរ ស្ថិតនៅក្នុងឃុំស្វាយយា ស្រុកស្វាយជ្រំ ហើយប្រធានកងបានចែករបបអង្ករឲ្យចំនួនបួនកំប៉ុងក្នុងមួយថ្ងៃសម្រាប់ដាំបាយហូប ។ ប៉ុន្តែ ក្រោយមក ដោយសារកងទ័ពវៀតណាមនិងកងទ័ពខ្មែរក្រហមនៅតែបន្តវាយប្រយុទ្ធគ្នាទៅវិញទៅមក ធ្វើឲ្យគ្រួសាររបស់ សឹម ផ្លាស់ប្តូរទីកន្លែងស្នាក់នៅជាញឹកញាប់ ហើយពេលខ្លះត្រូវរត់ទៅដេកលាក់ខ្លួនក្នុងគុម្ពោតព្រៃដំបូក ឬក្រោមដើមឈើនៅទីវាលឆ្ងាយពីភូមិ ។ នៅខណៈនោះ បងប្អូនជីដូនមួយរបស់ សឹម ឈ្មោះ ថាត ធ្វើការនៅមន្ទីរសន្តិសុខបានចាប់ពូបង្កើតរបស់គាត់ឈ្មោះ យ៉ុន និងស្ត្រីម្នាក់យកទៅដាក់ខ្នោះជើងទាំងពីរនាក់ ដោយ ថាត បានចោទថា ពូរបស់គាត់មានស្រី (ប្រពន្ធ របស់ យ៉ុន មករាយការណ៍ប្រាប់ ថាត) ។ ទោះបីបានដឹងរឿងរ៉ាវនេះ ក៏ដោយ ក៏ឪពុកម្តាយរបស់ សឹម មិនហ៊ានទៅធានាឲ្យដោះលែងដែររហូតដល់ពេលថ្ងៃត្រង់ យ៉ុន ត្រូវសន្តិសុខគុកយកទៅសម្លាប់នៅក្នុងវត្តអង្គរសក្នុងស្រុកស្វាយជ្រំ ។

នៅរដូវវស្សា ឪពុកម្តាយនិងបងប្អូនរបស់ សឹម និងប្រជាជនចំនួនប្រាំគ្រួសារទៀតត្រូវខ្មែរក្រហមបញ្ជូនឲ្យមករស់នៅសហករណ៍កោះជ័យស្ថិតក្នុងស្រុកព្រះស្តេច ខេត្តព្រៃវែង ដោយអង្គការបានបែងចែករបបអង្ករឲ្យហូបរួម ។ រយៈពេលមួយខែក្រោយមក ប្រធានសហករណ៍បានប្រកាសប្រាប់គ្រួសារដែលជម្លៀសមកទាំងអស់ឲ្យទៅនៅតំបន់ដីខ្លាញ់ ក្នុងខេត្តពោធិ៍សាត់វិញ ។

ឪពុកម្តាយ បងប្អូន និង សឹម បានទៅរស់នៅសហករណ៍ថ្កុកសង្កែ ស្ថិតក្នុងភូមិដំណាក់ឆ្កួត ស្រុកបាកាន ។ នៅទីនោះ ដោយសារគ្មានកន្ទេល មុង ភួយ សឹម បានយកចំបើងមកក្រាលដេក ហើយពេលខ្លះត្រូវដេកផ្ទាល់លើដីក្នុងរោងប្រក់ស្លឹកតែម្តង ។ សឹម ត្រូវខ្មែរក្រហមចាត់តាំងឲ្យឃ្វាលគោនិងរែកទឹកដាក់ពាងឲ្យបានចំនួនម្ភៃពាងក្នុងមួយថ្ងៃ ចំណែកបងគាត់ចំនួន៥នាក់ត្រូវចាត់តាំងឲ្យ

ធ្វើការនៅក្នុងកងចល័ត ។ នៅទីនោះ ក្អួយប្រុសរបស់ សឹម ម្នាក់មានជំងឺងងឹតមាន់ត្រូវខ្មែរក្រហមចាត់តាំងឲ្យជីកដី លើកភ្លឺស្រែនៅពេលមេឃងងឹត ។ ដោយ សឹម មានការអាណិតអាសូរក្អួយដែលងងឹតមើលផ្លូវពុំឃើញ គាត់តែងតែទៅជួយជីកដៃនាំផ្លូវក្អួយដល់ការដ្ឋានធ្វើការ និងជួយជីកដីក្អួយថែមទៀតផង ។

នៅព្រឹកថ្ងៃមួយ សឹម បានឃើញយាយចាស់ម្នាក់ដែលមានរបួសត្រង់ក្បាលបានរត់មកនៅសហករណ៍របស់គាត់ ហើយបន្ទាប់ពីប្រធានកងឲ្យបាយហូបរួចហើយក៏បានរាយការណ៍ប្រាប់ទៅប្រធានសហករណ៍ ។ ភ្លាមនោះប្រធានសហករណ៍បានមកដល់ រួចចាប់ចងដៃយាយនោះទៅក្រោយរឹតយ៉ាងតឹងដោយការឈឺចាប់ខ្លាំងគាត់បានអង្វរប្រធានសហករណ៍ថាកុំឲ្យចងដៃតឹងខ្លាំងពេក ហើយគាត់សន្យាថានឹងមិនរត់គេចទៅណាទៀតទេ ។ នៅវេលាថ្ងៃត្រង់ ប្រធានសហករណ៍បានបណ្តើរយាយនោះទៅវាយសម្លាប់នៅត្រង់កន្លែងថ្លុកដែលក្របីដេករួចកាច់មែកសង្កែគ្របពីលើ ។ ចំណែកបងប្អូនជីដូនមួយស្រីរបស់ សឹម និងកូនតូចក៏ត្រូវខ្មែរក្រហមយកទៅវាយសម្លាប់ចោលពេលយប់នៅខាងក្រោយភូមិដែរ ។

នៅឆ្នាំ១៩៧៨ គ្រួសារជម្លៀសប្រមាណជា១០០គ្រួសារដែលរស់នៅក្នុងសហករណ៍ថ្លុកសង្កែ រួមទាំងឪពុកម្តាយ បងស្រី បងប្រុស ក្អួយ និង សឹម ត្រូវខ្មែរក្រហមប្រមូលផ្តុំដោយប្រាប់ថាប្រជាជនដែលមានអាយុចាស់ៗត្រូវទៅរស់នៅនិងធ្វើការនៅលើភ្នំ ។ ដោយឪពុកម្តាយរបស់ សឹម ដឹងថា ខ្មែរក្រហមនឹងមិនទុកជីវិតឲ្យប្រជាជនមកពីស្វាយរៀងភូមិភាគបូព៌ា គាត់ក៏បានប្រាប់ សឹម និងបងប្រុសរបស់គាត់ឲ្យរត់គេចខ្លួន ។ ខណៈនោះ ដោយសារ សឹម មានការភ័យតក់ស្លុតខ្លាំង គាត់ក៏ឡើងលាក់ខ្លួនលើដើមមួយដើមដែលដុះនៅក្នុងវាលស្រែជិតសហករណ៍នោះ ។ នៅពេលរសៀល សឹម បានសម្លឹងឃើញឈ្លបក្មេងពីរនាក់បណ្តើរបងរបស់គាត់ចំនួន៤នាក់ ឪពុកនិងម្តាយពាក់អាវវាល-កពណ៌ពងក្រសារ មានហោប៉ៅ៣ ជីកដៃចៅតូចៗនិងអ្នកជម្លៀសជាច្រើនគ្រួសារទៀតចេញពីភូមិ ។ រយៈពេលពីរថ្ងៃក្រោយមក សឹម ឃើញប្រពន្ធប្រធានកងយកអាវរបស់ម្តាយគាត់មកពាក់ ទើបគាត់ដឹងថាម្តាយរបស់គាត់ពិតជាត្រូវឈ្លបខ្មែរក្រហមយកទៅសម្លាប់ហើយ ។ ថ្ងៃមួយ សឹម បានដើរទៅក្រោយភូមិ ដើម្បីរកសាកសពម្តាយ ក៏ឃើញមានអណ្តូងធំចំនួនពីរពោរពេញដោយសាកសពហើមស្អុយរលួយដែលធ្វើឲ្យគាត់មិនអាចចំណាំបាន ។

សឹម នៅជាក្មេងកំព្រា និងរស់នៅក្នុងកងចល័តកុមារធ្វើការងារលើកភ្លឺស្រែ ប្រូតស្រូវស្ទើរគ្មានពេលឈប់សម្រាក ។ សឹម កើតដំបៅនិងរលួយត្រង់ជើងស្តាំដោយសារដើរកាត់វាលស្មៅវាលស្រូវ និងគ្មានអាហារមានជីវជាតិសម្រាប់ហូប ។ ទោះបី សឹម មានការឈឺចាប់ត្រង់មុខរបួសយ៉ាងណាក៏ដោយ ក៏គាត់មិនដែលបានទទួលថ្នាំយកមកព្យាបាល ឬអនុញ្ញាតឲ្យសម្រាកដែរ ។ រហូតដល់ពេលកងទ័ពវៀតណាមវាយជិតដល់សហករណ៍ថ្លុកសង្កែនៅឆ្នាំ១៩៧៩ សឹម បានរត់គេចដោយជួយរែករបស់របរ ចាន ឆ្នាំងមួយចំនួនឲ្យយាយ យ៉ុង ដែលរស់នៅភូមិឃុំជាមួយគ្នាកាត់តាមវាលស្រែសំដៅមកទីរួមខេត្តពោធិសាត់វិញ ។ នៅទីនោះ ដោយឃើញសភាពដំបៅរបស់ សឹម រលួយជ្រុះសាច់ កងទ័ពរណសិរ្ស



ខឹម សឹម, ប្រពន្ធ, កូន និងម្តាយក្មេក នៅស្រុករំដួល ខេត្តស្វាយរៀង

រំដោះជាតិកម្ពុជាបានជួយព្យាបាលរហូតធ្វើឲ្យដៃជោរបស់គាត់បានធូរស្បើយ ។ ចំណែកបងប្រុសរបស់ សឹម ដែលភៀសខ្លួនទៅប្រទេសវៀតណាមក៏បានត្រឡប់មកផ្ទះកំណើតនៅភូមិត្រពាំងរុនវិញដែរ ប៉ុន្តែដោយទទួលដំណឹងថា បងប្អូន ឪពុកម្តាយ ត្រូវខ្មែរក្រហមជម្លៀសទៅខេត្តពោធិ៍សាត់ទាំងអស់ គាត់ក៏បានសុំច្បាប់រដ្ឋអំណាចទៅតាមស៊ើបសួររកដំណឹងនេះ ។

សឹម បានជួបបងប្រុសនៅក្នុងសាលាខេត្តពោធិ៍សាត់ រួចហើយនាំគ្នាត្រឡប់មករស់នៅផ្ទះក្នុងភូមិវិញ ។ ដោយសារបងប្រុសមានប្រពន្ធ និងកូន ចំណែកឪពុកម្តាយស្លាប់អស់ហើយ សឹម ក៏សម្រេចចិត្តទៅស្នាក់ជាមួយគ្រូសូត្រស្តាំរស់ យ៉េង គង់នៅវត្តគីសាលាក្នុងឃុំស្វាយយា ស្រុកស្វាយជ្រុំ ដែលគាត់ធ្លាប់ស្គាល់ពីមុនមក ។ រហូតដល់ឆ្នាំ១៩៨០ សឹម បានផ្លាស់មករស់នៅជាមួយព្រះសង្ឃនៅវត្តពាមអម្ពិល (វត្តថ្មី) ក្នុងស្រុករំដួលវិញ ។

នៅឆ្នាំ១៩៨៤ សឹម បានចូលរៀនបន្តនៅថ្នាក់ទី៤ (ថ្មី)



នៅសាលាបឋមសិក្សាវត្តពាមអម្ពិល ហើយបន្ទាប់មកគាត់ក៏ចូលរៀននៅអនុវិទ្យាល័យកំពង់ចក ។ ដោយសារការខិតខំប្រឹងប្រែងរៀនសូត្រ សឹម បានប្រឡងជាប់រួចចូលរៀនបន្តនៅវិទ្យាល័យស្វាយរៀងដែលមានចម្ងាយប្រមាណ៣០គីឡូម៉ែត្រពីកន្លែងគាត់ស្នាក់នៅ ។ រៀងរាល់ថ្ងៃ ឹម ត្រូវភ្ញាក់នៅម៉ោង៤ព្រឹក ដើម្បីជិះកង់មកសាលាឲ្យទាន់ម៉ោងរៀន ប៉ុន្តែទោះបីជាមានការនឿយហត់និងផងនុយដេកយ៉ាងណាក៏ដោយ ក៏គាត់នៅតែតស៊ូរៀនរហូតបានប្រឡងជាប់គ្រូមធ្យមសិក្សាបឋមភូមិផ្នែកប្រវត្តិវិទ្យានៅក្នុងឆ្នាំ១៩៨៩ដែរ ។ សព្វថ្ងៃ សឹម មានប្រពន្ធ និងកូនចំនួន៤នាក់ ។ សឹម ធ្វើជាគ្រូបង្រៀនអស់រយៈពេល១៨ឆ្នាំ នៅវិទ្យាល័យកំពង់ចក ហើយនៅឆ្នាំ២០០៩ នេះក្រសួងអប់រំបានជ្រើសរើសគាត់ឲ្យធ្វើជាគ្រូបង្គោលថ្នាក់ខេត្តបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

សឹម តែងតែនិយាយពីបទពិសោធន៍ដែលគាត់បានឆ្លងកាត់ក្នុងរបបខ្មែរក្រហមប្រាប់កូនរបស់គាត់និងប្រាប់ទៅដល់សិស្សឲ្យយល់ដឹងកាន់តែច្រើនពីរបបពីអំពើឃោរឃៅរបស់ខ្មែរក្រហមជានិច្ចដើម្បីរកវិធីទប់ស្កាត់និងផ្សះផ្សានូវរបួសផ្លូវចិត្តរបស់ជនរងគ្រោះឡើងវិញ ។

**សោម ប៊ុនថន**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង ៧-៧:៣០ព្រឹក និងម៉ោង៧:០០-៧:៣០ល្ងាច ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។ **ស៊ិន សុធីតា**

# សោមនស្ស ភិរម្យ ៖ ដឹងពីរបបខ្មែរក្រហមតាមរយៈឪពុកម្តាយ

*សោមនស្ស ភិរម្យ អាយុ៣៥ឆ្នាំ សព្វថ្ងៃរស់នៅក្រុងតាខ្មៅ ខេត្តកណ្តាល គឺជាគ្រូប្រវត្តិសាស្ត្រម្នាក់ ។ ឪពុករបស់ភិរម្យឈ្មោះ មុី សោមនស្ស ហើយម្តាយឈ្មោះ មាស សុខន មានមុខងារជាមន្ត្រីរាជការដូចគ្នា ។*

*ភិរម្យ រំឭកថា កាលពីនៅក្មេង ឪពុកម្តាយរបស់គាត់តែងតែនិយាយរឿងរ៉ាវដែលគាត់បានជួបប្រទះកាលពីជំនាន់មុន គឺតាំងពីហេតុការណ៍រដ្ឋប្រហារឆ្នាំ១៩៧០ ព្រឹត្តិការណ៍ស្តីពីជំនាន់សង្រ្គាមស៊ីវិលរហូតដល់ខ្មែរក្រហមគ្រប់គ្រងប្រទេសទាំងស្រុងនៅឆ្នាំ១៩៧៥ ។ ភិរម្យ ចាំថា «នៅពេលខ្មែរក្រហមចូលមកគ្រប់គ្រងភ្នំពេញនៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសប្រជាជនទាំងអស់ចេញពីទីក្រុងទៅរស់នៅជនបទ ហើយបានបង្ខំឲ្យធ្វើស្រែស៊ើរតែគ្មានពេលសម្រាក» ។ មនុស្សគ្រប់រូបពេលដែលរំឭកពីរបបខ្មែរក្រហមមិនដែលភ្លេចនិយាយពីការសម្លាប់ដែលបានកើតឡើងកាលពីជំនាន់នោះទេ ។ ភិរម្យ បានបន្តថា «អ្វីដែលខ្ញុំចាំតាមការរៀបរាប់របស់ឪពុកម្តាយខ្ញុំគឺថា ខ្មែរក្រហមបានសម្លាប់ប្រជាជនតាមរយៈការឲ្យធ្វើការហួសកម្លាំង ការបង្អត់អាហារ និងការសម្លាប់ដោយចោទថាជាខ្មាំងព្រោះតែកំហុសតូចតាចប៉ុណ្ណោះ» ។*

*ក្រៅពីការចងចាំតាមរយៈការរៀបរាប់របស់ឪពុកម្តាយ ភារម្យ ក៏បានរៀនសូត្រពីរបបខ្មែរក្រហមតាមថ្នាក់រៀនកាលពីទសវត្សរ៍៨០ផងដែរ ។ ចំណែកលោកគ្រូអ្នកគ្រូក៏បាននិយាយពីប្រវត្តិ និងបទពិសោធន៍ឈឺចាប់របស់គាត់ថែមទៀត ។ ភិរម្យ បានសារភាពថា កាលពីដំបូងគាត់សឹងតែមិនជឿថាមានការកាប់សម្លាប់មនុស្សយ៉ាងព្រៃផ្សៃដោយជនជាតិខ្មែរគ្នាឯងដូច្នេះទេ ។ ប៉ុន្តែដោយសារការសិក្សានៅតាមសាលារៀន ការអានសៀវភៅ និងការនិយាយប្រាប់ពីសំណាក់ឪពុកម្តាយនិងគ្រូបង្រៀន គាត់ជឿទាំងស្រុងថា អំពើព្រៃផ្សៃពិតជាកើតឡើងមែនកាលពីសម័យខ្មែរក្រហម ។ ដោយសារតែបទពិសោធន៍របស់ខ្លួនធ្លាប់តែមិនជឿនូវអ្វីដែលបានកើតឡើងកាលពីសម័យនោះ ភិរម្យ គិតថាថ្ងៃណាមួយគាត់នឹងប្រែក្លាយខ្លួនទៅជាអ្នកអប់រំក្មេងជំនាន់ក្រោយអំពីរបបខ្មែរក្រហមនេះមិនខាន ។ ភិរម្យ បានបន្តថា «ប្រវត្តិសាស្ត្រសម័យកម្ពុជាប្រជាធិបតេយ្យមានសារសំខាន់ណាស់ ហើយក្មេងជំនាន់ក្រោយត្រូវតែដឹងពីរបបដ៏ឃោរឃៅព្រៃផ្សៃនេះ» ។*

*នៅឆ្នាំ២០០៤ ក្រោយពីបញ្ចប់ការសិក្សាជំនាញសូនរូបនៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ភិរម្យ បានចូលបម្រើការងារនៅក្រសួងអប់រំយុវជននិងកីឡា ដោយមានតួនាទីជាគ្រូបង្រៀនខាងប្រវត្តិសាស្ត្រ ។ ថ្មីៗនេះ ក្រោមការសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ ភិរម្យ ត្រូវបានជ្រើសតាំងឲ្យចូលរួមបណ្តុះបណ្តាលក្នុងកម្មវិធីអប់រំគ្រូបង្គោលថ្នាក់ជាតិក្រោមការបង្ហាត់បង្រៀនពីអ្នកជំនាញខាងអប់រំនិងប្រវត្តិសាស្ត្រខ្មែរក្រហមមកពីសហរដ្ឋអាមេរិក កាណាដា អង់គ្លេស អូស្ត្រាលី និងកម្ពុជា ។ ក្រោយពីទទួលកាលបណ្តុះបណ្តាលនេះរួចមក ភិរម្យ បានបញ្ជាក់ថា «នៅពេលដែលបានក្លាយជាគ្រូបង្គោលថ្នាក់ជាតិក្នុងការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ខ្ញុំសប្បាយចិត្តជាខ្លាំងព្រោះអ្វីដែលខ្ញុំបានគិតទុកកាលពីក្មេងបានសម្រេចដូចគោលបំណងមែន» ។ ភិរម្យ យល់ថា ការបញ្ចូលកម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យទៅក្នុងកម្មវិធីសិក្សារបស់ក្រសួងថ្នាក់ទី៧និងថ្នាក់ទី១២ពិតជាបានផ្តល់ឲ្យសិស្សានុសិស្សសិក្សាបន្ថែមពីប្រវត្តិសាស្ត្ររបស់ប្រទេសខ្លួន ព្រមទាំងអាចស្រាវជ្រាវឲ្យកាន់តែច្បាស់ពីអំពើប្រល័យពូជសាសន៍នៅប្រទេសកម្ពុជាដែលបានសម្លាប់ប្រជាជនអស់ជិតពីរលាននាក់ ។*

*នៅចុងឆ្នាំ២០០៩កន្លងទៅនេះ ភិរម្យ បានចុះទៅបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ខេត្តរយៈពេល៧ថ្ងៃនៅខេត្តព្រៃវែង ។ ក្រោយពីចប់វគ្គ ភិរម្យ យល់ថា ការបណ្តុះបណ្តាលនេះគឺជាជំហានមួយដែលអាចនាំឲ្យការបង្រៀនអំពីប្រវត្តិកម្ពុជាប្រជាធិបតេយ្យនៅតាមសាលារៀនកាន់តែស៊ីជម្រៅថែមទៀត ។ ការសិក្សាអំពីប្រវត្តិសាស្ត្រពិតជាមានមានសារសំខាន់ណាស់ក្នុងការផ្សះផ្សាជាតិឡើងវិញតាមរយៈការសិក្សាពីប្រវត្តិសាស្ត្ររបស់ខ្លួន ។*

**ស៊ិន សុធីតា**

# ថាច់ ចូវ : អតីតសិស្សរបស់ ខៀវ សំផន

ថាច់ ចូវ មានអាយុ៨០ឆ្នាំ កើតនៅភូមិដៃទឹងខាងជើង ឃុំសុងឡុក ខេត្តត្រាវិញ កម្ពុជាក្រោម ប្រទេសវៀតណាម ។ នៅឆ្នាំ១៩៥១ ថាច់ ចូវ បានចូលមកប្រទេសកម្ពុជាដើម្បីសិក្សា ។ ក្រោយពីខ្មែរក្រហមដួលរលំឆ្នាំ១៩៧៩ ថាច់ ចូវ បានចូលធ្វើជានាយកមន្ទីរអប់រំខេត្តស្វាយរៀង ហើយសព្វថ្ងៃគាត់ជួយធ្វើការងារនៅមណ្ឌលកុមារកំព្រាខេត្ត ។

ថាច់ ចូវ មានបងប្អូនចំនួន៨នាក់ និងមានម្តាយឈ្មោះ ថាច់ អៀង និង ឪពុកឈ្មោះ ថាច់ ឡុង ធ្វើជាទាហានបារាំងនៅក្នុងអំឡុងសង្គ្រាមលោកលើកទី១ (១៩១៤-១៩១៨) ។ កាលពីកុមារ ថាច់ ចូវ មិនចេះនិយាយភាសាវៀតណាមទេ ឃើញដូច្នេះ ឪពុករបស់គាត់ក៏បញ្ជូនគាត់ឲ្យចូលរៀនក្នុងសាលាវៀណាម រយៈពេលបីឆ្នាំ ។ បន្ទាប់ពីរៀនចប់ ថាច់ ចូវ បានចូលរៀននៅសាលាត្រាវិញ ឬ (Franco Khmer) សម្រាប់ជនជាតិខ្មែរកម្ពុជាក្រោមជាមួយ សុន សេន ដែលស្ថិតក្នុងទីរួមខេត្តត្រាវិញដែលមានមានចម្ងាយ៦គីឡូម៉ែត្រពីផ្ទះរបស់គាត់ ចំណែកសិស្សជនជាតិវៀតណាមត្រូវចូលរៀននៅសាលា (Franco Namic) ដែលនៅដាច់ដោយឡែកពីសិស្សខ្មែរកម្ពុជាក្រោម ។ រៀងរាល់ថ្ងៃ ថាច់ ចូវ និង សុន សេន ដែលរស់នៅភូមិសំបួរលិច (ដែលមានចម្ងាយប្រមាណជិតមួយគីឡូម៉ែត្រពីផ្ទះរបស់ ថាច់ ចូវ) បានដួសបាយដាក់ត្រឡោកដូងខ្ចប់ទុកសម្រាប់ហូបពេលម៉ោងសម្រាកថ្ងៃត្រង់ជាមួយគ្នា រួចចូលរៀនបន្តរហូតដល់ពេលល្ងាចទើបត្រឡប់មកផ្ទះវិញ ។

ក្រោយមក ដោយសារភូមិដៃទឹងដែល ថាច់ ចូវ រស់នៅនៅមានចលនាខ្មែរឥស្សរៈ និងខ្មែរវៀតមិញចូលគ្រប់គ្រង គាត់ក៏ឈប់រៀនមួយរយៈ ។ ចំណែក សុន សេន បានរៀនចប់ រួចបន្តទៅរៀននៅសាលាគរុវិជ្ជាក្នុងទីក្រុងភ្នំពេញ ។ ខណៈនោះ ថាច់ ចូវ ក៏សម្រេចចិត្តរត់មកបួសជានេននៅវត្តត្រានាត ក្នុងខេត្តត្រាវិញ ដើម្បីគេចពីការធ្វើបាប និងការអុកឡុកពីចលនាខ្មែរឥស្សរៈ និងវៀតមិញនៅក្នុងភូមិ ។ ថាច់ ចូវ បានសុំសាលាចូល រៀនបន្ត ប៉ុន្តែគ្រូបង្រៀនភាសាបារាំងបានបដិសេធ ដោយលើកហេតុផលថា គាត់ឈប់រៀនយូរហើយ ហើយរៀនក៏មិនទាន់សិស្សនៅក្នុងថ្នាក់ដែរ រួចក៏ប្រាប់ឲ្យគាត់ត្រឡប់ទៅជួយឃ្វាលគោ-ក្របី និងជួយធ្វើស្រែ-ចម្ការឪពុកម្តាយវិញ ។ ពាក្យស្តីបន្ទោសនេះភ្លាម ថាច់ ចូវ អាក់អន់ចិត្តយ៉ាងខ្លាំង ប៉ុន្តែដោយសារមានបំណងចង់ចូលរៀនបន្ត គាត់ក៏បានទៅសុំម្តាយដើម្បីមករៀនបន្តនៅភ្នំពេញទៀត ។

នៅឆ្នាំ១៩៥១ ថាច់ ចូវ បានលាចាកសិក្ខាបទ រួចហើយក៏សម្រេចចិត្តជិះកប៉ាល់ហុកប៊ុក (កប៉ាល់ទឹក) មកទីក្រុងភ្នំពេញ ទោះបីជាគាត់មិនមានផ្ទះបងប្អូនឬមិត្តភក្តិសម្រាប់ស្នាក់នៅក៏ដោយ ។ នៅលើកប៉ាល់ ថាច់ ចូវ បានជួបនឹងព្រះសង្ឃមួយអង្គនៅខេត្តត្រាវិញបានចេញមករៀនបាលីនៅភ្នំពេញ ពេលវិស្សមកាល ។ បន្ទាប់ពីការសាកសួរហើយ ហើយដោយមានការពេញចិត្តនិងអាណិតអាសូរ ថាច់ ចូវ ព្រះសង្ឃនោះបានសន្យាថា ពេលមកដល់ភ្នំពេញគាត់នឹងយក ថាច់ ចូវ ទៅផ្ញើជាមួយព្រះសង្ឃក្នុងវត្ត


ថាច់ ចូវ

ខណ្ឌលោម ។ ទៅដល់វត្ត ថាច់ ចូវ មិនបានជួបនឹងព្រះចៅអធិការទេព្រោះព្រះអង្គមានធុរៈចេញទៅក្រៅ ដូច្នេះគាត់ក៏ទៅជួបនឹងព្រះចៅអធិការរង ប៉ុន្តែព្រះអង្គបានបដិសេធដោយសារនៅតាមកុដិមានកូនសិស្សរស់នៅពេញអស់ហើយ ។ ខណៈនោះ ដោយសារគ្មានអ្នកទីពឹងទៀត ថាច់ ចូវ បានអង្វរព្រះចៅអធិការរងមកដេកនៅរោងបាយ ។ ថ្ងៃមួយ ថាច់ ចូវ បានជួបនឹងលោកគ្រូម្នាក់ដែលមានស្រុកកំណើតនៅកម្ពុជាក្រោម ដែលមកបង្រៀននៅសាលាជីវឌ្ឍកុ្នងស្រុកកៀនស្វាយ និង ធ្លាប់រស់នៅកុដិក្នុងវត្តខណ្ឌលោមពីមុនមកបានហៅ ថាច់ ចូវ ឲ្យទៅនៅជាមួយដោយសារតែឃើញការលំបាករបស់គាត់ ។

ថាច់ ចូវ បានចូលរៀនរយៈពេលមួយឆ្នាំកន្លះ គាត់ក៏បានប្រឡង (Certificat) ជាប់ ដើម្បីចូលរៀន បន្តនៅវិទ្យាល័យ ប៉ុន្តែដោយសារគាត់មានអាយុ២១ឆ្នាំហើយ (សាលាបានកំណត់អាយុសិស្សក្រោម១៦ឆ្នាំទើបអាចចូលរៀនបាន) ទើបគាត់ប្រឡងចូលរៀននៅសាលាគរុវិជ្ជាផ្នែកគ្រូបឋមសិក្សាដែលស្ថិតនៅខាងក្រោយវិទ្យាល័យព្រះស៊ីសុវត្ថិ (បច្ចុប្បន្នអនុវិទ្យាល័យដូនពេញ) ។ នៅឆ្នាំទី១ ថាច់ ចូវ បានរៀនជាមួយលោកគ្រូ ខៀវ សំផន បង្រៀនផ្នែកគណិតវិទ្យា រយៈពេល៣ម៉ោងក្នុងមួយសប្តាហ៍ ។ រៀងរាល់ម៉ោងបង្រៀនលោកគ្រូ ខៀវ សំផន បានយកចិត្តទុកដាក់ពន្យល់មេរៀនទៅសិស្សនៅក្នុងថ្នាក់បានយ៉ាងក្បោះក្បាយ ប៉ុន្តែគាត់មិនដែលនិយាយលេងជាមួយសិស្សទេ ហើយជាគ្រូដែលតឹងរ៉ឹងជាងគេក្នុងពេលប្រលង ។ ទោះបីជា ខៀវ សំផន ជាមនុស្សស្ងប់ស្ងាត់ និងម៉ឺងម៉ាត់ក៏ដោយ ក៏សិស្សនៅក្នុងថ្នាក់នៅតែពេញចិត្តនឹងការបង្រៀនរបស់គាត់ដែរ ។ នៅក្នុងឆ្នាំទីពីរ ឆ្នាំ ១៩៥២ ថាច់ ចូវ មិនបានរៀនជាមួយលោកគ្រូ ខៀវ សំផន ទៀតទេ ព្រោះគាត់ត្រូវចេញទៅរៀនបន្តនៅប្រទេសបារាំង ដូច្នេះសាលាបានយកគ្រូជនជាតិបារាំងមកបង្រៀនជំនួសវិញ ដែលធ្វើឲ្យសិស្សនៅក្នុងថ្នាក់ទាំងអស់រអ៊ូរទាំ និងខឹងយ៉ាងខ្លាំង ដោយសារគ្រូជនជាតិបារាំងនោះពន្យល់មិនបានក្បោះក្បាយ និងពិបាកក្នុងស្តាប់ភាសារបស់គាត់ផង ។

នៅឆ្នាំ១៩៥៦ ថាច់ ចូវ ប្រឡងបញ្ចប់គរុកោសល្យនិងត្រូវចេញទៅបង្រៀននៅវិទ្យាល័យព្រះមុន្នីវង្សក្នុងខេត្តបាត់ដំបង ។ បង្រៀនបានរយៈពេលពីរឆ្នាំ ថាច់ ចូវ ដាក់ពាក្យប្រឡងជាប់ផ្នែកគ្រូមធ្យមសិក្សានៅសាលាគរុវិជ្ជា ប្តុសាលា (INP) ស្ថិតនៅខាងជើងវិមានឯករាជ្យ ក្រុងភ្នំពេញដែលមានលោកគ្រូ កេង វ៉ាន់សាក់ ជានាយក និង សុន សេន ជានាយករង ។ នៅពេលវិស្សមកាលឆ្នាំសិក្សាទី១ ថាច់ ចូវ ទៅលេងស្រុកកំណើតនៅភូមិដៃទឹងខាងជើងខេត្តត្រាវិញ ខណៈនោះ សុន សេន ក៏បានផ្តាំផ្ញើពាក្យសួរសុកទុក្ខមួយចំនួន តាម ថាច់ ចូវទៅម្តាយរបស់គាត់ដែលរស់នៅក្នុងភូមិសំបូរលិច ។ បន្ទាប់ពីត្រឡប់មកដល់ភ្នំពេញវិញ ថាច់ ចូវ បានចូលរៀនបន្តនៅឆ្នាំទី២ ប៉ុន្តែគាត់មិនបានជួបជាមួយនឹង សុន សេន ដូចមុនទៀតទេ ព្រោះគាត់បានរត់ចូលព្រៃដើម្បីធ្វើចលនាប្រឆាំងជាមួយនឹងរដ្ឋាភិបាលសម្តេចសីហនុ ។

នៅឆ្នាំ១៩៦១ ថាច់ ចូវ បានចេញទៅបង្រៀននៅវិទ្យាល័យបាភ្នំ ក្នុងស្រុកបាភ្នំ ខេត្តព្រៃវែង ។ នៅពេលបង្រៀន ថាច់ ចូវ តែងតែយកចិត្តទុកដាក់ក្នុងការពន្យល់ និងជួយសិស្សខ្សោយ និងសិស្សក្រីក្រដែលធ្វើឲ្យគាត់មានការរាប់អានពីសំណាក់សិស្សនិងប្រជាជនដែលរស់នៅទីនោះជាច្រើន ។ បង្រៀនបានមួយរយៈ ថាច់ ចូវ បានឡើងតំណែងជានាយកវិទ្យាល័យបាភ្នំ រហូតដល់ឆ្នាំ១៩៧០ ក៏មានចលនានយោបាយក្នុងសាលាទាំងមូលដែលធ្វើឲ្យមានភាពច្របូកច្របល់ ហើយសិស្សមួយចំនួន


ខៀវ សំផន និង សុន សេន (ពាក

បានរត់ចូលព្រៃ និងមួយចំនួនទៀតបានឈប់រៀនរួចចូលធ្វើការ ងាររប្រវាស់ដៃតាមភូមិ ។ ក្រោយមក ដោយសារកន្លែងស្នាក់នៅរបស់ ថាច់ ចូវ នៅឆ្ងាយពីទីប្រជុំជន ហើយស្រុកកំណើតនៅស្រុកត្រាំវិញ និងពិបាកក្នុងការបញ្ជូនកូនឲ្យចូលរៀននៅសាលានៅឆ្នាំ១៩៧១ គាត់ក៏សុំក្រសួងអប់រំផ្លាស់មកធ្វើជានាយកការិយាល័យអភិបាលនៅវិទ្យាល័យព្រះសូរិយាវង្សវិញ (បច្ចុប្បន្ន វិទ្យាល័យស្វាយរៀង) ស្ថិតក្នុងទីរួមខេត្តស្វាយរៀង ។

នៅឆ្នាំ១៩៧៥ ថាច់ ចូវ និងគ្រួសារត្រូវខ្មែរក្រហមជម្លៀសឲ្យទៅនៅភូមិតាសួស ។ នៅទីនោះបានរយៈពេលប្រហែល ៧ថ្ងៃ ថាច់ ចូវ បានបែកពីប្រពន្ធដោយមានតែខោអាវមួយកំប្លេប៉ុណ្ណោះ ព្រោះខ្មែរក្រហមបានឃោសនាប្រាប់ថា ឲ្យគាត់ទៅចូលរួមប្រជុំនៅភូមិលើទាល ស្រុកស្វាយជ្រុំ ប៉ុន្តែខ្មែរក្រហមបែរជាបញ្ជូនគាត់ទៅនៅសាលារៀនមួយខ្នងដែលស្ថិតនៅក្នុងភូមិព្រៃបឹង ឃុំម៉ឺនជ័យ ស្រុករំដួល បានរយៈពេល៣សប្តាហ៍ ទើបខ្មែរក្រហមបញ្ជូនគាត់ឲ្យទៅរៀនពីសីលធម៌របស់បក្ស និងការបែងចែកប្រជាជនចាស់-ថ្មី នៅវត្តទួលប្រស្រីក្នុងស្រុករំដួល ។

បន្ទាប់ពីរៀនចប់នៅឆ្នាំ១៩៧៦ ខ្មែរក្រហមបានប្រាប់ ថាច់ ចូវ ឲ្យមកនៅភូមិអង្គាសដី ឃុំតាសួស ស្រុកស្វាយរៀង (បច្ចុប្បន្នស្រុកស្វាយជ្រុំ) វិញ ប៉ុន្តែគាត់មិនបានជួបជុំគ្រួសារវិញទេ ព្រោះប្រពន្ធនិងកូនរបស់គាត់បានរត់ភៀសខ្លួនទៅកម្ពុជាក្រោមអស់ហើយ ហើយខ្មែរក្រហមក៏បានចាត់តាំងគាត់ឲ្យចូលធ្វើការក្នុងកងផលិតជីលេខ១ (លាមកមនុស្ស) ។ នៅឆ្នាំដដែល នៅវេលាម៉ោងប្រមាណ១០ព្រឹក ពេល ថាច់ ចូវ ដើរពីកន្លែងធ្វើជីត្រឡប់មកផ្ទះក៏បានជួបនឹង សុន សេន ដែលជិះលើរថយន្តហ្ស៊ីប ចុះទៅត្រួតពិនិត្យកងទ័ពនៅព្រំដែន ស្ថិតនៅជិតវត្តតាសួស ប៉ុន្តែទោះបីធ្លាប់ជាមិត្តភក្តិរៀនជាមួយគ្នានៅសាលាត្រាំវិញក៏ដោយ ក៏ សុន សេន មិនបាននិយាយទៅរកគាត់ដែរ ។



នៅក្នុងកងផលិតជី ខ្មែរក្រហមបានស្នើ ថាច់ ចូវ ចំនួនពីរលើកឲ្យយកគ្រួសារថ្មី ប៉ុន្តែគាត់បានបដិសេធដោយលើកហេតុផលថា គាត់អាចរស់នៅម្នាក់ឯងបាន ។ នៅថ្ងៃមួយ ពេល ថាច់ ចូវ ដើរទៅធ្វើការនៅកន្លែងផលិតជីដែលស្ថិតនៅជិតវត្តតាសួស ស្រាប់តែមានកម្មាភិបាលប្រធានផ្នែកសុខាភិបាលម្នាក់ដែលជាអតីតសិស្សរបស់គាត់នៅវិទ្យាល័យបាភ្នំបានមកឈប់កង់ក្បែរគាត់ រួចដោះមួកចេញហើយស្រែកថា "លោកគ្រូស្គាល់ខ្ញុំទេ!" ប៉ុន្តែដោយ សារ ថាច់ ចូវ ឈប់បង្រៀននៅ ទីនោះយូរហើយ គាត់ក៏ឆ្លើយ តបវិញថា "ខ្ញុំចាំមុខបានប៉ុន្តែឈ្មោះខ្ញុំភ្លេចហើយ" បន្ទាប់ពីសួរសុខទុក្ខគាត់រួចមក កម្មាភិបាលនោះក៏ទៅផ្តាំផ្ញើប្រធានកង និងគណៈឃុំឲ្យជួយថែទាំ ថាច់ ចូវ ព្រោះគាត់ជាកម្មាភិបាលតស៊ូផ្ទៃក្នុង ។ មួយរយៈក្រោយមកដោយឃើញ ថាច់ ចូវ នៅតែម្នាក់ឯង ខ្មែរក្រហមបានរៀបចំជាលើកទីបីដើម្បីឲ្យគាត់យកគ្រួសារថ្មី ខណៈនោះសិស្សរបស់គាត់ដែលជាកម្មាភិបាលខ្មែរក្រហមក៏បានមកប្រាប់ ថាច់ ចូវ ថា សូមលោកគ្រូទទួលទៅ ព្រោះប្រសិនបើបដិសេធម្តងនេះ ខ្មែរក្រហមប្រាកដជានឹងយកលោកគ្រូទៅសម្លាប់មិនខាន ។ ដោយដឹងហេតុការណ៍នេះមុន ថាច់ ចូវ បានយល់ព្រម ប៉ុន្តែនារីជាច្រើននៅក្នុងកងបានបដិសេធដោយសារតែគាត់ជាខ្មែរកម្ពុជាក្រោមដែលជាមុខសញ្ញារបស់ខ្មែរក្រហម ។ ទោះបីជាមានការភ័យខ្លាចនឹងអត្តសញ្ញាណរបស់ ថាច់ ចូវ ក៏ដោយ ក៏មាននារីម្នាក់បានយល់ព្រមទទួលគាត់ជាស្វាមីដែរ និងមករស់នៅជួបជុំគ្នានៅភូមិមេភ្លើង សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀងរហូតមក ។

ក្រោយពេលរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ ថាច់ ចូវ បានសម្រេចចិត្តត្រឡប់ទៅភ្នំពេញ ប៉ុន្តែត្រូវរដ្ឋមន្ត្រីក្រសួងអប់រំស្នើគាត់ឲ្យបានចូលជួយការងារនៅមន្ទីរអប់រំខេត្តស្វាយរៀងវិញ ។ សព្វថ្ងៃ ទោះបី ថាច់ ចូវ មានអាយុ៨០ឆ្នាំ និងចូលនិវត្តន៍ហើយក៏ដោយ ក៏គាត់នៅតែឆ្លៀតពេលទៅជួយការងារ និងបង្រៀនភាសាបារាំងដល់ក្មេងៗនៅមណ្ឌលកុមារកំព្រាដែរ ។ **សោម ប៊ុនថន**

# សេង ពិសិដ្ឋនារី : បាត់បង់ឪពុកដោយមិនដឹងពីមូលហេតុ

សេង ពិសិដ្ឋនារី មានបងប្អូនចំនួនបួននាក់ (ស្រីពីរនាក់ និង ប្រុសពីរនាក់) ។ ឪពុករបស់ នារី ត្រូវខ្មែរក្រហមយកទៅសម្លាប់ ដោយមិនដឹងមូលហេតុ ចំណែកបងប្រុសពីរនាក់ទៀតបាត់ខ្លួន រហូតដល់សព្វថ្ងៃនេះ ។ នារី បានរៀបរាប់អំពីរបបខ្មែរក្រហមទាំង ស្រក់ទឹកភ្នែកថា ៖ នៅឆ្នាំ ១៩៧៥ ខ្ញុំនិងក្រុមគ្រួសារមានគ្នាប្រ ហែលជា១០នាក់ត្រូវបានខ្មែរក្រហមជម្លៀសចេញពីទីក្រុង ភ្នំពេញតាមផ្លូវលេខជាតិ២ឆ្ពោះទៅស្រុកត្រាំកក់ ខេត្តតាកែវ ។ នៅទីនោះ ខ្មែរក្រហមបានចាត់តាំងឲ្យគ្រួសាររបស់ខ្ញុំស្នាក់នៅលើ ផ្ទះឈើតូចមួយខ្នងដែលមានសមាជិកប្រហែលជា១០នាក់ ។ បន្ទាប់ មក ប្រធានកងបានចាត់តាំងឲ្យម្តាយខ្ញុំចូលក្នុងកងស្រីៗ ឪពុកខ្ញុំនៅ ក្នុងកងឃ្វាលគោ ពូនិងបងប្រុសខ្ញុំនៅក្នុងកងយុវជន បងស្រីនៅក្នុង កងកុមារ និងខ្ញុំនៅក្នុងមណ្ឌលមើលក្មេងៗ (មិនទាន់បានចូលក្នុងកង កុមារទេ) ។ មួយរយៈក្រោយមក ប្រធានកងស្រាប់តែនិយាយ ថា ខ្ញុំជិតគ្រប់អាយុចូលទៅក្នុងកងកុមារហើយ រួចក៏ដកខ្ញុំទៅកងថ្មី មួយទៀត គឺនៅជាមួយយាយរបស់ខ្ញុំវិញ ។

នៅឆ្នាំ១៩៧៨ ម្តាយរបស់ខ្ញុំបានប្រាប់ខ្ញុំថា «ម៉ែបានឃើញ បងប្រុសធំរបស់កូននៅក្នុងកងយុវជនមានជំងឺហើមស្ទេកស្វាំង


សេង ពិសិដ្ឋនារី

ដើរមិនរួចទេ ព្រមទាំងមានទឹកមុខក្រៀមក្រំទៀត ពេលដែលមក ជួបម៉ែដើម្បីរកបបរហូប» ។ ពីរ-បីថ្ងៃក្រោយមក ខ្ញុំខានបាន ជួបគាត់រហូត ។ ក្រោយពីបងប្រុសរបស់ខ្ញុំបាត់ខ្លួនមិនបានប៉ុន្មាន ថ្ងៃផងឪពុករបស់ខ្ញុំក៏បានរបួសជើង ដោយសារធ្លាក់ពីលើដើម អម្ពិល ។ របួសនោះធ្ងន់រហូតដល់ដើរមិនរួច ប្រធានកងក៏បញ្ជូន ឪពុករបស់ខ្ញុំទៅព្យាបាលនៅក្នុងមន្ទីរពេទ្យមួយរយៈពេលប្រហែល ជាមួយសប្តាហ៍ ។ ក្រោយពេលត្រឡប់មកសម្រាកនៅផ្ទះបានពីរ យប់ ថ្ងៃមួយនៅវេលាម៉ោងប្រហែលជា៦យប់ ស្រាប់តែប្រធាន កងឃ្វាលគោឈ្មោះ គាតិប កាន់ខ្សែគោមួយចន្លាយធំដើរតម្រង់ មកផ្ទះរបស់ខ្ញុំ ហើយស្រែកហៅឪពុករបស់ខ្ញុំថា «អើយសមមិត្ត ម៉ុន គេហៅឲ្យទៅប្រជុំនៅក្នុងរោងគោ» ។ ពេលនោះ ឪពុកខ្ញុំបាន ឆ្លើយតបវិញថា «បងអញ្ជើញទៅមុនចុះចាំខ្ញុំទៅតាមក្រោយ» ។ ខ្ញុំនៅចាំព្រឹត្តិការណ៍យប់នោះយ៉ាងច្បាស់ថា «ខ្ញុំបានឃើញកាយ វិការរបស់ឪពុកខ្ញុំហាក់ដូចជាគាត់បានដឹងមុនថា គាត់ប្រាកដជា ខ្មែរក្រហមយកទៅសម្លាប់ហើយ» ។ បន្ទាប់មក គាត់បានឲ្យបងស្រី របស់ខ្ញុំចងមុង ហើយគាត់ដើរមកជិតខ្ញុំ ហើយថើបខ្ញុំនិងបងស្រីខ្ញុំ រួចបានផ្តាំទៅបងស្រីខ្ញុំថា «កុំវាយប្អូន មើលប្អូនផង ប៉ាទៅរោង គោប្រជុំមួយភ្លែត ប៉ាមកវិញឥឡូវហើយ» ។ ចាប់តាំងពីពេល នោះមក ឪពុករបស់ខ្ញុំក៏បាត់ដំណឹងរហូត ។

នៅពេលដែលយាយខ្ញុំ ម្តាយខ្ញុំ និងបងស្រីខ្ញុំដឹងថា ឪពុកខ្ញុំ បាត់ខ្លួន ស្រាប់តែសំឡេងទ្រហោយំបានលាន់ឮជាខ្លាំង រហូតធ្វើឲ្យ ខ្ញុំភ្ញាក់ដឹងខ្លួន រួចដើរមកជិតពួកគាត់សួរថា ហេតុអីបានជាយំ? ពួកគាត់បានប្រាប់ខ្ញុំថា ឪពុកយើងបានស្លាប់ហើយ ។ ដោយសារ តែខ្ញុំមានអាយុ៥ឆ្នាំ មិនទាន់យល់ពាក្យស្លាប់មានន័យអ្វីផង ទើបខ្ញុំ មិនបានយំនឹងគេទេ ហើយខ្ញុំតែងតែទៅរង់ចាំមើលផ្លូវឪពុករបស់ ខ្ញុំជារៀងរាល់ពេលល្ងាចក្រែងគាត់បានផ្លែឈើយកមកផ្ញើខ្ញុំ ព្រោះ នៅពេលដែលត្រឡប់មកពីឃ្វាលគោវិញ គាត់តែងបេះផ្លែត្របែក អម្ពិល និងផ្លែរំពាក់មកផ្ញើខ្ញុំជានិច្ច ។ ជាច្រើនលើកច្រើនសា ខ្ញុំនៅ

តែរង់ចាំផ្លូវឪពុករបស់ខ្ញុំ ពេលនោះ យាយរបស់ខ្ញុំព្រួយបារម្ភចំពោះខ្ញុំជាខ្លាំង ហើយតែងតែព្យាយាមពន្យល់ប្រាប់ខ្ញុំថា «ឪពុកចៅស្លាប់ហើយ កុំចាំមើលផ្លូវអី» ។

ប៉ុន្មានខែក្រោយមក ប្រធានកងក៏បានជម្លៀសគ្រួសាររបស់ខ្ញុំទៅរស់នៅក្នុងសហករណ៍មួយទៀតដែលមានរោងមួយយ៉ាងវែង ហើយមានមនុស្សរស់នៅជាច្រើន ទើបខ្ញុំឈប់ចាំមើលផ្លូវឪពុករបស់ខ្ញុំ ។ នៅទីនោះ ការរស់នៅមានសភាពតឹងតែងជាងកន្លែងមុនទៅទៀត ប្រសិនបើធ្វើអ្វីខុសអង្គការនឹងយកទៅសម្លាប់ជាមិនខាន ។ ជាក់ស្តែង ថ្ងៃមួយពេលដែលម្តាយរបស់ខ្ញុំនឹកឃើញឪពុកនិងបងប្រុសរបស់ខ្ញុំម្តងៗ គាត់យំកាន់តែខ្លាំងឡើងៗ រហូតធ្វើឲ្យប្រធានកង ឈ្មោះ យាយនួន បានគំរាមគាត់ថា «សមមិត្តឯងកុំយំ បើហ៊ានយំទៀត អញយកទៅសម្លាប់ចោលហើយ ព្រោះមិត្តខ្ញុំឯងយំបំផុសបំផុល អីចឹងមិត្តឯងជាខ្មាំង» ។ ម្តាយខ្ញុំក៏ឆ្លើយបានតបវិញថា «បើសម្លាប់ក៏សម្លាប់ចុះ ព្រោះប្តីនិងកូនប្រុសខ្ញុំស្លាប់អស់ហើយ» ។ ពេលនោះ យាយនួនមិនបានដាក់ទណ្ឌកម្មម្តាយរបស់ខ្ញុំទេ ។ ប៉ុន្តែ ក្រោយមក ស្រាប់តែមានអ្នករាយការណ៍ប្រាប់ យាយនួន ថា ឪពុកខ្ញុំគឺជាទាហានស័ក្តិ៥ ចំណែកម្តាយខ្ញុំស័ក្តិ៣ ។ ព្រឹកព្រាម យាយនួន នាំគ្នាទៅឆែកឆេរកន្លែងស្នាក់នៅរបស់ម្តាយខ្ញុំ រួចក៏រកឃើញហ្វូលផាមួងរបស់ម្តាយខ្ញុំដែលគាត់ខំលាក់ទុក (ពេលគាត់មានមុខរបរជាអ្នកលក់ហ្វូលផាមួង) ។ បន្ទាប់មក យាយនួន បានចោទម្តាយខ្ញុំថាជាពួកសក្តិភូមិ រួចបញ្ជាឲ្យចាប់ម្តាយខ្ញុំយកទៅឃុំទុកប្រហែលជា៥-៦ថ្ងៃ ។ នៅពេលល្ងាច នួន បានបណ្តើរម្តាយខ្ញុំយកទៅធ្វើទារុណកម្មដោយវាយនឹងខ្សែតីដើម្បីសួរចម្លើយ ។ នួន បានសួរម្តាយខ្ញុំថា «ស័ក្តិ៣មែន ឬមិនមែន?» ម្តាយខ្ញុំបានឆ្លើយតបវិញថា «គាត់មិនមែនស័ក្តិ៣ទេ គាត់គ្រាន់តែជាមេផ្ទះ និងមាន



សេង ពិសិដ្ឋនារី ទស្សនាវាលពិឃាតជើងឯក

លក់ហូលជាមួងប៉ុណ្ណោះ» ។ ដោយសារតែមិនជឿសម្ដីរបស់ម្ដាយខ្ញុំ នួន បានវាយម្ដាយរបស់ខ្ញុំ រហូតដល់មានស្នាមជាំពេញខ្លួន ។ ប៉ុន្តែ នៅតែរកមិនឃើញកំហុស នួន បែរជាដាក់ទណ្ឌកម្មឲ្យម្ដាយរបស់ខ្ញុំកាស់គល់ឈើក្នុងរយៈពេលបីថ្ងៃឲ្យហើយមួយគល់ បើមិនហើយតាមផែនការ ទេនឹងយកទៅសម្លាប់ចោលជាមិនខាន ។ ពេលនោះ ខ្ញុំបានត្រឹមតែអង្គុយក្រោមដើមត្រាវសម្លឹងមើលម្ដាយរបស់ខ្ញុំកាស់គល់ឈើតែម្នាក់ឯងប៉ុណ្ណោះ ។ ប៉ុន្តែ ម្ដាយរបស់ខ្ញុំសំណាងណាស់ ដោយនៅទីនោះប្រុសៗមានចិត្តអាណិតម្ដាយខ្ញុំរួចបានលួចទៅជួយកាស់គល់ឈើនោះឲ្យរួចតាមផែនការ ។ បន្ទាប់មក នួន បានដោះលែងម្ដាយខ្ញុំ ហើយបញ្ជូនគាត់ឲ្យទៅរស់នៅក្នុងកងធម្មតាវិញ ។

ចំណែកម្ដាយមីងរបស់ខ្ញុំក៏ត្រូវខ្មែរក្រហមធ្វើបាបស្ទើរតែបាត់បង់ជីវិតដែរ ។ ខ្ញុំនៅចាំបានថា ពេលមួយនៅវេលាថ្ងៃត្រង់ម្ដាយមីងរបស់ខ្ញុំឃើញអាវដែលទុកចោល គាត់ក៏បានទៅលួចកាត់ឡេវអាវនោះប្រហែលជាប្រាំឡេវអាវ ។ ពេលប្រធានកងមកទាន់ ក៏ដាក់ទណ្ឌកម្មគាត់ដោយប្រើឲ្យក្មេងៗជីករណ្ដៅមួយរួចឲ្យបងស្រីខ្ញុំនិងកុមារប្អូនប្រាំនាក់ទៀតយកដីលប់គាត់ ។ ប្រហែលជា៥-១០នាទីក្រោយមក ប្រធានកងបានប្រើឲ្យក្មេងៗទាំងនោះកាយដីចេញវិញ ។

នៅឆ្នាំ១៩៧៩ ខ្មែរក្រហមម្នាក់ (មិនចាំឈ្មោះ) ដែលជាអ្នកដើរតាម នួន បានមកប្រាប់ម្ដាយខ្ញុំឲ្យឆាប់នាំគ្នារត់គេចខ្លួនទៅព្រោះ «នួន មានគម្រោងការបញ្ជាឲ្យគេជីករណ្ដៅរួចហើយ ដើម្បីយកក្រុមគ្រួសារខ្ញុំទៅកម្ទេចចោល ដោយសារតែមានអ្នករាយការណ៍មកថា ម្ដាយខ្ញុំជាស័ក្តិ៣ ប្ដីស័ក្តិ៥» ។ ម្ដាយខ្ញុំឮដូច្នេះ គាត់បានប្រមូលបងប្អូន និងកូនៗទាំងអស់ឲ្យនៅជុំគ្នា រួចនាំគ្នារត់ភៀសខ្លួនមកទីក្រុងភ្នំពេញ ។ នៅតាមផ្លូវ ខ្ញុំបានឃើញមនុស្សស្លាប់និងរបួសជាច្រើនដោយសារគ្រាប់ផ្លោង និងការប្រយុទ្ធគ្នារវាងកងទ័ពខ្មែរក្រហមនិងកងទ័ពវៀតណាម ។ ធ្វើដំណើរជាច្រើនថ្ងៃក្រោយមក គ្រួសាររបស់ខ្ញុំក៏បានមកដល់ក្រុងភ្នំពេញវិញ ។

ពេលដែលទៅដល់លំនៅឋានដែលធ្លាប់រស់នៅ ម្ដាយរបស់ខ្ញុំសប្បាយចិត្តជាខ្លាំងព្រោះលែងរស់នៅក្នុងសភាពភ័យខ្លាចទៀតហើយ ។ ប៉ុន្តែ មួយសន្ទុះក្រោយមក ម្ដាយរបស់ខ្ញុំស្រាប់តែស្រក់ទឹកភ្នែកដោយមិនដឹងខ្លួន ព្រោះនឹកដល់កូនដែលបានបាត់ខ្លួននៅក្នុងរបបនោះ ។ ដោយមិនអស់ចិត្ត ម្ដាយរបស់ខ្ញុំបានរើសដុំថ្មមួយកូនដុំមកសរសេរលើជញ្ជាំងផ្ទាំទៅបងប្រុសរបស់ខ្ញុំថា «ឪពុកកូនស្លាប់ហើយ ម្ដាយនៅរស់ទេ បើកូននៅរស់ ហើយឃើញអក្សរនេះ កូនចាំម្ដាយនៅទីនេះ ម្ដាយនឹងមកជួបកូន» ។

នៅឆ្នាំ១៩៨១ ម្ដាយរបស់ខ្ញុំបានធ្វើជាគ្រូបង្រៀននៅសាលាបឋមសិក្សាបឹងសាឡាង ហើយខ្ញុំក៏បានចូលរៀននៅទីនោះដែរ ។ នៅឆ្នាំ១៩៩១ ខ្ញុំបានប្រឡងជាប់បាក់ឌុប ហើយបានដាក់ពាក្យប្រឡងធ្វើជាគ្រូបង្រៀនផ្នែកអក្សរសាស្ត្រនិងមនុស្សសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញទៀត ។ នៅឆ្នាំ១៩៩៦ ខ្ញុំបានទៅបង្រៀននៅវិទ្យាល័យ ជា ស៊ីម ខេត្តតាកែវ ។ មួយឆ្នាំក្រោយមក ខ្ញុំក៏បានផ្លាស់មកបង្រៀននៅសាលានាយកដ្ឋានស្រាវជ្រាវគរុកោសល្យទីក្រុងភ្នំពេញវិញ ។

នៅឆ្នាំ២០០៩ ខ្ញុំត្រូវបានក្រសួងអប់រំ យុវជន និងកីឡាសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាជ្រើសរើសធ្វើជាគ្រូបង្គោលថ្នាក់ជាតិ បង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ ខ្ញុំសប្បាយចិត្តជាខ្លាំងដែលខ្ញុំមានវត្តមាននៅក្នុងកម្មវិធីនេះ ព្រោះអាចជួយផ្សព្វផ្សាយឲ្យសិស្សបានដឹងកាន់តែច្រើនពីរបបខ្មែរក្រហម ជាពិសេសអប់រំពីអំពើប្រល័យពូជសាសន៍កុំឲ្យកើតមានជាលើកទីពីរទៀត ។ «វាពិតជាមានសារសំខាន់ណាស់សម្រាប់សិស្សនៅតាមសាលាក៏ដូចជាក្មេងៗជំនាន់ក្រោយទៀតបានដឹងពីប្រវត្តិសាស្ត្ររបស់ខ្លួន» ។ **ស សេងគា**

## គម្រោងអប់រំពីអំពើប្រល័យពូជសាសន៍

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ១៩៧៥-១៩៧៩» និង «សៀវភៅណែនាំគ្រូបង្រៀន» ដែលមានជាភាសាខ្មែរ និងអង់គ្លេស ។ ប្រសិនបើសាធារណជនចង់អាន សូមមើលតាមរយៈគេហទំព័រ

*http://dccam.org/Projects/Genocide/Khmer.htm*

*http://dccam.org/Projects/Genocide/pdf/DC-Cam_%2 0Teacher_Guidebook_Kh.pdf*

# សេក សុខា គ្រូបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

សេក សុខា ជាគ្រូបង្រៀនថ្នាក់ជាតិ ផ្នែកប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ។ សេក សុខា បានធ្វើជាគ្រូបង្រៀនបន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ ១៩៧៩ ។ គាត់បានរៀបរាប់ខាងក្រោមនេះថាៈ

នៅក្នុងរបបខ្មែរក្រហម ខ្ញុំបានបាត់បង់ ឪពុក បងប្រុស ព្រមទាំងប្រពន្ធនិងកូន ពូ-មីងជាច្រើននាក់ ដោយសារធ្វើការងារហួសកម្លាំង ជំងឺ និងការអត់អាហារបរិភោគ ។

ខ្ញុំមានអាយុ៥៨ឆ្នាំ កើតនៅភូមិត្រពាំងក្រសាំង ឃុំត្រពាំងក្រសាំង ស្រុកបាទី ខេត្តតាកែវ ។ ខ្ញុំមានបងប្អូនបង្កើត ៩នាក់ ប្រុស៤នាក់ និង ស្រី៥នាក់ ។ ខ្ញុំមានឪពុកឈ្មោះ សេក សំ និង ម្តាយឈ្មោះ អ៊ុង ខែម ធ្វើស្រែ ប៉ុន្តែរៀងរាល់ឆ្នាំក្រោយពេលប្រមូលផលស្រូវរួច ម្តាយរបស់ខ្ញុំចាប់ផ្តើមត្បាញក្រមា សារុងសូត្រ រហូតបានចំនួនច្រើន ទើបឪពុករបស់ខ្ញុំ រៀបចំចងដាក់លើចង្អេរកង់ដឹកយកទៅលក់នៅតាមបណ្តាខេត្តនានារយៈពេល១-២ខែ ទើបគាត់ត្រឡប់មកផ្ទះម្តងដើម្បីយកប្រាក់មកផ្គត់ផ្គង់ជីវភាពក្នុងគ្រួសារ និងកូនៗទៅរៀនសូត្រ ។

នៅអាយុ៦ឆ្នាំ ខ្ញុំបានចូលរៀននៅសាលាបឋមសិក្សាអង្គរុន ដែលមានចម្ងាយមួយគីឡូម៉ែត្រពីផ្ទះរបស់ខ្ញុំ ។ ខ្ញុំមិនដែលរៀនត្រួតថ្នាក់ទេ ទោះបីខ្ញុំរវល់ជួយធ្វើស្រែ និងជួយការងារឪពុកម្តាយនៅផ្ទះក៏ដោយ ។ នៅឆ្នាំ១៩៦៧ ខ្ញុំបានប្រឡងជាប់ចូលរៀនថ្នាក់ទី៦ នៅវិទ្យាល័យចំបក់ (បច្ចុប្បន្នវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ចំបក់) ដោយផ្លាស់មកស្នាក់នៅផ្ទះជាមួយបងប្រុសទី១ ធ្វើជាគ្រូបង្រៀន ។ ក្រោយរដ្ឋប្រហារទម្លាក់សម្តេចសីហនុថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ប្រទេសចាប់ផ្តើមចលាចលដោយសារប្រជាជនបានតវ៉ាទាមទារឲ្យសម្តេចឡើងកាន់អំណាចវិញ ទើបសាលារបស់ខ្ញុំត្រូវបិទទ្វារ ។ ខណៈនោះបងប្រុសទី១របស់ខ្ញុំ ត្រូវរដ្ឋាភិបាលសាធារណរដ្ឋខ្មែររបស់លោក លន់ នល់ តម្រូវឲ្យគាត់ចូលធ្វើទ័ពប្រចាំការនៅខេត្តតាកែវ ។ ឃើញដូច្នេះ ឪពុកម្តាយមិត្តភក្តិរបស់ខ្ញុំជាច្រើនចាប់ផ្តើមមានការបារម្ភ រួចក៏បញ្ជូនកូនៗរបស់ខ្លួនឲ្យទៅបួសជាព្រះសង្ឃដើម្បីគេចចេញពីការតម្រូវឲ្យចូលទ័ព ។ ចំណែកឪពុកម្តាយរបស់ខ្ញុំ មិនបានជំរុញខ្ញុំ និងក្មួយប្រុសម្នាក់ (កូនរបស់បងប្រុសដែលធ្វើគ្រូ) ដែលរៀននៅវិទ្យាល័យចំបក់ជាមួយគ្នាទៅបួសទេ គឺគាត់ឲ្យខ្ញុំនិងក្មួយនៅជួយធ្វើស្រែមួយរយៈសិន រង់ចាំសាលាបើកទ្វារទើបគាត់បញ្ជូនឲ្យចូលរៀនវិញ ។


សេក សុខា

ឪពុកម្តាយខ្ញុំតែងតែទូន្មានខ្ញុំថា "បើគាត់ជាអ្នកល្ងង់ហើយគាត់មិនចង់ឲ្យកូនចៅល្ងង់ដូចគាត់ទេ" និងបានជំរុញឲ្យខ្ញុំខិតខំរៀនថែមទៀត ដោយគាត់ពន្យល់ខ្ញុំថា នៅសម័យអាណានិគមបារាំង ឪពុកម្តាយជាច្រើនមិនសូវបញ្ជូនកូនឲ្យទៅរៀននៅសាលាទេ ព្រោះដោយសារមានជីវភាពខ្វះខាត ចំណែកសាលារៀនស្ថិតនៅឆ្ងាយពីផ្ទះទៀត ប៉ុន្តែទោះជាលំបាកយ៉ាងណាក៏ដោយ ក៏គាត់ខិតខំសន្សំលុយ ដើម្បីឲ្យបងប្រុសទី១ និងបងប្រុសទី៣ចូលរៀននៅសាលាក្នុងទីក្រុងភ្នំពេញដែរ ។ បងប្រុសខ្ញុំទាំងពីរនាក់បានស្នាក់នៅកុដិព្រះពោធិវង្ស ម៉ឹង តិល ក្នុងវត្តបទុមវតី រាជធានីភ្នំពេញ ដែលរៀងរាល់ខែឪពុករបស់ខ្ញុំបានដឹកជញ្ជូនអង្ករ ត្រីសាច់តាមរទេះគោក្នុងចម្ងាយ៥០គីឡូម៉ែត្រពីផ្ទះស្ថិតក្នុងភូមិត្រពាំងក្រសាំង យកទៅឲ្យបងខ្ញុំទាំងពីរនាក់ហូបជាប្រចាំ ។ ក្រោយមក ដោយសារការខិតខំប្រឹងរៀនសូត្រ បង

ប្រុសទី១បានប្រឡងជាប់គ្រូបឋមសិក្សា និងបងប្រុសទី៣បានប្រលងជាប់សាលាកសិកម្ម ។

ខ្ញុំរង់ចាំចូលរៀនរហូតដល់ឆ្នាំ១៩៧១ ប៉ុន្តែដោយសារនៅស្រុកបាទី ជាតំបន់ប្រទាញប្រទង់រវាងរដ្ឋាភិបាលសាធារណៈរដ្ឋខ្មែររបស់លោក លន់ នល់ និង ខ្មែរក្រហម ទើបសាលាមិនបានបើកទទួលសិស្សឲ្យចូលរៀនឡើងវិញទេ ។

ថ្ងៃមួយ បងប្រុសរបស់ខ្ញុំដែលធ្វើទាហាន លន់ នល់ ប្រចាំការនៅខេត្តតាកែវ បានលួចរត់គេចចេញពីបន្ទាយដើម្បីត្រឡប់មកផ្ទះវិញ ។ នៅតាមផ្លូវដែលមានចម្ងាយ៣៣គីឡូម៉ែត្រ បងប្រុសខ្ញុំបានដើរឆ្លងកាត់ខ្សែត្រៀមប្រយុទ្ធ ដោយជួបនឹងប៉ុស្តិ៍ត្រួតពិនិត្យរបស់កងទ័ពខ្មែរក្រហមជាច្រើនកន្លែង ប៉ុន្តែដោយសារគាត់និយាយកុហកថា ជាប្រជាជន ទើបខ្មែរក្រហមអនុញ្ញាតឲ្យគាត់បន្តដំណើរទៅមុខទៀត ចំណែកអ្នកដែលគេស្គាល់អត្តសញ្ញាណថាជាទាហាន លន់ នល់ ពិតប្រាកដហើយ កងទ័ពខ្មែរក្រហមនឹងបាញ់សម្លាប់អ្នកទាំងនោះចោលនៅនឹងកន្លែងតែម្តង ។ មកដល់ផ្ទះឪពុកម្តាយ បង ប្អូន និងបងថ្លៃស្រីរបស់ខ្ញុំសប្បាយចិត្តខ្លាំងណាស់ដោយបានជួបនឹងបងវិញ ។ នៅព្រឹកបន្ទាប់ ដោយមានការបារម្ភពីសុវត្ថិភាពរបស់បងទី១ព្រោះខ្លាចមានការចាប់ខ្លួន ឪពុកខ្ញុំបានឲ្យបងប្រុសទី៨ យកម៉ូតូ ជូនបងទី១ទៅទីក្រុងភ្នំពេញវិញ ដើម្បីបង្ហាញខ្លួននៅអគ្គសេនាធិការកងទ័ព លន់ នល់ បន្ទាប់មកក្រសួងក៏ចាត់តាំងគាត់បានចូលធ្វើការនៅផ្នែកហិរញ្ញវត្ថុយោធា ។ ក្រោយពីបងប្រុសទី១ធ្វើការបានមួយរយៈ និងមានផ្ទះស្នាក់នៅស្ថិតនៅជិតសាលាបឋមសិក្សាសន្សំកុសល្យហើយ គាត់ក៏ត្រឡប់ទៅយកប្រពន្ធ កូន និងខ្ញុំពីស្រុកកំណើតមកស្នាក់នៅជាមួយ ។ ខ្ញុំនិងក្មួយបានចូលបន្តរៀននៅថ្នាក់ទី៤សង្គមចាស់ នៅវិទ្យាល័យកម្ពុជបុត្រ ។ រៀងរាល់ថ្ងៃខ្ញុំ និងក្មួយ បានជិះកង់ទៅសាលារៀន ប៉ុន្តែយើងមានការលំបាកក្នុងការធ្វើដំណើរជាខ្លាំងនៅពេលមានភ្លៀងធ្លាក់ព្រោះទឹកលិចផ្លូវ និងលិចផ្ទះដែលខ្ញុំស្នាក់នៅ ។

នៅឆ្នាំ១៩៧២ ខ្ញុំបានប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ រហូតដល់ឆ្នាំ១៩៧៤ ទើបខ្ញុំប្រលងជាប់សញ្ញាប័ត្រមធ្យមសិក្សាប័ត្រភាគ១ និងត្រូវចូលរៀនថ្នាក់បញ្ចប់ ។ ប៉ុន្តែខ្ញុំមិនបានចូលរៀនទៀងទាត់ទេ ព្រោះរៀងរាល់ថ្ងៃមានការភិតភ័យដោយសារមានគ្រាប់ផ្លោងធ្លាក់នៅជិតផ្ទះរបស់ខ្ញុំស្នាក់នៅដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីផ្ទះរបស់លោក លន់ នល់ ។ ការបាញ់ផ្លោងបានអូសបន្លាយរហូតដល់ថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំឃើញមានកងទ័ពរបស់លោក លន់ នល់ ជាច្រើនជិះឡាន GMC និងរថក្រោះM១១៣ បើកតាមដងវិថីនានាត្រឡប់ចូលក្នុងទីក្រុងភ្នំពេញវិញដោយមានលើកទង់ជ័យសគ្រវីផង ។ នៅព្រឹកថ្ងៃបន្ទាប់ ដោយមិនដឹងពីសភាពការណ៍មុន បងប្រុសទី១របស់ខ្ញុំស្លៀកពាក់ឯកសណ្ឋានយោធា រួចហើយជិះម៉ូតូចេញទៅធ្វើការដូចសព្វដង ទៅដល់ផ្សារទួលទំពូងស្រាប់តែគាត់ឮស្នូរផ្ទុះអាវុធ និងមានកងទ័ពខ្មែរក្រហមជាច្រើនបានចូលមកដល់ទីក្រុង ។ ឃើញដូច្នេះ បងប្រុសទី១បានជិះម៉ូតូតាមផ្លូវវាងតូចៗត្រឡប់មករកប្រពន្ធនឹងកូននៅផ្ទះវិញ រួចហើយប្រញាប់ប្រញាល់ដោះឯកសណ្ឋានយោធាចេញដោយប្តូរមកស្លៀកក្រមាអំបោះវិញ ។ ខណៈនោះ ស្រាប់តែកងទ័ពខ្មែរ ក្រហមជាច្រើននាក់ដែលក្នុងដៃមានកាន់កាំភ្លើងបានមកដល់មុខផ្ទះ រួចសួរបងខ្ញុំថា តើផ្ទះនេះជាផ្ទះរបស់មេកង (៥០ខ្នងមានមេក្រុមម្នាក់ដែលគ្រប់គ្រងលើប្រជាជនចំនួន៥០គ្រួសារ)ឬ? ភ្លាមនោះ បងប្រុសទី១បានឆ្លើយតបទាំងអារម្មណ៍ភិតភ័យថា មិនមែនទេ ។ បន្ទាប់ពីកងទ័ពខ្មែរក្រហមចាកចេញអស់ បងប្រុសបានរៀបចំឥវ៉ាន់ រួចនាំយកប្រពន្ធទៅស្នាក់នៅផ្ទះរបស់ពូនៅម្តុំស្ថានកម្មករបឹងទំពុនដោយឲ្យខ្ញុំ និង ក្មួយ កូន របស់គាត់) នៅចាំផ្ទះ ។ ប្រមាណម៉ោង៨យប់ បងប្រុសទី៨ ជាទាហាន លន់ នល់ ដែលត្រូវគ្រាប់ក្នុងពេលវាយប្រយុទ្ធគ្នាជាមួយខ្មែរក្រហមនៅសមរភូមិស្វាយរលំក្នុងស្រុកស្អាង បណ្តាលឲ្យបាក់ជើង ហើយត្រូវមកសម្រាកព្យាបាលនៅមន្ទីរពេទ្យបុរីកីឡាបានមកគោះទ្វារស្រែកហៅឈ្មោះខ្ញុំទាំងខ្លួនមានជំងឺ ថា សុខៗ! ខ្ញុំក្រោកឡើងបើកទ្វារ ហើយត្រេកអរណាស់ដោយឃើញបងមកដល់ផ្ទះវិញ ព្រោះខ្ញុំមិនបានទៅមើលថែគាត់អស់រយៈពេលច្រើនថ្ងៃមកហើយ ហើយអ្នកជំងឺនៅក្នុងមន្ទីរពេទ្យជាច្រើនត្រូវខ្មែរ ក្រហមបាញ់សម្លាប់ចោលគ្មានសល់ ។

នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំ បង ពូ មីង សរុបទាំងអស់ប្រមាណ២០នាក់ បានមកជួបជុំគ្នានៅបឹងទំពុន រួចរៀបចំខោអាវ អីវ៉ាន់ ដាក់លើរទេះគោអូសចេញពីផ្ទះ ។ គ្រួសារ ខ្ញុំមក

សម្រាកនៅចំការដូងមួយយប់ ហើយនៅព្រឹកបន្ទាប់ ទើបបន្តដំណើរទៅមុខទៀត ចំណែកបងប្រុសទី៨ដែលពិការជើងជិះកង់ដោយខ្លួនឯងទៅមុន។ ខណៈនោះ ដោយឃើញ បងប្រុសទី១ខ្ញុំមានខោអាវទាហាន លន់ នល់ នៅសេសសល់ក្នុងសាក់កាដូរស្ពាយយើងក៏ឲ្យគាត់បោះចោល ព្រោះនៅដូវខាងមុខខ្លាចកងទ័ពខ្មែរក្រហមឆែកឃើញច្បាស់ជាយកទៅសម្លាប់ចោលមិនខាន។ គ្រួសារខ្ញុំដើរទៅដល់រោងចក្រកែវដែលស្ថិតនៅតាមបណ្តោយផ្លូវចំម្ការដូង ស្រាប់តែឃើញបងទី៨របស់ខ្ញុំ បក់ដៃហៅយើងទាំងអស់គ្នាពីមាត់ទ្វារោងចក្រដើម្បីឲ្យទៅជួយ ប៉ុន្តែយើងមិនត្រូវបានអនុញ្ញាតឲ្យចូលបរិវេណនោះទេ ព្រោះមានសុទ្ធតែកងទ័ពខ្មែរក្រហមនៅឈរយាមការពារ។ ឃើញដូច្នេះ គ្រួសារខ្ញុំរន្ធត់ចិត្តខ្លាំងណាស់ ហើយប្រពន្ធ របស់គាត់បានយំយ៉ាងខ្លាំងព្រោះបងប្រុសត្រូវកងទ័ពខ្មែរក្រហមឃាត់ខ្លួនហើយ។ ខណៈ នោះដោយសារនៅតាមផ្លូវមានមនុស្សកកស្ទះ និងមិនអាចរង់ចាំបាន គ្រួសារខ្ញុំបានសម្រេចចិត្តបន្តដំណើរទៅមុខទាំងយំខ្សឹកខ្សួលទៅឈប់សម្រាកនៅវត្តព្រែកជ្រៃដើម្បីសម្រាកដាំបាយហូប ស្រាប់តែពេលនោះឃើញបងទី៨ដើរទ្រេតទ្រោត ដោយដៃម្ខាងឱបកន្ទេលចបូតមួយសំដៅមករកយើង រួចហើយរៀបរាប់ថា នៅទីនោះគាត់បានជួបនឹងមិត្តភក្តិម្នាក់ដែលរៀននៅវិទ្យាល័យចំបក់ជាមួយគ្នា ធ្វើជាមេបញ្ជាកងទ័ពខ្មែរក្រហមបានមកធានាឲ្យដោះលែងគាត់។

មកដល់ពាក់កណ្តាលផ្លូវគ្រួសារខ្ញុំសប្បាយចិត្តខ្លាំងណាស់ដោយសង្ឃឹមថា ឪពុកនឹងយករទេះគោមកទទួលត្រឡប់ទៅផ្ទះវិញ ប៉ុន្តែយើងមិនបានឃើញគាត់មកទេ ព្រោះភូមិត្រពាំងក្រសាំងខ្មែរក្រហមបានចូលគ្រប់គ្រងហើយ។ ខ្មែរក្រហមបានប្រជុំប្រាប់ប្រជាជនទាំងអស់នៅក្នុងភូមិថា (អ្នករស់នៅក្នុងតំបន់ លន់ នល់ ទាំងអស់គឺជាអ្នកចាញ់សង្គ្រាម ជាឈ្លើយសឹក) ហើយមិនត្រូវមានការរាក់ទាក់ ជាមួយអ្នកជម្លៀសមកថ្មីទាំងអស់នេះទេ ទោះបីជាកូន បងប្អូន ឬឪពុកម្តាយក៏ដោយ។ ក្រោយពីទទួលបានសេចក្តីប្រកាសនេះ ឪពុករបស់ខ្ញុំមិនហ៊ានប្រឆាំងទេ ទោះបីគាត់ដឹងថាកូនចៅត្រឡប់មកផ្ទះវិញក៏ដោយ ព្រោះពីមុនឪពុករបស់ខ្ញុំត្រូវខ្មែរក្រហមចាប់ខ្លួនយកទៅឃុំឃាំងម្តងរួចហើយ ដោយសារតែគាត់បានទៅសួរសុខទុក្ខកូនៗនៅភ្នំពេញ។ រយៈពេល៩ថ្ងៃក្រោយមក គ្រួសារខ្ញុំបានធ្វើដំណើរមកដល់ផ្ទះកំណើត និងបានជួបឪពុកម្តាយបងស្រីទី១ដែលជាអ្នកមូលដ្ឋានបញ្ញើ (ព្រោះមានបងប្រុសពីរនាក់រស់នៅភ្នំពេញ និងធ្វើការនៅក្នុងកងទ័ពរដ្ឋាភិបាលសាធារណរដ្ឋខ្មែររបស់លោក លន់ នល់) ដោយធ្វើឲ្យខ្ញុំមានក្តីនឹករព្ញក និងរន្ធត់ក្នុងចិត្តយ៉ាងខ្លាំងរហូតគ្រួសាររបស់ខ្ញុំឈរស្រក់ទឹកភ្នែកទាំងអស់គ្នា។ ខណៈនោះ ដោយដឹងថាយើងជួបជុំគ្នាកងឈ្លបក៏ចូលមកឆែកឆេរលើផ្ទះខ្ញុំពុកខ្ញុំ និងរឹបអូសយកសម្ភារៈមួយចំនួនដែលគាត់យកមកពីភ្នំពេញ។ គ្រួសារខ្ញុំ និងប្រជាជនក្នុងភូមិត្រូវទៅបើករបបអង្ករពីសេដ្ឋភូមិដោយទទួលបានរបបម្នាក់មួយកំប៉ុងក្នុងមួយថ្ងៃយកមកដាំហូបរៀងៗខ្លួន។ រយៈពេល៣ថ្ងៃក្រោយមក អង្គការបានប្រាប់ខ្ញុំ និងប្រជាជនក្នុងស្រុក៥៦ (ស្រុកបាទី) ជាច្រើនពាន់នាក់ទៀតឲ្យទៅចូលរួមសន្និបាតនៅកន្លែងយុទ្ធជន-យុទ្ធនារីពលីដែលស្ថិតនៅផ្សារចំបក់ (បច្ចុប្បន្នទល់គ្នានឹងសាលាស្រុកបាទី)។ អង្គការបានរៀបចំសង់វេទិកា ដោយមានបង់ក្រណាត់ចម្រុះពណ៌លំអរដោយផ្កាស្រស់ៗ និងនិមន្តព្រះសង្ឃមកសូត្រធម៌ប្រោះព្រំដល់គណៈអធិបតីដែលចូលរួម រួមដោយកម្មាភិបាលភូមិ ឃុំ ស្រុកជាច្រើនរូបផង។ អង្គការបានលើកឡើងពីថ្ងៃជ័យជម្នះ១៧ មេសា និងការចូលរួមតស៊ូប្រយុទ្ធរបស់កម្មាភិបាលយុទ្ធជន និងអញ្ជើញ លោក យឹម ឌិត ជាមេយុវជនសម័យសម័យសង្គមរាស្ត្រនិយមឡើងចាប់អារម្មណ៍។ នៅពេលយប់ អង្គការបានឲ្យក្រុមសិល្បៈដែលស្លៀកពាក់ខ្មៅ បង់កក្រមាសម្តែងពីជោគជ័យដែលកងទ័ពខ្មែរក្រហមទទួលជ័យជម្នះលើរបប លន់ នល់ ជូនប្រជាជនទស្សនា។ នៅពេលសម្តែង ក្រុមសិល្បៈបាន ប្រើពាក្យប្លែកៗដូចជា មូលដ្ឋាន សេដ្ឋកិច្ច ភូមិ-ឃុំ ខ្សែត្រៀម អង្គការ កម្មុច ដែលខ្ញុំមិនដែលធ្លាប់ដឹងនិងឮពីមុនមកសោះ។

រយៈពេលមួយសប្តាហ៍ក្រោយមក អង្គការបានចាត់តាំងឲ្យខ្ញុំទៅលើកទំនប់បឹងលាច នៅឃុំចំបក់ ស្រុកបាទី ដែលនៅទីនោះមានកម្លាំងយុវជន យុវនារីជាច្រើនធ្វើការជាមួយគ្នា។ ប្រធានកងដែលជាអ្នកមូលដ្ឋាន បានបែងចែកការងារឲ្យប្រជាជនក្នុងមួយភូមិត្រូវលើកទំនប់ប្រវែង៥០ម៉ែត្រឲ្យហើយក្នុងរយៈ ពេល២ថ្ងៃ ដោយមានកងឈ្លបឃុំដើរត្រួតពិនិត្យ និងស្តាប់ការជជែកគ្នារបស់

ប្រជាជន។ នៅការដ្ឋាន ប្រធានក្រុម ប្រធានកង តែងតែប្រជុំប្រាប់ប្រជាជនទាំងអស់ថា ត្រូវខិតខំធ្វើការងារ កុំមានសតិអារម្មណ៍ និងកុំនិយាយលេងសើចព្រោះអ្នកនៅទីនេះសុទ្ធតែជាឈ្លើយសឹក។ ខ្ញុំនិងបងប្អូន ដែលជាប្រជាជនថ្មី តែងតែត្រូវប្រជាជនមូលដ្ឋានដេប្រមាថ និងពោលពាក្យថា ខំធ្វើការទៅ ប្រយ័ត្នចូលវត្តកកោះ (មន្ទីរសន្តិសុខ ស្រុក៥៦ ស្ថិតនៅក្នុងឃុំត្រពាំងសាប) នៅពេលដែលយើងធ្វើការងារមិនត្រូវតាមចិត្តរបស់គេ។ ក្រោយពីឮការគំរាមចាប់ខ្លួននេះ ខ្ញុំនិងបងប្អូនមានការភិតភ័យយ៉ាងខ្លាំង ហើយខិតខំធ្វើការងារស្ទើរគ្មានពេលសម្រាក។

ថ្ងៃមួយ នៅពេលកំពុងលើកទំនប់ ខ្ញុំឃើញយុវជនចំនួន៧នាក់និងយុវនារីចំនួន៣នាក់ (ប្រជាជនថ្មី) មកពីភូមិកន្លែងខ្លះមកធ្វើការនៅការដ្ឋានលើកទំបន់ ហើយបានលួចស្រលាញ់គ្នានៅពេលយប់ ប៉ុន្តែអង្គការបានព្រមានព្រោះខុសសីលធម៌។ រយៈពេលមួយថ្ងៃក្រោយមក យុវជននិងយុវនារីទាំងនោះ ក៏បាត់ខ្លួនរហូត ហើយខ្ញុំតែងតែឮសំឡេងអ្នកទោសយំ និងថ្ងូរចេញពីមន្ទីរសន្តិសុខឃុំ (ស្ថិតនៅចម្ងាយប្រមាណជា២០០ម៉ែត្រពីកន្លែងខ្ញុំធ្វើការ) នៅពេលកងឈ្លបធ្វើទារុណកម្ម ហើយជារឿយៗខ្ញុំបានឃើញកងឈ្លបបណ្តើរអ្នកទោសចេញពីមន្ទីរឃុំឃាំងមកធ្វើការនៅខាងក្រៅ។ ថ្ងៃមួយ នៅមន្ទីរសន្តិសុខឃុំ មានសន្តិសុខម្នាក់បានលួចយកអង្រឹងកងសន្តិសុខគ្នាឯង ប៉ុន្តែក្រោយមកអង្គការដឹងក៏យកសន្តិសុខនោះទៅធ្វើទារុណកម្មរហូតស្លាប់ រួចហើយយកទៅចងព្យួរកនៅដើមឈើជិតកន្លែងឃុំឃាំង បន្ទាប់មករាយការណ៍ថាបុរសនោះចងកសម្លាប់ខ្លួនឯង។ ចំណែកមិត្តភក្តិនៅក្នុងកងរបស់ខ្ញុំម្នាក់ ក៏ត្រូវអង្គការចោទប្រកាន់ថា បានលួចយកនាឡិកាដៃមួយគ្រឿងដែរ ហើយត្រូវកងឈ្លបឃុំចាប់យកទៅឃុំឃាំងនិងធ្វើទារុណកម្មរយៈពេលមួយខែទើបដោះលែងវិញ ព្រោះតែរកមិនឃើញកំហុសរបស់គាត់។

នៅការដ្ឋាន ការងារមិនទាន់ហើយរួចរាល់នៅឡើយ ឃើញដូច្នេះ អង្គការបានប្រជុំណែនាំប្រាប់ដល់ប្រជាជនឲ្យខិតខំធ្វើឲ្យហើយមុនផែនការកំណត់ ដើម្បីបានស្រូវទុកហូបទាំងអស់គ្នាដែលខុសពី របប លន់ នល់ គឺមានអ្នកធ្វើ មានអ្នកចាំហូប។ នៅពេលខ្លះ អង្គការបានដាក់ការងារដែលខ្ញុំមិនចេះឲ្យធ្វើ ប៉ុន្តែខ្ញុំមិនដែលហ៊ានសាកសួរទេព្រោះខ្លាចអង្គការស្តីបន្ទោស ហើយខ្ញុំត្រូវរង់ចាំរហូតដល់ម៉ោងសម្រាកពីការងារទើបសួរអ្នកនៅក្នុងកងជាមួយ ដោយមិនហ៊ានឲ្យកងឈ្លបដឹងឡើយ ព្រោះខ្លាចគេរាយការណ៍ទៅថ្នាក់លើថាខ្ញុំមិនចេះធ្វើឲ្យរាំងស្ទះដល់ការងារអង្គការ។

បន្ទាប់ពីលើកទំនប់បឹងលាចចប់រួចរាល់ រយៈពេលមួយខែក្រោយមក អង្គការបានចាត់តាំង ការងារថ្មីឲ្យខ្ញុំទៅដឹកព្រែកនៅចឹកខ្ពស់ (ស្ថិតនៅជិតអំពែភ្នំ) ខេត្តកំពង់ស្ពឺ ខណៈពេលឪពុកខ្ញុំមានជំងឺហើមដៃ ហើមជើង ហើមមុខធ្ងន់ធ្ងរ ដោយសារពុំមានអាហារហូបគ្រប់គ្រាន់ និងគ្មានថ្នាំសម្រាប់ព្យាបាល។ ក្រោយមកដោយសារឃ្លានខ្លាំងពេក ឪពុកខ្ញុំបានប្រាប់ម្តាយ និងបងស្រីខ្ញុំថា គាត់ចង់ហូបថ្លើមជ្រូក ឮដូច្នេះម្តាយខ្ញុំបានខិតខំដើររកគ្រប់ផ្ទះរបស់ប្រជាជនក្នុងភូមិ ប៉ុន្តែមិនអាចរកបានព្រោះអង្គការមិនអនុញ្ញាតឲ្យធ្វើហូបឯកជនទេ។ ឃើញដូច្នេះ ខ្ញុំបានទៅសុំអង្វរប្រធានភូមិនៅធ្វើការក្នុងភូមិដើម្បីឆ្លៀតពេលថែឪពុកដែលឈឺកាន់តែធ្ងន់ធ្ងរ និងមិនសង្ឃឹមថាគាត់នៅរស់បានយូរទៀតទេ ប៉ុន្តែប្រធានភូមិបានបដិសេធ ហើយថែមទាំងបន្ទោសថានៅមើលធ្វើអី អ្នកឯងមិនមែនជាគ្រូពេទ្យទេ។ ខ្ញុំត្រូវទៅ ធ្វើការតាមការចាត់តាំងវិញ ហើយរៀងរាល់ថ្ងៃខ្ញុំត្រូវខិតខំធ្វើការងារដើម្បីកុំឲ្យប្រធានភូមិចាប់កំហុស។

ថ្ងៃមួយ នៅពេលកំពុងដឹកព្រែក អ្នកភូមិម្នាក់ដែលធ្វើការងារនៅក្នុងកងសេដ្ឋកិច្ច បានដឹកអង្ករពីភូមិត្រពាំងក្រសាំងយកមកឲ្យរោងបាយសហករណ៍ដែលខ្ញុំធ្វើការ ដោយបានមកប្រាប់ខ្ញុំថា ឪពុកខ្ញុំបានស្លាប់ និងរៀបចំធ្វើបុណ្យរួចរាល់ហើយ។ ខ្ញុំរន្ធត់ចិត្តខ្លាំងណាស់នៅពេលឮពាក្យនេះភ្លាម ព្រោះខ្ញុំមិនបានទទួលដំណឹងពីគាត់អស់រយៈពេលច្រើនថ្ងៃមកហើយ ខ្ញុំបានត្រឹមតែឈរសម្រក់ទឹកភ្នែកប៉ុណ្ណោះ ហើយខ្ញុំត្រូវរង់ចាំរហូតដោយត្រូវធ្វើការងារចប់តាមផែនការ ទើបអង្គការអនុញ្ញាតឲ្យត្រឡប់ទៅភូមិវិញ។

ខ្ញុំមកនៅផ្ទះបានជួបមុខម្តាយរយៈពេលតែបីថ្ងៃប៉ុណ្ណោះ ក៏ត្រូវមេភូមិចាត់តាំងឲ្យទៅកាប់គាស់ គល់ឈើនៅការដ្ឋានខាងត្បូងភ្នំតាម៉ៅដើម្បីរានដីដាំដំឡូង។ បន្ទាប់ពីកាប់ឆ្ការរួចរាល់ហើយ ប្រធានកងបានចាត់តាំងឲ្យខ្ញុំធ្វើជាអ្នកបរទេះដឹកទន្រ្ទានខែត្រជា

មួយនារីចំនួន៧នាក់ដែលជាអ្នកប្រមូល ។ ក្នុងមួយថ្ងៃ ខ្ញុំត្រូវរកឲ្យបានពីរដើង ប៉ុន្តែក្រោយមកដោយនៅភូមិផ្សេងៗអង្គការចាត់តាំងឲ្យដើរប្រមូលទន្រ្ទានខែត្រដែរ ទើបធ្វើឲ្យក្រុមខ្ញុំមានការលំបាកក្នុងការដើររក ហើយពេលខ្លះខ្ញុំត្រូវបរទេះដើរប្រមូលទន្រ្ទានខែត្ររហូតដល់អណ្តូងព្រីង(បច្ចុប្បន្ន ស្ទួនចិញ្ចឹមសត្វភ្នំតាម៉ៅ) ទៀតផង ។

នៅធ្វើការក្នុងកងបររទេះបានរយៈពេលមួយខែ ដោយសារឃើញខ្ញុំនៅលីវ ប្រធានភូមិក៏ចាត់តាំងឲ្យចូលកងចល័តយុវជនក្នុងឃុំចំបក់ ចំណែកអ្នកមានគ្រួសារអង្គការបានអនុញ្ញាតឲ្យធ្វើការនៅក្នុងភូមិក្រោមការគ្រប់គ្រងរបស់យុវជនមូលដ្ឋាន ។ ខ្ញុំត្រូវអង្គការចាត់តាំងឲ្យទៅលើកទំនប់ លើកភ្លឺស្រែនៅតាមឃុំនិងស្រុកផ្សេងៗ និងត្រូវស្នាក់នៅតាមកងរហូត ។ នៅរដូវវស្សា ខ្ញុំត្រូវភ្ញាក់ពីដេកនៅម៉ោង៥ព្រឹក ទៅដកសំណាបឲ្យបានមួយផ្លូន រួចហើយត្រូវដឹកជញ្ជូនយកកន្លែងស្ទូងដោយខ្លួនឯងទៀត ។ អង្គការបានកំណត់ឲ្យកងចល័តឈប់សម្រាកហូបបាយនៅម៉ោង១២ថ្ងៃត្រង់ ប៉ុន្តែពេលខ្លះខ្ញុំត្រូវរង់ចាំរហូតដល់ម៉ោង១ព្រោះម្ហូបមិនទាន់ឆ្អិន ។ ទោះបីជាឃ្លានយ៉ាងណាក៏ដោយ ក៏ខ្ញុំមិនដែលហ៊ានរអ៊ូរទាំដាក់ចុងភៅដែរ ព្រោះខ្លាចគេចោទប្រកាន់ខ្ញុំជាខ្មាំងរួចរាយការណ៍ទៅថ្នាក់លើ ។

នៅពេលយប់ ខ្ញុំមិនដែលបានចូលសម្រាកនៅក្បាលព្រលប់ទេ គឺបន្ទាប់ពីហូបបាយរួចអង្គការបានដាក់ភ្លើងអំពូលម៉ែត្របំភ្លឺហើយចាត់តាំងឲ្យទៅដកសំណាបបន្ថែមទៀត ដោយសារខ្លាចខ្វះនៅពេលស្ទូង ។ ទោះបីមានភ្លៀងរលឹម ឬខ្យល់រងាយ៉ាងណាក៏ដោយ ក៏ខ្ញុំត្រូវដកសំណាបឲ្យបានមួយផ្លូនដែរ ទើបទៅដេកនៅក្រោមផ្ទះប្រជាជន ឬក្រោមកុដិលោក និងសាលាសំណាក់ដែលស្ថិតនៅជិតកន្លែងធ្វើការ ។

ដើមឆ្នាំ១៩៧៦ ពេលក្រុមខ្ញុំសម្រាកពីស្ទូងស្រូវនៅពេលថ្ងៃត្រង់នៅភូមិសីហា ប្រធានសន្តិសុខឃុំចំបក់ បានបញ្ជាឲ្យបុរសម្នាក់នៅក្នុងកងភ្ជួរដោះយកគោទៅរាស់ដីវិញ ស្រាប់តែបុរសនោះប្រកែកថា គោខ្ញុំភ្ជួររយៈពេលពេញមួយព្រឹកមកហើយ វាមិនអាចអូសរនាស់បានទេ ។ គ្រាន់តែឮពាក្យតវ៉ានេះភ្លាម ប្រធានសន្តិសុខបានស្ទុះទៅកញ្ឆក់យកក្រមាពីលើក្បាលបុរសនោះមកចងដៃទាំងពីររបស់គាត់ទៅក្រោយ រួចយករំពាត់ផ្តៅវាយទៅលើក្បាលបុរសនោះយ៉ាងដំណំ ហើយស្រែកគំរាមថា "អ្ហែងប្រកែកនឹងអញ អ្ហែងខ្មាំងហ្ន" ។ បន្ទាប់មក ប្រធានសន្តិសុខ នោះបានឲ្យឈ្លបបណ្តើរបុរសនោះទៅមន្ទីរសន្តិសុខឃុំដែលមានចម្ងាយប្រមាណ១គីឡូម៉ែត្រពីកង ។

នៅពេលទៅដល់កន្លែងឃុំឃាំងឃុំចំបក់ អ្នកទោសនោះបានស្រាយចំណង រួចហើយដេញវាយឈ្លបក្មេងៗផ្អើលពេញមន្ទីរសន្តិសុខ ។ បន្ទាប់មក អ្នកទោសនោះបានរត់ឡើងលើដើមត្នោតដែលមានចម្ងាយពីរគីឡូម៉ែត្រពីមន្ទីរឃុំឃាំង ដោយមានកាន់កូនកាំបិតមួយដើម្បីអារកធ្វើអត្តឃាតខ្លួនឯង ។ ភ្លាមនោះដោយដឹងថាអ្នកទោសរត់រួច គណៈឃុំចំបក់បានមកដល់រួចហើយស្រែកប្រាប់អ្នកទោសនោះថា "ចុះមកដីមក អង្គការនឹងមិនយកទោសពៃរ៍ទេ" ។ ស្តាប់ឮការលួងលោមនេះ អ្នកទោសនោះក៏យល់ព្រមចុះមកក្រោមវិញ បន្ទាប់មកអង្គការក៏បញ្ជូនគាត់ទៅព្យាបាលនៅពេទ្យស្រុក៥៦ ប៉ុន្តែមួយរយៈក្រោយមក អង្គការក៏បញ្ជូនអ្នកទោសនោះទៅឃុំឃាំងនៅមន្ទីរវត្តកកោះវិញ ។

នៅពាក់កណ្តាលឆ្នាំ១៩៧៦ អង្គការចាប់ផ្តើមសង្ស័យលើកម្មាភិបាលគ្រប់ថ្នាក់ទាំងអស់នៅក្នុងតំបន់ ។ នៅពេលនោះគណៈតំបន់៣៣ គណៈស្រុក៥៦ និងគណៈឃុំជាច្រើនត្រូវចាប់ខ្លួន រួចហើយអង្គការបានបញ្ជូនកម្មាភិបាលថ្មីមកគ្រប់គ្រងជំនួសវិញ ។ ខណៈនោះអង្គការបានចាត់តាំងខ្ញុំឲ្យកាប់ដី ដំបូកយកមកលាយជាមួយស្លឹកសង្កែ និងដើមទន្រ្ទានខែត្រលាយធ្វើជីរហូតដល់រដូវស្រូវទុំ ទើបផ្លាស់ប្តូរខ្ញុំមកកងប្រូតវិញ ។ រៀងរាល់ថ្ងៃ កងរបស់ខ្ញុំត្រូវងើបឡើងពីព្រលឹមដើម្បីជញ្ជូនកណ្តាប់ទៅទុកនៅកន្លែងបោកបែន ព្រោះស្រូវក្នុងស្រែទុំកាន់តែច្រើនហើយ ហើយពេលយប់ត្រូវជួយបោកកណ្តាប់រហូតដល់ម៉ោង១១ - ១២យប់ទើបបានឈប់សម្រាក ។ នៅពេលប្រូតម្តងៗ មេក្រុមបានដើរកត់ចំនួនកណ្តាប់ដែលសមាជិកប្រូតបានដើម្បីរាយការណ៍ទៅថ្នាក់លើ ហើយប្រសិនបើនរណាប្រូតបានតិចជាងគេ អង្គការនឹងចោទថាខ្ជិលតែម្តង ។

បន្ទាប់ពីប្រមូលផលស្រូវចប់រួចរាល់ អង្គការបានដាក់ផែនការឲ្យខ្ញុំទៅជីកព្រែក លើកប្រឡាយបន្តទៀត ។ អង្គការបានអនុញ្ញាតឲ្យឈប់សម្រាកតែនៅពេលមានសន្និបាត ឬមានជំងឺធ្ងន់

ប៉ុណ្ណោះ ។ ប្រសិនបើសុំច្បាប់មកលេងឪពុកម្តាយ បងប្អូន អង្គការនឹងមិនអនុញ្ញាតទេដោយលើកហេតុផលថាមានការងារបន្ទាន់ ហើយត្រូវធ្វើឲ្យទាន់តាមផែនការ ។ ដូច្នេះនៅពេលនឹកផ្ទះម្តងសមាជិកនៅក្នុងកងរបស់ខ្ញុំទាំងអស់តែងលួចមកលេងផ្ទះនៅពេលយប់ដោយមិនឲ្យប្រធានដឹងឡើយ ព្រោះខ្លាចចោទថាជាខ្មាំង ។ ដោយការដ្ឋានរបស់ខ្ញុំធ្វើការនៅឆ្ងាយពីភូមិ និងផ្ទះប្រជាជន ដូច្នេះបន្ទាប់ពីធ្វើការងារហេវហត់អស់កម្លាំង នៅពេលយប់ ខ្ញុំត្រូវដើរកាប់ស្លឹកឈើ ឬយកកន្ទេលមកក្រាលដេកផ្ទាល់នឹងដីក្រោមដើមឈើតែម្តង ។ អង្គការមិនដែលចែករបបអាហារឲ្យហូបគ្រប់គ្រាន់ទេ ប៉ុន្តែក៏មិនមានអ្នកណាហ៊ានតវ៉ាដែរ ។

នៅខែមេសា ឆ្នាំ១៩៧៧ អង្គការតម្រូវឲ្យខ្ញុំ និងកងចល័តយុវជនទាំងអស់ទៅជីកព្រែកនៅឃុំដាន់សង្កែ ស្រុក៥១ (ស្រុកភ្នំស្រួច) ខេត្តកំពង់ស្ពឺ ដោយយកឡានមកទទួល ប៉ុន្តែកងចល័តទាំងអស់ត្រូវទៅស្នាក់នៅរង់ចាំនៅក្នុងឃុំកុមាររាជ (ស្ថិតនៅជាប់ផ្លូវជាតិលេខ៣) ។ នៅទីនោះ ដោយសារត្រូវរង់ចាំ យូរថ្ងៃ និងមិនទាន់មានការងារធ្វើ ទើបបន្ទាប់ពីហូបបាយពេលល្ងាចរួច យើងតែងតែនាំគ្នារាំច្រៀង ចម្រៀងបដិវត្តន៍ដោយមិនគិតពីការនឿយហត់និងការយកទោសម្លាប់ទេ ។

ខ្ញុំរង់ចាំរយៈពេលជិតកន្លះខែ ទើបឃើញឡានទ្រុងរបស់ចិនចំនួន៥គ្រឿងមកទទួលនៅពេលល្ងាច រហូតដល់យប់ជ្រៅយើងធ្វើដំណើតទៅដល់ពេជ្រនិល ហើយអ្នកបើកឡានបានបត់តាមផ្លូវលំទៅឈប់នៅក្នុងព្រៃក្បែរមាត់បឹង ដែលស្ថិតក្នុងភូមិកូនត្រាំក្នុងឃុំអូរ ។ មេកងបានប្រកាសឲ្យអ្នកជិះលើឡានទាំងអស់រកកន្លែងសម្រាករៀងខ្លួន ដើម្បីរង់ចាំដល់ថ្ងៃស្អែកទើបសង់រោងដេក ។ ព្រឹកឡើង អង្គការបានចាត់តាំងឲ្យកងចូលព្រៃកាប់ឈើ និងស្លឹកដើម្បីសង់រោងស្នាក់នៅ ។ ប៉ុន្តែ យើងមិនហ៊ានដេកផ្ទាល់នឹងដីដូចពេលមុនទេ ព្រោះខ្លាចពស់ចឹក និងសត្វក្អែបទិច ដូច្នេះក្រុមខ្ញុំខិតខំកាប់ឈើបន្ថែម សម្រាប់ធ្វើគ្រែ ។ នៅថ្ងៃបន្ទាប់ អង្គការក៏ចាត់តាំងកងយុវជនទាំងអស់ទៅការដ្ឋានទំបន់ព្រែកត្នោត ដែលមានទទឹងមាត់លើ១០ម៉ែត្រ ជម្រៅ៤ម៉ែត្រ ហើយត្រូវរែកដីមកចាក់លើមាត់ទំនប់ម្ខាងដើម្បីធ្វើផ្លូវដើរ ។ រៀងរាល់ថ្ងៃ ខ្ញុំត្រូវចំណាយពេលពីរម៉ោងដើរទៅការដ្ឋានដែលមានចម្ងាយផ្លូវត្រឹម៦គីឡូម៉ែត្រ ព្រោះនៅតាមផ្លូវធ្វើដំណើរមានវល្លិ៍ឈើ និងមានពស់ច្រើន ហើយពេលខ្លះបានចឹកកងចល័តយុវជនទៀតផង ។ នៅការដ្ឋានខ្ញុំតែងតែឮអ្នកនៅក្នុងកងជាមួយគ្នានិយាយថា នៅពេលយប់មានខ្លាហក់ចូលមកកន្លែងដេក ប៉ុន្តែក្រោយមកទើបខ្ញុំដឹងថា ខ្លានោះមិនមែនជាសត្វខ្លាពិតប្រាកដទេ គឺកងឈ្លបចូលមកចាប់អ្នកទោសដែលអង្គការចោទប្រកាន់ថាក្បត់បដិវត្តន៍ ។ ការងារជីកព្រែកកាន់តែសម្រុកខ្លាំងព្រោះជិតដល់រដូវភ្លៀងធ្លាក់ ដូច្នេះនៅវេលាម៉ោង៣ទៀបភ្លឺ មេកងបានផ្លុំកញ្ចែដើម្បីដាស់កងយុវជនឲ្យចេញទៅការដ្ឋាន ហើយពេលខ្លះដោយងងុយដេកខ្លាំងពេកខ្ញុំក្រោកដើរទាំងបិទភ្នែក ។ នៅពេលកាប់ម្តងៗ យើងអាចកាប់ដីនឹងចបបានជម្រៅត្រឹមតែ៣តឹកប៉ុណ្ណោះ ព្រោះនៅខាងក្រោមសុទ្ធតែផ្សាំងផ្ទ ដូច្នេះយើងត្រូវយកដែកត្រសេះ និងដែកគ្បៀងដើម្បីគាស់បំបែក ។ ទោះបីការងារលំបាកខ្លាំងយ៉ាងណាក៏ដោយ ក៏ប្រធានកងបានកំណត់ឲ្យគ្រប់កងទាំងអស់ធ្វើឲ្យហើយទាន់ផែនការ ហើយពេលប្រជុំម្តងៗ អង្គការបានប្រកាសថា បើជីកប៉ះភ្នំត្រូវរំលាយភ្នំ បើចំដើមឈើត្រូវរំលំដើមឈើ ។ ចំណែករបបអាហារបានត្រឹមតែបាយមួយស្លាក់ម្នាក់ និងសម្លមួយគោមប៉ុណ្ណោះសម្រាប់មនុស្ស៤នាក់ ។ នៅពេលសម្រាកពេលថ្ងៃត្រង់ម្តងៗ ខ្ញុំមិនដែលហ៊ានដេកទេព្រោះខ្លាចមូសខាំបណ្តាលឲ្យមានជំងឺគ្រុន ហើយខ្ញុំឆ្លៀតពេលចូលព្រៃគាស់


សេក សុខា បង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

ដើមឈើ និងឫសឈើសម្រាប់ផ្សំធ្វើថ្នាំដីកព្យាបាលខ្លួន ។

រយៈពេលមួយខែក្រោយមក ដោយសារមានភ្លៀងធ្លាក់ច្រើនបណ្ដាលឲ្យលិចការដ្ឋានទំនប់ព្រែកត្នោត ទើបអង្គការសម្រេចដកកងចល័តទាំងអស់មកមូលដ្ឋានភូមិត្រពាំងក្រសាំងវិញ ។ នៅក្នុងភូមិ ខ្ញុំមិនអាចចេញទៅធ្វើការបានទៀតទេ ព្រោះខ្ញុំចាប់ផ្ដើមមានជំងឺគ្រុនចាញ់បណ្ដាលឲ្យរាករូសយ៉ាងខ្លាំង ។ សភាពជំងឺរបស់ខ្ញុំកាន់តែធ្ងន់ ឃើញដូច្នេះម្ដាយរបស់ខ្ញុំក៏សុំអនុញ្ញាតពីអង្គការបញ្ជូនខ្ញុំទៅព្យាបាលនៅមន្ទីរពេទ្យអស់រយៈពេល១៥ថ្ងៃ ទើបអង្គការចាត់តាំងខ្ញុំ និងយុវជនម្នាក់ទៀតឲ្យចូលកង ធ្វើជី និងធាក់រហាត់ទឹកដាក់ស្រូវប្រាំងដែលស្ថិតនៅក្នុងភូមិបឹងលាច ។ ដោយសារនៅទីនោះ ជាទីវាល ខ្ញុំបានដើររកឈើដើម្បីធ្វើរោងស្នាក់នៅ ហើយត្រូវភ្ញាក់ពីយប់ដើម្បីធាក់រហាត់ទៀត ព្រោះខ្លាចពុំមានទឹកគ្រប់គ្រាន់សម្រាប់សន្ទូង ។ ជារឿយៗ ខ្ញុំតែងតែឃើញកងឈ្លបបណ្ដើរអ្នកទោសដោយចងភ្ជាប់ ជាមួយនឹងធាងត្នោតរួចឲ្យអ្នកទោសទាំងនោះរត់ពីមុខកង់របស់គេ និងមានអ្នកទោសខ្លះត្រូវកងសន្តិសុខចាប់ចងស្លាបសេកលើកដាក់គរគ្នាលើរទេះសេះយកទៅឃុំនៅមន្ទីរសន្តិសុខវត្តកកោះ ស្រុក៥៦ ។

នៅឆ្នាំ១៩៧៨ អង្គការបានសង់រោងឲ្យកងចល័តទាំងអស់ស្នាក់នៅដែលស្ថិតនៅក្នុងភូមិត្រពាំងលាន ឃុំចំបក់ និងបានប្រកាសប្រាប់ប្រជាជនទាំងអស់ថា ចាប់ពីថ្ងៃនេះទៅអង្គការឈប់បែងចែករវាងប្រជាជនចាស់ និងប្រជាជនថ្មីទៀតហើយ គឺយើងជាខ្មែរ ត្រូវរួបរួម ប្រមូលកម្លាំងវាយយួនដណ្ដើមយកទឹកដីកម្ពុជាក្រោមវិញ ។ ខណៈនោះ អង្គការក៏ចាប់ផ្ដើមប្រកាសជ្រើសរើសយុវជនឲ្យចូលបម្រើទ័ព ដោយស្ដាប់ពុការឃោសនានេះភ្លាម យុវជនចំនួនប្រមាណ១០នាក់នៅកងជាមួយខ្ញុំ បានលើកដៃស្ម័គ្រចិត្ត ។ ចំណែកយុវជន-យុវនារីដែលមិនបានចូលទ័ព អង្គការបានរៀបចំជ្រើសរើសគូស្រករដែលខ្លួនស្រលាញ់ពេញចិត្តឲ្យបានគ្នាជាប្ដីប្រពន្ធដោយរៀបការម្ដង២០គូ ។ ពេលនោះ ដោយសារខ្ញុំគ្រប់អាយុរៀបការហើយ ម្យ៉ាងទៀតមិត្តភក្តិខ្ញុំជាច្រើនបានរៀបចំគូអស់ហើយ ទើបនៅខែតុលា ឆ្នាំ១៩៧៨ ខ្ញុំក៏សម្រេចចិត្តរៀបការជាមួយប្រពន្ធដែលនៅក្នុងឃុំស្រុកជាមួយខ្ញុំដែរ ។

បន្ទាប់ពីរៀបការហើយ ខ្ញុំបានទៅរស់នៅផ្ទះខាងប្រពន្ធដែលស្ថិតនៅភូមិវាលប្រីយ៍ខ្ទី ឃុំចំបក់ ។ នៅចុងឆ្នាំ១៩៧៨ កងទ័ពវៀតណាមបានវាយចូលកាន់កាប់ផ្សារចំបក់ និងសាលាស្រុកបាទីបាន ប៉ុន្តែស្រាប់តែមួយខែក្រោយមកកងទ័ពទាំងនោះបានដកទ័ពត្រឡប់ទៅវិញ ។ ខណៈនោះ មេភូមិ មេឃុំ និងកងឈ្លបខ្មែរក្រហមបានត្រឡប់ចូលភូមិវិញដែរដោយកាន់កាំបិតដាវ និងដែកគោលរទេះមកចាប់អ្នកដែលរើយកអង្ករ និងអំបិលរបស់អង្គការ បន្ទាប់មកឈ្លបបានយកអ្នកទោសទៅអារកនៅចំពោះមុខប្រជាជនក្នុងភូមិដែលធ្វើឲ្យខ្ញុំភិតភ័យយ៉ាងខ្លាំង ។ រយៈពេលមួយសប្ដាហ៍ក្រោយមក ទើបកងឈ្លប និងកម្មាភិបាលរបស់ខ្មែរក្រហមរត់គេចខ្លួនអស់ នៅពេលដែលកងទ័ពរណសិរ្សចូលមកម្ដងទៀត និងបានរៀបចំរដ្ឋអំណាចភូមិឃុំជាថ្មីឡើងវិញ ។

នៅឆ្នាំ១៩៧៩ ដោយសារនៅក្នុងភូមិមិនមានគ្រូបង្រៀនគ្រប់គ្រាន់ ទើបខ្ញុំសម្រេចចិត្តចូលបង្រៀនមួយរយៈ ហើយក្រោយមកបានទៅក្លាយជានាយកសាលានៅបឋមសិក្សាអង្គរុន ។ ចាប់ពីឆ្នាំ ១៩៨១ ដល់ឆ្នាំ២០០១ ខ្ញុំរៀនបន្តជាគ្រូមធ្យមសិក្សាបឋមភូមិ និងគ្រូមធ្យមសិក្សាទុតិយភូមិ បង្រៀននៅវិទ្យាល័យប៊ុនរ៉ានី ហ៊ុន សែន បាទី ។ ពីឆ្នាំ២០០១ ដល់ឆ្នាំ២០០៣ ខ្ញុំធ្វើជាអធិការមធ្យមសិក្សានៅមន្ទីរអប់រំយុវជន និងកីឡាខេត្តតាកែវ ។ ពីឆ្នាំ២០០៣ ដល់ឆ្នាំ២០០៥ ខ្ញុំធ្វើជានាយកវិទ្យាល័យទន្លេបាទី បន្ទាប់មកផ្លាស់មកធ្វើជាអធិការមធ្យមសិក្សាចំណេះទូទៅនៅក្រសួងអប់រំយុវជននិងកីឡានៅភ្នំពេញ ។ នៅឆ្នាំ២០០៩ ក្រសួងអប់រំក៏បានជ្រើសរើសរើសខ្ញុំឲ្យធ្វើជាគ្រូបង្រៀនថ្នាក់ជាតិ បង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

បច្ចុប្បន្ន ទោះបីរបបខ្មែរក្រហមដួលរលំអស់រយៈពេលជាង៣០ហើយក៏ដោយ ក៏ខ្ញុំនៅតែនឹកឃើញនូវទុក្ខវេទនា ការឈឺចាប់ដែលខ្ញុំបានជួបប្រទះដែរ ។ ដូច្នេះក្នុងតួនាទីជាគ្រូបង្រៀនប្រវត្តិសាស្ត្រកម្ពុជា ប្រជាធិបតេយ្យទៅគ្រូបង្រៀននិងសិក្ខាកាមខ្ញុំតែងតែពន្យល់ទៅសិស្ស ដោយផ្ដោតសំខាន់ទៅលើគោលជំហរបង្រួបបង្រួមជាតិ លុបបំបាត់ភាពរើសអើង ការលើកកម្ពស់យុត្តិធម៌ក្នុងសង្គមដើម្បីទប់ស្កាត់កុំឲ្យរបបខ្មែរក្រហមកើតឡើងម្ដងទៀត និងបង្កើតប្រព័ន្ធសិក្សាពីរបបនេះឲ្យមានលក្ខណៈទូលំទូលាយជាងមុន ។ **សោម ប៊ុនថន**

# តើមានអ្វីកើតឡើងបន្ទាប់?

ពាក្យថា "ខ្មែរក្រហម" អាចបង្ហាញនូវរូបភាពនៃអំពើព្រៃផ្សៃភាពភ័យខ្លាច និងសោកនាដកម្ម ។ ដោយនិយាយពីហូឡូខសត៍ ការសម្លាប់មនុស្សរង្គាលនៅទ្វីបអឺរ៉ុបនៅសម័យសង្គ្រាមលោកលើកទីពីរ) បដិវត្តន៍វប្បធម៌របស់ ម៉ៅ សេទុង និងអំពើប្រល័យពូជសាសន៍នៅរ៉ាន់ដា ខ្មែរក្រហមដែលបានគ្រប់គ្រងកម្ពុជាចាប់តាំងពីឆ្នាំ១៩៧៥-១៩៧៩ គឺជារបបមួយដែលមានការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរបំផុត ។ ពេលសិក្សាផ្នែកវិទ្យាសាស្ត្រនយោបាយនៅឯសកលវិទ្យាល័យស្តេនហ្វត ខ្ញុំធ្លាប់បានដឹងពីប្រវត្តិនៃអំពើប្រល័យពូជសាសន៍បែបនេះ និងដឹងពីរបៀបដែលវាកើតមានឡើងនៅក្នុងរយៈកាលដ៏ខ្មៅងងឹតរបស់ប្រទេសនោះ ។

ប៉ុន្តែ តើនឹងមានអ្វីកើតឡើងបន្ទាប់? តើប្រទេសទាំងនោះអភិវឌ្ឍន៍ចេញពីអតីតកាលដ៏អាក្រក់នោះដោយរបៀបណា?

នៅរដូវក្តៅកន្លងទៅនេះ ខ្ញុំបានសិក្សាទៅលើថាតើប្រទេសកម្ពុជាបានសម្រេចចិត្តដោះស្រាយអតីតកាលរបស់ខ្លួនតាមរយៈប្រព័ន្ធយុត្តិធម៌មួយយ៉ាងដូចម្តេច?

ខណៈពេលធ្វើការស្រាវជ្រាវសម្រាប់សារណា ខ្ញុំបានចូលរួមក្នុងសវនាការកាត់សេចក្តី កាំងហ្កេកអ៊ាវ ហៅ ឌុច ដែលជាអតីតប្រធានមន្ទីរស-២១ ឬគុកទួលស្លែងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ក្រោមការគ្រប់គ្រងរបស់ ឌុច ប្រជាជនប្រមាណ១៧,០០០នាក់ បានស្លាប់នៅទីនោះ ។ អ្នកទោសរួមមានអតីតមន្ត្រីនៅក្នុងរបប លន់ នល់ បញ្ញវន្ត និងកម្មាភិបាលខ្មែរក្រហមមួយចំនួន ។ ដោយសារតែខ្លាច និងបារម្ភពីការគំរាមកំហែងផ្នែកនយោបាយ និងសង្គមប្រឆាំងនឹងរបបថ្មីនេះ ខ្មែរក្រហមបានបញ្ជូនអ្នកទោសទាំងនោះទៅកាន់មន្ទីរស-២១ ដោយចោទប្រកាន់ថាជាឈ្លបយកការណ៍ និងអ្នកក្បត់នឹងបដិវត្តន៍ ព្រមទាំងធ្វើទារុណកម្ម និងសម្លាប់អ្នកទាំងនោះដើម្បីចម្រាញយកចម្លើយសារភាព និងធ្វើទារុណកម្ម ។ មានអ្នកទោសមួយចំនួននៅរស់រានមានជីវិត ក៏ប៉ុន្តែជាទូទៅអ្នកដែលត្រូវបញ្ជូន



អ្នកភូមិស្តាប់ការរៀបរាប់អំពីករណី០០២ បកស្រាយដោយលោក វ៉ាន់ថាន់ ពៅដារ៉ា

ទោស-២១មិនមានវាសនានៅរស់ជីវិតទេ។

ការស្លាប់ចំនួន១៧,០០០នាក់ គឺគ្រាន់តែជាចំនួនតិចតួច ប៉ុណ្ណោះ បើគិតពីចំនួនមនុស្សស្លាប់ទាំងអស់ ដែលបង្កឡើងដោយរបបខ្មែរក្រហមដែលមានចំនួនជាង១,៧លាននាក់។ នៅពេលដែលជនកុម្មុយនីស្តជ្រុលនិយមបានឡើងកាន់អំណាចនៅប្រទេសកម្ពុជានៅខែមេសា ឆ្នាំ១៩៧៥ ហើយបានកែប្រែឈ្មោះប្រទេសទៅជាកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានចាប់ផ្តើមបង្កើតរបបដ៏គួរឲ្យភ័យខ្លាចមួយដែលបង្ខំឲ្យប្រជាជនធ្វើការ១៧ម៉ោងក្នុងមួយថ្ងៃ បង្អត់អាហារ អនុវត្តន៍យុទ្ធនាការប្រឆាំងនឹងសត្រូវនយោបាយ ធ្វើឲ្យមានការបាត់ខ្លួន និងមានសម្លាប់មនុស្សយ៉ាងសាហាវព្រៃផ្សៃជាច្រើន។ ឈ្មោះ ប៉ុល ពត ដែលកើតចេញពី សាឡុត ស នៅតែមានដក់ជាប់ក្នុងការសន្ទនារបស់ប្រជាជនទូទៅ។

អ្វីដែលអាក្រក់ជាងនេះទៅទៀតគឺអតីតមេដឹកនាំខ្មែរក្រហមភាគច្រើនបានរស់នៅដោយនិទ្ទណ្ឌភាពចាប់តាំងពីការដួលរលំនៃរបបនេះនៅក្នុងឆ្នាំ១៩៧៩។ ដើម្បីទាមទារយុត្តិធម៌ អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាបានឯកភាពគ្នាក្នុងការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម នៅឆ្នាំ២០០៣។ បន្ទាប់ពីមានការចរចាបន្ថែមរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងទទួលបានប្រាក់ឧបត្ថម្ភដោយប្រទេសផ្តល់ជំនួយអន្តរជាតិ តុលាការនេះ បានចាប់ផ្តើមដំណើរការរបស់ខ្លួនចាប់ពីខែកក្កដា ឆ្នាំ២០០៦មក។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺជាតុលាការកូនកាត់មានន័យថាតុលាការនេះអនុវត្តទាំងច្បាប់ព្រហ្មទណ្ឌជាតិ និងអន្តរជាតិ ព្រមទាំងមានចៅក្រម ព្រះរាជអាជ្ញា និងបុគ្គលិករដ្ឋបាលជាតិ និងអន្តរជាតិ។ តុលាការកូនកាត់ ធ្លាប់មាននៅក្នុងកូសូវ៉ូ ប្រទេសទីម័រខាងកើត និងប្រទេសសេរ៉ាឡេអូន។ រចនាសម្ព័ន្ធរបស់តុលាការកូនកាត់នេះផ្តល់ឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានូវភាពស្របច្បាប់មួយដែលបានមកពីការបញ្ចូលគ្នានូវបទដ្ឋានយុត្តិធម៌អន្តរជាតិ។ ដោយអង្គជំនុំជម្រះមានទីតាំងស្ថិតនៅក្រៅទីក្រុងភ្នំពេញដែលផ្តល់ភាពងាយស្រួលដល់ដល់ប្រជាជនមួយភាគធំ។

គោលបំណងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះគឺដើម្បីស៊ើបអង្កេតឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅអំឡុងរបបខ្មែរក្រហម។ “ឧក្រិដ្ឋកម្មដ៏ឃោរឃៅដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានដូចជា អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ



លោក វីល្លៀម ស្មីត ផ្តល់ការបង្ហាញដល់អ្នកភូមិអំពីដំណើរការសាលាក្តី


អ្នកភូមិកំពុងមើលប្រវត្តិរូបរបស់មេដឹកនាំខ្មែរក្រហម

និងឧក្រិដ្ឋកម្មសង្គ្រាមជាក់លាក់មួយចំនួន ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក៏មានអំណាចក្នុងការកាត់សេចក្តីលើឧក្រិដ្ឋកម្មមួយចំនួនដែលស្ថិតក្រោមច្បាប់កម្ពុជាផងដែរ” ច្បាប់នេះផ្តោតសំខាន់លើការចោទប្រកាន់អតីតមេដឹកនាំខ្មែរក្រហម ។ សព្វថ្ងៃនេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចោទប្រកាន់អតីតមន្ត្រីខ្មែរក្រហមចំនួន៤នាក់ដូចជាៈ

*នួន ជា អតីតប្រធានសភាតំណាងប្រជាជនកម្ពុជានៃរបបកម្ពុជាប្រជាធិបតេយ្យហើយជាបងធំទីពីរ បន្ទាប់ពី ប៉ុល ពត ។*

*អៀង សារី អតីតឧបនាយករដ្ឋមន្ត្រីនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយជាបងធំទី បីបន្ទាប់ពី ប៉ុល ពត ។*

*អៀង ធីរិទ្ធ ជាប្រពន្ធរបស់ អៀង សារី ហើយជាអតីតរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចរបស់របបកម្ពុជាប្រជាធិបតេយ្យ ។*

*ខៀវ សំផន អតីតប្រមុខរដ្ឋរបស់របបកម្ពុជាប្រជាធិបតេយ្យ និងជាបងធំទី៥បន្ទាប់ពី ប៉ុល ពត ។*

ខណៈពេលជនទាំង៤នាក់នេះមិនទាន់កាត់ទោស អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានកាត់ទោសដោយធ្វើការចោទប្រកាន់ ឌុច អតីតប្រធានមន្ទីរឃុំឃាំងស-២១ ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មដទៃទៀត ។ សវនាការកាត់ទោស ឌុច រយៈពេល៩ខែដែលបានចាប់ផ្តើមតាំងពីខែកុម្ភៈរហូតដល់ទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ ទើបធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ ។

អំឡុងពេលពីរខែស្នាក់នៅប្រទេសកម្ពុជា ខ្ញុំបានចូលរួមសវនាការកាត់ក្តី ឌុច ពីរដង ។ ជញ្ជាំងកញ្ចក់ការពារគ្រាប់កាំភ្លើងបានបែងចែកបន្ទប់សវនាការដែល ឌុច អង្គុយ និងបន្ទប់ទល់មុខនឹងបន្ទប់សវនាការដែលខ្ញុំអង្គុយជាមួយនិងអ្នកចូលរួមសវនាការដទៃទៀត ។ បន្ទប់សម្រាប់ទស្សនិកជននេះមានអ្នកចូលរួមមកពីទីកន្លែងខុសៗគ្នារួមមានអ្នកទេសចរ អ្នកសារព័ត៌មាន សិស្ស និស្សិត និងប្រជាជនខ្មែរនៅតាមជនបទដែលត្រូវជិះរថយន្តក្រុងដើម្បីធ្វើដំណើរមកកាន់សាលាក្តីខ្មែរក្រហមដែរ ។ បន្ទប់សវនាការរួមមានចៅក្រម ចុងចោទ ព្រះរាជអាជ្ញា និងអ្នកបកប្រែភាសាដែលត្រូវបកប្រែភាសាដំណើរការនីតិវិធីទៅជាភាសាខ្មែរ អង់គ្លេស និងបារាំង (ភាសាបីនេះជាភាសាផ្លូវការរបស់សាលាក្តីខ្មែរក្រហម) ។ ជាចុងក្រោយ ផ្នែកមួយទៀតរបស់បន្ទប់សវនាការគឺសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ដែលមានប្រជាជនកម្ពុជាដែលធ្លាប់ជាជនរងគ្រោះ ឬក៏មានសមាជិកក្រុម គ្រួសារអ្នកទោសនៅមន្ទីរស-២១ បានដាក់ពាក្យបណ្តឹងប្រឆាំងនឹង ឌុច ។ ដើមបណ្តឹងរដ្ឋប្បវេណី មួយចំនួនបានចូលរួមរាល់សវនាការ-ចាប់តាំងពីការចាប់ផ្តើមសវនាការ ឌុច ដំបូង ។

ឌុច មិនដូចនឹងអ្វីដែលខ្ញុំបានរំពឹងទុកនោះទេ ។ គាត់មានរូបរាងមាឌតូច និងមិនក្រអឺតក្រទម ។ គាត់មើលទៅដូចជាឪពុករបស់ខ្ញុំច្រើនជាងអ្វីដែលខ្ញុំគិតថាគាត់គឺជាអតីតមេដឹកនាំមន្ទីរឃុំឃាំងមួយនៅក្នុងរបបខ្មែរក្រហម ។ នៅថ្ងៃដំបូងរបស់ខ្ញុំដែលចូលរួមសវនាការ ឌុច គាត់ឆ្លើយសំនួររបស់ចៅក្រមទាក់ទងនឹងមន្ទីរសន្តិសុខស-២៤ ដែលជា “មន្ទីរអប់រំ” ប៉ុន្តែការពិតជាជំរំពលកម្មដែលគាត់គ្រប់គ្រងបន្ថែមលើមន្ទីរស-២១ទៀត ។ ឌុច បានឆ្លើយនឹងសំណួររបស់ចៅក្រមយ៉ាងច្បាស់លាស់ និងល្អិតល្អន់ដែលស័ក្តិសមនឹងជីវប្រវត្តិរបស់គាត់ជាគ្រូគណិតវិទ្យា រួមទាំងវិធីសាស្ត្រដែលធ្វើឲ្យគាត់អាចមានតំណែងខ្ពស់នៅក្នុងជួរមេដឹកនាំខ្មែរក្រហម និងរក្សាអំណាចគ្រប់គ្រងមន្ទីរស-២១បាន ។ នៅថ្ងៃបន្ទាប់ អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មរបស់អតីតបុគ្គលិកមន្ទីរស-២១ ដូចជា ហ៊ឹម ហ៊ុយ ដែលជាអតីតសន្តិសុខម្នាក់នៅមន្ទីរស-២១ ដែលមានតួនាទីនាំអ្នកទោសមកកាន់មន្ទីរឃុំឃាំង ។ សក្ខីកម្មដែលបានមកពីអ្នកដែលធ្លាប់បម្រើការនៅឯមន្ទីរឃុំឃាំងស-២១នេះ បានបង្ហាញពីប្រតិបត្តិការរបស់មន្ទីរស-២១ ដែលមានលក្ខណៈជាប្រព័ន្ធ និងជាឋានានុក្រម ។

ព្រឹត្តិការណ៍របស់អង្គជំនុំជម្រះដែលធ្វើឲ្យខ្ញុំមានការចងចាំបំផុតនោះគឺស្តាប់សក្ខីកម្មរបស់ នង ចាន់ផល ជាអ្នករស់រានមានជីវិតពីមន្ទីរស-២១ដែរ ។ នៅក្នុងឆ្នាំ១៩៧៨ ក្មេងប្រុសអាយុ៨ឆ្នាំ នង ចាន់ផល ត្រូវបានអង្គការចាប់មកកាន់មន្ទីរ ស-២១ ជាមួយម្តាយ និងប្អូនប្រុសអាយុ៤ឆ្នាំ ។ គាត់គ្រាន់តែជាក្មេងប្រុសម្នាក់ នៅពេលនោះ ក៏ប៉ុន្តែគាត់ចងចាំថា ខ្មែរក្រហមបានវាយធ្វើបាបម្តាយរបស់គាត់នៅពេលដែលគាត់បានមកដល់មន្ទីរស-២១ ហើយបន្ទាប់មក គាត់ក៏ត្រូវបំបែកចេញពីម្តាយរបស់គាត់ ។ រយៈពេលមួយទៅពីរសប្តាហ៍នៅមន្ទីរស-២១ នង ចាន់ផល បាន

ស្លាក់នៅបន្ទប់ខាងក្រោយរហូតដល់កងទ័ពវៀតណាមដែលបានផ្ដួលរលំរបបខ្មែរក្រហមបានមកដល់មន្ទីរស-២១ នៅឆ្នាំ១៩៧៩ ។ នៅក្នុងបន្ទប់សវនាការ សំឡេងរបស់ នង ចាន់ផល មានភាពញ័រៗ នៅពេលដែលគាត់ព្យាយាមរំឭករឿងរ៉ាវដែលគាត់បានរកឃើញម្ដាយរបស់គាត់នៅក្នុងបន្ទប់មួយមុនពេលកងទ័ពវៀតណាមមកដល់ ។ គាត់បាននិយាយថា នៅពេលនោះគាត់ចង់ស្នាក់នៅមន្ទីរស-២១បន្តទៀតដើម្បីឲ្យម្ដាយរបស់គាត់អាចរកគាត់ឃើញ ។ បន្ទាប់មកសំឡេងរបស់គាត់ខ្សោយទៅៗ ហើយនៅស្ងៀមស្ងាត់នៅក្នុងបន្ទប់សវនាការ ហាក់បីដូចជាបង្ហាញថា សម្ដីរបស់គាត់បានរំលឹកនូវអតីតកាលដ៏ជូរចត់ និងគ្មានសង្ឃឹម ។ ទោះបីជារយៈពេល៣០ឆ្នាំកន្លងផុតទៅក៏ដោយ ក៏ប៉ុន្តែអតីតកាលនិងបទពិសោធនៅមន្ទីរស-២១ នៅតែជាស្រមោលអន្ទោលតាមគាត់រហូត ។ នៅអំឡុងពេលផ្ដល់សក្ខីកម្មរបស់ ចាន់ផល ឌុច មានពិបាកនឹងមើលមុខសាក្សី ហើយ ឌុច ក៏បានបង្ហាញទឹកមុខមាំដងដែរ ។ នេះប្រហែលមកពី ឌុច មានអារម្មណ៍ថាខ្លួនមិនមានការជាប់ពាក់ពន្ធ័ ។ ទោះបីជាយ៉ាងណាក៏ដោយក៏ ឌុច បានបង្ហាញនូវការសោកស្ដាយចំពោះអ្នកទោសដែលបានស្លាប់នៅមន្ទីរស-២១ដែរ និងទទួលខុសត្រូវចំពោះអ្នកដែល បានស្លាប់ក្នុងឋានៈរបស់គាត់ជាប្រធានមន្ទីរសន្តិសុខនេះ ប៉ុន្តែគាត់នៅតែនិយាយដដែលៗថា គាត់មិនបានបញ្ជាឲ្យមានការសម្លាប់មនុស្ស និងធ្វើទារុណកម្មចំពោះបុគ្គលណាម្នាក់ឡើយ ។ បន្ថែមលើសពីនេះទៅទៀត ឌុច បានសួរសំណួរទាក់ទងនឹងវត្តមានរបស់ នង ចាន់ផល និងការរស់រានមានជីវិតរបស់គាត់នៅមន្ទីរស-២១ ដោយនិយាយថា គ្រប់អ្នកទោសកុមារទាំងអស់បានស្លាប់អស់ហើយ ។

ដោយស្ដាប់ពីសក្ខីកម្មខុសៗគ្នា ខ្ញុំយល់ឃើញថាយុត្តិធម៌មិនទាន់បានរកឃើញនៅឡើយទេ ។ នៅពេលនោះ មានកម្មាភិបាលខ្មែរក្រហមជាច្រើនបានលាក់ខ្លួននិងធ្វើសកម្មភាពប្រឆាំងនឹងកងកម្លាំង ឈ្លានពានរបស់វៀតណាម ដើម្បីរក្សាសន្តិភាព និងស្វែងរកយុត្តិធម៌សម្រាប់ប្រជាជនកម្ពុជា ។ ថ្ងៃនេះដើម្បីកាត់ទោស អតីតកម្មាភិបាលខ្មែរក្រហមមិនថាជាសាក្សីឬក៏ជាដើមបណ្ដឹងរដ្ឋប្បវេណីឡើយគឺសុទ្ធតែមានឥទ្ធិពលទៅលើពាក្យបច្ចេកទេសច្បាប់ ។ ខណៈពេលដែលការវែកញែកអំពីខ្មែរក្រហមបានចាប់ផ្ដើមតាំងពីប៉ុន្មានទសវត្សរ៍មកហើយ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានផ្ដល់ការពិភាក្សាជាផ្លូវការមួយ ដើម្បីស្វែងរកការនិយាយ ការកត់ត្រាទុកការសន្ទនា និងការដកស្រង់យកការពិត ។ អាស្រ័យហេតុនេះ បន្ទាប់ពីការដួលរលំរបបខ្មែរក្រហម យុត្តិធម៌ត្រូវតែកើតមាន ។ ជាការពិតណាស់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនមែនល្អទាំងស្រុងនោះទេ ។ ការចោទប្រកាន់ទាក់ទងនឹងអំពើពុករលួយ និងភាពលម្អៀងបានគំរាមកំហែងដល់ភាពស្របច្បាប់ និងប្រសិទ្ធភាពរបស់តុលាការនេះដែលអាចបណ្ដាលឲ្យមានការប្រឈមនិងការបញ្ឈប់ភារកិច្ចរបស់ខ្លួន ។ អ្វីផ្សេងទៀតដែលត្រូវដោះស្រាយគឺកេរដំណែលរបស់របបខ្មែរក្រហម និងសេចក្ដីត្រូវការបច្ចុប្បន្នភាពរបស់ជនរងគ្រោះ ដូចជាភាពក្រីក្រ និងសុខភាពផ្លូវចិត្តជាដើម ។ ទោះបីជាយ៉ាងណាក៏ដោយ ដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីស្វែងរកយុត្តិធម៌បានធ្វើឲ្យជនរងគ្រោះមានភាពអស់ចិត្ត ដោយការដាក់ទោសអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងរបបខ្មែរក្រហមដោយបានបង្ហាញពីជំហានមួយឆ្ពោះទៅកាន់យុត្តិធម៌ និងការផ្សះផ្សានៅក្នុងប្រទេសកម្ពុជា ។

ជាមួយនឹងការបញ្ចប់សវនាការប្រឆាំងនឹង ឌុច អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចាប់ផ្ដើមសំណុំរឿង០០២ ប្រឆាំងជនជាប់ចោទចំនួន៤នាក់ទៀត ។ មិនដូចជា ឌុច ទេ អតីតមេដឹកនាំជាន់ខ្ពស់ទាំងនោះមានការសហការជាមួយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតិចតួចណាស់ ហើយជនជាប់ចោទទាំង៤នាក់នោះបានបដិសេធរាល់ការទទួលខុសត្រូវទាំងអស់ចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងក្នុងអំឡុងការគ្រប់គ្រងរបស់ខ្លួន ។ សំណុំរឿង០០២នេះអាចនឹងផ្ដល់ការលំបាកដល់សហព្រះរាជអាជ្ញារបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ នៅពេលជាមួយគ្នានេះដែរ សំណុំរឿងប្រឆាំងនឹងអតីតមេដឹកនាំរបបខ្មែរក្រហមដែលជារបបដ៏សាហាវព្រៃផ្សៃបំផុតបានបង្ហាញពីព្រឹត្តិការណ៍ដ៏សំខាន់សម្រាប់ប្រទេសកម្ពុជា និងសហគមន៍អន្តរជាតិ ។ ជាការពិត កម្ពុជាកំពុងតែបង្កើតប្រវត្តិសាស្ត្ររបស់ខ្លួនហើយ ។

**អេលីហ្សាបែត ជូ**

# វេទិកាប្រវត្តិសាស្ត្រនៃគម្រោងអប់រំអំពីប្រល័យពូជសាសន៍

វេទិកាប្រវត្តិសាស្ត្រនៃគម្រោងអប់រំពីប្រល័យពូជសាសន៍ បានចាប់ផ្តើមដោយការបើកនិងថ្លែងសុន្ទរកថាអំពីប្រវត្តិសាស្ត្រខ្មែរក្រហមដោយលោកសាស្ត្រាចារ្យ ដេវីត ឆេនល័រ និង ប្រែសម្រួលមកជាភាសាខ្មែរដោយ លោក អេង កុកថាយ ។ លោកសាស្ត្រាចារ្យ ដេវីត ឆេនល័រ បានស្រាវជ្រាវអំពីប្រវត្តិសាស្ត្រប្រទេសកម្ពុជាអស់រយៈពេលជិត៥០ឆ្នាំមកហើយ ហើយត្រូវបានចាត់ទុកថាជាអ្នកជំនាញម្នាក់នៅក្នុងវិស័យនេះ ។ លោកសាស្ត្រាចារ្យ ឆេនល័រ បានពិពណ៌នាសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ថាជាការរៀបរាប់រឿងរ៉ាវប្រវត្តិសាស្ត្រចម្បងមួយដែលសរសេរឡើងសម្រាប់សិស្សកម្រិតវិទ្យាល័យនិងប្រជាជនកម្ពុជាទូទៅ ។ លោកសាស្ត្រាចារ្យបានបកស្រាយបន្ថែមទៀតថា លោករំពឹងថាសៀវភៅរបស់ ឌី ខាំបូលី ជាការលើកទឹកចិត្តដល់អ្នកផ្សេងទៀតក្នុងការស្រាវជ្រាវអំពីអតីតកាលនៃរបបខ្មែរក្រហមក្នុងលក្ខណៈជាប្រព័ន្ធនេះ ។ លោកសាស្ត្រាចារ្យ ឆេនល័រ បាននិយាយថា ការសរសេរប្រវត្តិសាស្ត្រគឺជាវិធីសាស្ត្រមួយក្នុងការទទួលបានភាពជាម្ចាស់លើអតីតកាលដែលបានកើតឡើង ហើយបើទោះបីជាចាំបាច់តម្រូវឲ្យជនបរទេសសរសេរពីបញ្ហាខ្មែរក៏ដោយ ក៏លោកសង្ឃឹមថាប្រជាជនកម្ពុជានឹងសរសេរប្រវត្តិសាស្ត្ររបស់ខ្លួនដោយខ្លួនឯង ។ លោកសាស្ត្រចារ្យបានបកស្រាយបន្តទៀតថា វាមានសារសំខាន់ណាស់ក្នុងការដឹងថាហេតុអ្វីបានជាមានខ្មែរក្រហម? តើអ្វីទៅជាខ្មែរក្រហម? នរណាជាខ្មែរក្រហម ហើយមានប្រភពចេញពីណានិងដោយរបៀបណា? ប៉ុន្តែដោយសារតែភាពឈឺចាប់ពីអតីតកាល ជនរងគ្រោះមានការលំបាកក្នុងការតាំងអារម្មណ៍សរសេររឿងរ៉ាវផ្ទាល់ខ្លួនជាលាយលក្ខណ៍អក្សរសាស្ត្រណាស់ ។

លោកសាស្ត្រាចារ្យ ឆេនល័រ បានប្រៀបធៀបមេដឹកនាំក្នុងសម័យខ្មែរក្រហមទៅនឹងវីរបុរសនៃសោកនាដកម្មដែលមិនអាចត្រឡប់មកធ្វើអ្វីដែលអ្នកទាំងអស់នោះធ្លាប់ធ្វើបាន ប៉ុន្តែមិនដូចវីរបុរសនៃសោកនាដកម្មដែលភាគច្រើនជាមេដឹកនាំនៅរស់ទេ ។ លោកសាស្ត្រាចារ្យបានសង្កត់ធ្ងន់ថាមានសារសំខាន់ណាស់ក្នុងការចាត់ទុកនូវអ្វីយើងដែលបានកើតឡើងជាអន្តរជាតិ និងនៅកម្ពុជាផង នៅពេលដែលសិក្សាអំពីខ្មែរក្រហម ។ លោកសាស្ត្រាចារ្យ ឆេនល័រ បាននិយាយអំពីបក្សកុម្មុយនីស្តកម្ពុជាដែលបានលុបបំបាត់ចោលសិទ្ធិជាបុគ្គល និងការបំផ្លិចបំផ្លាញភាពជាគ្រួសារ ដោយកត់សម្គាល់ឃើញថាសកម្មភាពទាំងនោះត្រូវបានយកមកអនុវត្តយ៉ាងដុនដាបនិងវិនាសកម្មជាងអ្វីដែលបានធ្វើដោយគូបដិបក្សរបស់ខ្លួននៅក្នុងសហភាពសូវៀតទៅទៀត ។ លោកសាស្ត្រាចារ្យ ឆេនល័រ បានសរសេរនៅក្នុងសៀវភៅមួយថា



ហ៊ឹម ហ៊ុយ និយាយទៅកាន់អ្នកភូមិ

កម្ពុជាប្រជាធិបតេយ្យគឺរបបកុម្មុយនីស្តកម្ពុជាមួយដែលមានឥទ្ធិពលមកពីខាងក្រៅដែលជាការលាយធាតុផ្សំរបៀបកុម្មុយនីស្តមួយរវាងបរទេសនិងកម្ពុជា និងបានបញ្ចប់ទៅដោយនិយាយថា "កង់ប្រវត្តិសាស្ត្រ" ដែលពាក្យនេះត្រូវបានប្រើប្រាស់ដោយខ្មែរក្រហមជាញឹកញាប់ ។ កង់ប្រវត្តិសាស្ត្រនោះបានវិលទៅរកមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ ហើយទីបំផុតប្រជាជនកម្ពុជាប្រមាណពីរលាននាក់បានស្លាប់បាត់បង់ជីវិតក្នុងរយៈពេលមិនដល់បួនឆ្នាំផង ។

បន្ទាប់មក វគ្គសំណួរចម្លើយបានឈានចូលមកដល់ដោយមានគ្រូប្រហែលជា១០រូបបានឡើងចោទជាសំណួរ ។ គ្រូម្នាក់ដែលត្រូវបានជម្លៀសពីទីក្រុងភ្នំពេញទៅកាន់ខេត្តកណ្តាលនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បានសួរថាហេតុអ្វីបានជាប្រជាជនមកពីទីក្រុងភ្នំពេញទទួលបានរបបអាហារខុសពីប្រជាជនដទៃទៀត? លោកសាស្ត្រាចារ្យ ឆេនដល័រ បានឆ្លើយទៅវិញថាភាពខុសប្លែកគ្នានៃការទទួលរបបអាហារនេះគឺបណ្តាលមកពីការឲ្យតម្លៃទៅលើ "ប្រជាជនមូលដ្ឋាន" ខ្លាំងជាង "ប្រជាជន១៧មេសា" ឬ "ប្រជាជនថ្មី" ។ គ្រូម្នាក់ទៀតបានសួរអំពីទំនាក់ទំនងគ្នាទៅវិញទៅមករវាងរបបកម្ពុជាប្រជាធិបតេយ្យជាមួយប្រទេសចិននិងប្រទេសវៀតណាមនិងសួរអំពីមូលហេតុដែលបណ្តាលឲ្យអង្គការសហប្រជាជាតិខ្វះការធ្វើអន្តរាគមន៍មកលើរបបខ្មែរក្រហម ។ លោកសាស្ត្រចារ្យ ឆេនល័រ បានបកស្រាយដោយពន្យល់ថា កាលជំនាន់នោះអង្គការសហប្រជាជាតិមិនទាន់មានយន្តការរក្សាសន្តិសុខដូចពេលបច្ចុប្បន្ននេះទេ ហើយក៏មិនមានការបោះឆ្នោតដើម្បីមកធ្វើអន្តរាគមន៍មកលើប្រទេសកម្ពុជាដែរ ។ គ្រូម្នាក់បានក្រោកឈរហើយសួរថាហេតុអ្វីបានជាឧក្រិដ្ឋកម្មអន្តរជាតិទាំងនេះមិនត្រូវបានកាត់នៅក្នុងតុលាការអន្តរជាតិទីក្រុងឡាអេ ។ លោកសាស្ត្រចារ្យ ឆេនល័រ បានឆ្លើយថា រាជរដ្ឋាភិបាលកម្ពុជា មិនមានបំណងឲ្យតុលាការនេះស្ថិតនៅក្រៅប្រទេសទេ ហើយរដ្ឋាភិបាលបានហៅទង្វើនេះថាការរំលោភលើអធិបតេយ្យភាពរបស់ប្រជាជនកម្ពុជា ។ សំណួរចុងក្រោយនិងជាសំណួរដែលប្រជាជនទូទៅចង់ដឹង ហើយត្រូវបានចោទសួរដោយគ្រូម្នាក់គឺថា ហេតុអ្វីបានជាខ្មែរក្រហមប្រព្រឹត្តនូវអ្វីដែលបានធ្វើកន្លងមកនៅអំឡុងពេលខ្លួនកាន់អំណាច ។ លោកសាស្ត្រាចារ្យ ឆេនល័រ បានឆ្លើយប្រាប់លោកគ្រូអ្នកគ្រូទាំងអស់ថា នេះគឺជាការទទួលខុសត្រូវរបស់លោកគ្រូ-អ្នកគ្រូទាំងអស់ក្នុងការត្រៀមនូវសំណួរដើម្បីឆ្លើយទៅកូនសិស្ស ហើយនេះគឺជាកម្មវត្ថុដ៏ចម្បងនៃការរៀបចំវេទិកានេះឡើង ។




បន្ទាប់ពីលោកសាស្ត្រាចារ្យ ឆេនល័រ អ្នកដែលឡើងមានមតិបន្ទាប់គឺអតីតអ្នកយាមគុកម្នាក់នៅមន្ទីរស-២១ ហ៊ឹម ហ៊ុយ ។ លោកគ្រូ-អ្នកគ្រូបានស្តាប់យ៉ាងយកចិត្តទុកដាក់នៅខណៈដែល ហ៊ឹម ហ៊ុយ រៀបរាប់យ៉ាងក្បោះក្បាយអំពីរបៀបដែលគាត់បានមកដល់មន្ទីរស-២១ និងបទពិសោធន៍ខ្លះៗនៅអំឡុងពេលដែលគាត់ធ្វើជាសន្តិសុខនៅទីនោះ ។ បន្ទាប់មក ហ៊ឹម ហ៊ុយ ក៏បានរៀបរាប់ពីមុខងារដែលគាត់ធ្វើក្រោយពីគាត់ត្រូវបានផ្លាស់ចេញពីមន្ទីរស-២១ទៅធ្វើស្រែនៅជើងឯក ។ ហ៊ឹម ហ៊ុយ បានរៀបរាប់ដំណើររឿងដូចតទៅៈ គាត់បានវាយចូលទីក្រុងភ្នំពេញនៅថ្ងៃទី

១៧ ខែមេសាក្នុងនាមជាកងទ័ពម្នាក់របស់កងពលលេខ៧០៣ ។ ក្រោយមក ហ៊ឹម ហ៊ុយ ត្រូវបានចាត់តាំងឲ្យធ្វើសន្តិសុខនៅមន្ទីរ ស-២១ ។ ក្នុងនាមជាអ្នកយាមម្នាក់ គាត់បាននិយាយថា គាត់មិនដែលបានសម្លាប់នរណាម្នាក់ដោយផ្ទាល់ទេ ប៉ុន្តែគាត់ត្រូវទទួលបន្ទុកខាងដឹកអ្នកទោសទៅជើងឯកដើម្បីសម្លាប់ ។ ហ៊ឹម ហ៊ុយ បានរៀបរាប់ថាជីវិតរបស់កម្មាភិបាលពីមួយថ្ងៃទៅមួយថ្ងៃគឺ «រង់ចាំដល់វេនគេយកទៅសម្លាប់» តែប៉ុណ្ណោះ ។ ហ៊ឹម ហ៊ុយ បាននិយាយបន្តទៀតថា គាត់ត្រូវបានបញ្ជូនទៅធ្វើស្រែនៅជើងឯកក្នុងឆ្នាំ១៩៧៨ ហើយនៅពេលដែលវៀតណាមចូលមក គាត់បានរត់ភៀសខ្លួនចេញជាមួយនឹងកម្មាភិបាលផ្សេងទៀត ។ សំណួរជាច្រើនបានត្រូវបានចោទសួរទៅកាន់ ហ៊ឹម ហ៊ុយ និងសំណួរភាគច្រើនគឺទាក់ទងទៅនិងអារម្មណ៍ផ្ទាល់ខ្លួនរបស់គាត់ក្នុងនាមជាអ្នកយាមម្នាក់នៅមន្ទីរស-២១ ។ គ្រូម្នាក់បានរៀបរាប់ថា ហ៊ឹម ហ៊ុយ មើលទៅមិនដូចជាឃាតករទាល់តែសោះ ។ ហ៊ឹម ហ៊ុយ បានបញ្ជាក់បន្ថែមទៀតថា គាត់មិនដែលបានសម្លាប់នរណាម្នាក់ទេ ហើយការបញ្ជាឲ្យសម្លាប់អ្នកទោសគឺចេញមកពី ឌុច ដែលជាប្រធានមន្ទីរស-២១ផ្ទាល់ ។ នៅពេលដែលត្រូវបានសួរអំពីបំណងរបស់គាត់នៅថ្ងៃអនាគត ហ៊ឹម ហ៊ុយ បាននិយាយថា គាត់ចង់និយាយទៅកាន់សាធារណជនដូចជាវេទិកានេះជាដើម ពីព្រោះគាត់ចង់ឲ្យប្រជាជនបានដឹងអំពីខ្មែរក្រហម និងបង្រៀនក្មេងៗជំនាន់ក្រោយឲ្យដឹងពីរបបនេះ ។

បន្ទាប់មក លោកស្រី ឡូរ៉ា សាំមើរ ឡើងបង្ហាញអំពីមេរៀនរបស់គាត់ដែលប្រែសម្រួលដោយលោក ជី ទេរិទ្ធ អំពីប្រវត្តិសាស្ត្រក្នុងតំបន់ប៉ៃលិន ។ ខ្លឹមសារសំខាន់នៃការបង្ហាញរបស់លោកស្រីគឺជាការវិភាគទៅលើភាពជោគជ័យនៃវិស័យសេដ្ឋកិច្ចក្នុងក្រុងប៉ៃលិនដែលជាទីប្រជុំជនមួយមានរយៈពេលដ៏ខ្លីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយបើតាមគំនិតរបស់លោកស្រី ការបង្ហាញនេះក៏បានរៀបរាប់ពីជំហានមួយចំនួនដែលនាំទៅរកការបង្រួបបង្រួមជាតិដែរ ។ នៅឆ្នាំ១៩៩២ សាស្ត្រាចារ្យ សាំមើរ បានចំណាយរយៈពេលពីរថ្ងៃនៅក្នុងតំបន់ប៉ៃលិន ហើយលោកស្រីបានបង្ហាញដល់លោកគ្រូ-អ្នកគ្រូនូវរូបថតផ្ទាល់ខ្លួនមួយចំនួននៃទីក្រុងប៉ៃលិននៅពេលដែលអ្នកស្រីនៅទីនោះ ។ ប៉ៃលិនត្រូវបានបោះបង់ចោលរហូតដល់ពេលកងទ័ពជាតិកម្ពុជាប្រជាធិបតេយ្យបានដណ្តើមកាន់កាប់សាជាថ្មីដើម្បីរៀបចំសម្រាប់ដំណើរទស្សនកិច្ចមួយរបស់សម្តេចព្រះប្រមុខរដ្ឋ នរោត្តម សីហនុ ។ ផ្ទះដែលបោះបង់ចោលត្រូវបានជួសជុលសាឡើងវិញដោយទាហាន ហើយគ្រួសារនីមួយៗត្រូវទទួលខុសត្រូវចំពោះការជួសជុលផ្ទះដែលបាក់បែកដោយសម្ភារៈទិញមកពីប្រទេសថៃ ។ រូបថតមួយសន្លឹករបស់លោកស្រី សាំមើរ និងមេបញ្ជាការកងទ័ពខ្លះដែលថតនៅលើកំពូលភ្នំយ៉ាតជាសម្បត្តិវប្បធម៌ដ៏ថ្លៃថ្លានិងមានសារៈសំខាន់ជាពិសេស ដោយមេបញ្ជាការចង់បង្ហាញថា ប្រាសាទនេះមិនត្រូវបានបំផ្លិចបំផ្លាញទេ ហើយត្រូវបានថែទាំយ៉ាងល្អ ។ មេបញ្ជាការខ្មែរក្រហមនោះចង់បង្ហាញឲ្យប្រជាជនកម្ពុជាដឹងថា កេរមរតកជាតិមានសុវត្ថិភាពល្អណាស់ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ។ ការអភិវឌ្ឍនៃទីក្រុងនេះមានដំណើរយ៉ាងយឺតៗ ដែលក្រោយមកឃើញកើតមានសណ្ឋាគារតូចមួយ អគារមួយខ្នង និង ហាងលក់ថ្នាំមួយកន្លែងតែប៉ុណ្ណោះ ។

មកត្រឹមឆ្នាំ១៩៩៥ គឺជាជោគជ័យផ្នែកសេដ្ឋកិច្ចមួយដោយមានប្រជាជនប្រមាណបីពាន់នាក់បានផ្លាស់ទីលំនៅទៅកាន់ទីក្រុងនោះជារៀងរាល់ឆ្នាំ ។ ប៉ៃលិនមានការផ្លាស់ប្តូរវិស័យសេដ្ឋកិច្ច និងសង្គមកិច្ចយ៉ាងលឿនតាំងពីភាពបរាជ័យក្នុងសង្គ្រាមនៃរបបកម្ពុជាប្រជាធិបតេយ្យមក ។ នៅពេលដែល ប៉ុល ពត អំពាវនាវឲ្យមានការពង្រឹងជាតិនិយមនិងរស់នៅជាសមូហភាពឡើងវិញក្នុងឆ្នាំ១៩៩៦ មេបញ្ជាការកងទ័ពទាំងអស់មិនស្តាប់តាមបញ្ជារបស់គាត់ទេ ។ នៅខណៈនោះ ប្រជាជនប្រមាណជាពីរម៉ឺននាក់បានបោះបង់ចោលចលនាខ្មែរក្រហម ។ លោកស្រី សាំមើរ បាននិយាយថា «ភាពជោគជ័យនៃវិស័យសេដ្ឋកិច្ចសង្គមជាក់ស្តែងនៅពេលនោះតម្រូវឲ្យមេបញ្ជាការទាំងអស់គោរពតាមឆន្ទៈរបស់ប្រជាជនហើយអនុវត្តតាមលទ្ធិប្រជាធិបតេយ្យ» ។ មកត្រឹមឆ្នាំ១៩៩៨ ចំនួនប្រជាជននៅប៉ៃលិនកើនដល់៧០,៤៨៦នាក់ ដែលជាខេត្តមួយរីកដុះដាលលឿនជាងគេបំផុតនៅក្នុងប្រទេស ។ នៅទីបញ្ចប់ក្នុងការបង្ហាញលោកស្រីបញ្ជាក់ថា ការវិវឌ្ឍវិស័យសេដ្ឋកិច្ចនិងនយោបាយរបស់ទីក្រុងប៉ៃលិនគឺ «មិនមានគម្រោងទុកជាមុនទេ វាកើតឡើងដោយចៃដន្យ ដោយផ្សែផ្សំគ្នា និងគ្មាន

គម្រោងច្បាស់លាស់ឡើយ»។ នៅក្នុងវគ្គសំណួរចម្លើយ គ្រូម្នាក់បានសួរអំពីថាតើក្រៅពីប្រទេសចិន មានប្រទេសណាខ្លះដែលបានផ្តល់ថវិកាជួយខ្មែរក្រហម? លោកស្រីបានរៀបរាប់ថា នៅអំឡុងទសវត្សរ៍៨០ ជំនួយតិចតួចទទួលបានមកពីបណ្តាប្រទេសមួយចំនួននៅអាស៊ីអាគ្នេយ៍ ប៉ុន្តែមិនមានជំនួយមកពីប្រទេសផ្សេងទៀតទេ។ គ្រូម្នាក់ទៀតបានសួរថា បើសិនពឹងផ្អែកទៅលើព័ត៌មានដែលបានបង្ហាញ គាត់អាចស្មានបានថាការបរាជ័យរបស់កម្ពុជាប្រជាធិបតេយ្យគឺជាលទ្ធផលនៃការបែកបាក់គ្នារវាងប្រទេសចិននិងសហភាពសូវៀត។ លោកស្រីសាំមើរ បានឆ្លើយបដិសេធថា «ទេ» ពីព្រោះថាការបែកបាក់គ្នាបានដោះស្រាយរួចហើយ នៅក្នុងឆ្នាំ១៩៨៩ និងបានសង្កត់ធ្ងន់ថា កម្ពុជាប្រជាធិបតេយ្យបានបរាជ័យដោយសារបញ្ហាផ្ទៃក្នុង។

ចុងក្រោយ លោក នង ចាន់ផល ដែលជាអ្នករួចរស់ជីវិតពីមន្ទីរស-២១ បានឡើងបកស្រាយម្តង។ ចាន់ផល ជាមនុស្សម្នាក់ក្នុងចំណោមក្មេងបួននាក់ដែលនៅរានមានជីវិត។ ឪពុករបស់គាត់ជាកម្មាភិបាលខ្មែរក្រហមម្នាក់នៅក្នុងខេត្តកំពង់ស្ពឺ ហើយនៅពាក់កណ្តាលឆ្នាំ១៩៧៨ គ្រួសាររបស់គាត់បានទទួលសំបុត្រអញ្ជើញមួយច្បាប់ឲ្យមកកាន់ទីក្រុងភ្នំពេញ។ កាលនោះម្តាយរបស់គាត់មានជំងឺ ហើយ ចាន់ផល នៅចាំថា ពេលមកដល់មន្ទីរស-២១ កម្មាភិបាលនៅទីនោះបានស្រែកឲ្យគ្រួសារគាត់ចេញពីក្នុងឡាន។ ម្តាយរបស់គាត់ដែលកំពុងឈឺមានការលំបាកក្នុងការធ្វើតាមបញ្ជារបស់កម្មាភិបាលទាំងនោះណាស់ ចាន់ផល បានឃើញកម្មាភិបាលខ្មែរក្រហមវាយនិងរុញម្តាយរបស់គាត់ដួលទៅលើដី។ ចាន់ផល និងបងប្រុសរបស់គាត់នៅបែកពីម្តាយនៅពេលចូលទៅកាន់មន្ទីរនោះ ហើយបានត្រឹមតែសម្លឹងមើលម្តាយពីចម្ងាយប៉ុណ្ណោះហើយតាំងពីពេលនោះមក ចាន់ផល ក៏លែងបានជួបម្តាយរបស់គាត់រហូត។ នៅថ្ងៃមួយ ជិតដល់ថ្ងៃរំដោះ ចាន់ផល ដែលពួនពីក្រោយគំនរខោអាវដោយខ្លាចថា ប្រសិនបើគាត់រត់ចេញគាត់នឹងវង្វេងម្តាយ។ នៅពេលដែលកងទ័ពវៀតណាមចូលមកកងទ័ពទាំងនោះបានប្រទះឃើញ ចាន់ផល និងក្មេងបីនាក់ទៀតដែលនៅរស់។ តាមការចងចាំ ចាន់ផល បានរៀបរាប់ថា គាត់បាននៅមន្ទីរស-២១ មិនដល់មួយខែទេ ហើយយោងទៅលើឯកសារបានបញ្ជាក់ថា ចាន់ផល នៅទីនោះអស់រយៈមួយអាទិត្យឬក៏តិចជាងនេះ។ បន្ទាប់មក គ្រូម្នាក់បានសួរអំពីរបបអាហារដែលទទួលបានប្រចាំថ្ងៃនៅមន្ទីរស-២១។ ចាន់ផល បាននិយាយថា គាត់មិនមានអាហារហូបប្រហែលបួនដប់ថ្ងៃពីព្រោះកម្មាភិបាលក្នុងទីនេះបានរត់ភៀសខ្លួនអស់ហើយមុនពេលដែលកងទ័ពវៀតណាមមកដល់។ ចាន់ផល គ្រាន់តែចងចាំថា កាលនោះមិនមានទឹកផឹកគ្រប់គ្រាន់ទេ ហើយបួនប្រុសរបស់គាត់ស្ទើរតែស្លាប់ដោយដាច់ពោះទៅហើយ។ គ្រូម្នាក់ទៀតបានសួរថាតើម្តាយរបស់ ចាន់ផល បានស្លាប់ដោយសារជំងឺឬខ្មែរក្រហមសម្លាប់? ចាន់ផល មិនបានដឹងពិតប្រាកដថាម្តាយរបស់គាត់ស្លាប់បែបណាទេ តែគាត់បានបញ្ជាក់ថា បើទោះជាកម្មាភិបាលខ្មែរក្រហមមិនសម្លាប់ម្តាយរបស់គាត់ក៏ម្តាយគាត់ស្លាប់ដោយសារជំងឺដែរ។ ចាន់ផល នៅតែនឹកឃើញការឈឺចាប់ ហើយការនិយាយរឿងរ៉ាវនេះឡើងធ្វើឲ្យគាត់ហូរទឹកភ្នែកខណៈពេលកំពុងនិយាយនេះ។ សំណួរចុងក្រោយដែលគ្រូម្នាក់ចោទសួរទៅ ចាន់ផល ថាតើគាត់ពេញចិត្តចំពោះដំណើរការកាត់ទោសមេខ្មែរក្រហមរាល់ថ្ងៃនេះឬទេ? ចាន់ផល មិនពេញចិត្តនឹងតុលាការនេះទេ ហើយគាត់បាននិយាយថា គាត់មិនអាចទទួលយកនូវការសូមទោសរបស់ ឌុច បានឡើយ។ ការឈឺចាប់របស់ម្តាយជាទីស្រឡាញ់របស់គាត់បានកប់យ៉ាងជ្រៅក្នុងចិត្តគាត់ហើយ ចាន់ផល នៅតែចងចាំម្តាយរបស់គាត់យ៉ាងច្បាស់។ ចាន់ផល បានរង់ចាំតុលាការនេះយូរមកហើយ ហើយគាត់សង្ឃឹមថាតុលាការនេះនឹងនាំមកនូវយុត្តិធម៌។ បន្ទាប់ពី ចាន់ផល និយាយចប់ លោក ឌី ខាំបូលី បានសុំឲ្យអ្នកទាំងអស់គ្នាក្រោកឈរឡើងដើម្បីរំលែកទុក្ខវេទនាចំពោះការឈឺចាប់របស់ម្តាយគាត់។

នៅថ្ងៃបិទវគ្គ លោក ឌី ខាំបូលី និងលោក វ៉ាន់ថាន់ ពៅដារ៉ា បានថ្លែងអំណរគុណដល់វាគ្មិនបរទេសទាំងអស់ដែលបានជួយក្នុងដំណើរការវេទិកានេះ។ ជាកិច្ចបន្ថែម បូលី និង វ៉ាន់ថាន់ ពៅដារ៉ា បានថ្លែងអំណរគុណដល់គ្រូបង្រៀនទាំងអស់ដែលមានវត្តមាននៅក្នុងវេទិកានេះ ហើយវត្តមានរបស់លោកគ្រូអ្នកគ្រូគឺជាផ្នែកមួយដែលធ្វើឲ្យគម្រោងអប់រំអំពើប្រល័យពូជសាសន៍មានប្រសិទ្ធភាព។

**ម៉ាឃីតា ស្មិត**

# ទំហំនៃអំណាចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រាប់ទាមទារសក្ខីកម្មមន្ត្រីជាន់ខ្ពស់នៃរដ្ឋាភិបាលកម្ពុជានិងសម្តេច សីហនុ

## ១) សេចក្តីផ្តើម

*សារសំខាន់និងភាពត្រឹមត្រូវដើម្បីទទួលបានសក្ខីកម្មរបស់សម្តេចសីហនុ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានក្លាយទៅជាបដិវាទនៅឆ្នាំ២០០៧ នៅពេលដែលអង្គការក្រៅរដ្ឋាភិបាលមួយដែលមានការគាំទ្រពីសហរដ្ឋអាមេរិកស្នើថា អភ័យឯកសិទ្ធិរបស់ព្រះអង្គគួរតែត្រូវបានដកចេញ ហើយតួនាទីរបស់ទ្រង់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគួរតែត្រូវបានស៊ើបអង្កេត ។ អ្នកនាំពាក្យរបស់តុលាការបាននិយាយថា «ព្រះមហាក្សត្រដែលចូលនិវត្តន៍អាចត្រូវបានយាងមកធ្វើជាសាក្សី ប៉ុន្តែករណីដែលព្រះអង្គទ្រង់យាងមកបង្ហាញព្រះកាយឬអត់គឺជាបញ្ហាមួយទៀត» ។ ដើម្បីជាការឆ្លើយតប ព្រះមហាក្សត្រដែលបានចូលនិវត្តន៍បានអញ្ជើញបុគ្គលិកអង្គការសហប្រជាជាតិឲ្យចូលរួមជជែកពិភាក្សា តាមរយៈទូរទស្សន៍រយៈពេលបីម៉ោងនៅព្រះបរមរាជវាំង ។ នៅពេលនោះ សម្តេចបានអះអាងថា បទសម្ភាសន៍របស់ព្រះអង្គ «អាចកាត់បន្ថយតម្រូវការនៃការផ្តល់សក្ខីកម្មដល់តុលាការ» ហើយប្រសិនបើអង្គការសហប្រជាជាតិមិនយល់ព្រមទេ ទ្រង់នឹង «មិនយល់ព្រមជួបឬមានព្រះបន្ទូល ឬទំនាក់ទំនងជាមួយអង្គការសហប្រជាជាតិដែលជាអ្នកបង្កើតអង្គជំនុំជម្រះឡើយ» ។ ប៉ុន្តែ អង្គការសហប្រជាជាតិសម្រេចជ្រើសរើសការមិនចូលរួមជជែកពិភាក្សាជាមួយនឹងព្រះអង្គទេ ។*

*ប្រហែលជាមួយឆ្នាំក្រោយមក មេធាវីការពារក្តី នួន ជា បានស្នើឲ្យសហចៅក្រមស៊ើបអង្កេតរបស់អង្គជំនុំជម្រះស្វែងរកសក្ខីកម្មពីព្រះមហាក្សត្រដែលចូលនិវត្តន៍ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រធានព្រឹទ្ធសភា ជា ស៊ីម និង ប្រធានរដ្ឋសភា ហេង សំរិន ។ ក្រោយមក នៅខែកក្កដា មានសេចក្តីរាយការណ៍ថា សហចៅក្រមស៊ើបអង្កេត ម៉ាសែល ឡឺម៉ុងដ៍ បានផ្ញើលិខិតមួយច្បាប់ទៅព្រះអង្គ «ក្នុងគោលបំណងចង់បានការផ្តល់សក្ខីកម្មពីព្រះអង្គ» ដែលនេះប្រហែលជាការស្នើរបស់មេធាវីការពារក្តី ។ ប៉ុន្តែមិនមានសេចក្តីរាយការណ៍ថា មេដឹកនាំជាន់ខ្ពស់របស់រាជរដ្ឋាភិបាល ដែលមេធាវីការពារក្តីរបស់ នួន ជា ចង់ឲ្យធ្វើបទសម្ភាសន៍ទទួលបានលិខិតស្រដៀងគ្នានេះដែរ ឬយ៉ាងណាទេ ។*

## ២) អំណាចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងការចេញដីកាកោះអញ្ជើញឲ្យមកបង្ហាញខ្លួន

*នៅពេលចាំបាច់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងប្រើប្រាស់ច្បាប់នីតិវិធីព្រហ្មទណ្ឌកម្ពុជានិងនីតិវិធីអន្តរជាតិដើម្បីបំពេញចន្លោះរវាងច្បាប់ក្នុងស្រុកនិងបទដ្ឋានអន្តរជាតិ ។ ទោះបីជាយ៉ាងណាក៏ដោយ រហូតដល់ក្រមនីតិវិធីព្រហ្មទណ្ឌត្រូវបានអនុម័តនៅឆ្នាំ២០០៧ កម្ពុជានៅតែខ្វះខាតក្រមពេញលេញមួយសម្រាប់ឲ្យអង្គជំនុំជម្រះប្រើប្រាស់ដដែល ។ អាស្រ័យហេតុនេះ ចៅក្រមអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានធ្វើសេចក្តីព្រាងវិធានផ្ទៃក្នុងដោយខ្លួនឯង ហើយវិធានផ្ទៃក្នុងនោះត្រូវបានអនុម័តដោយកិច្ចប្រជុំពេញអង្គរបស់តុលាការនៅឆ្នាំ២០០៧ ។ អង្គបុរេជំនុំជម្រះបាននិយាយថា ជាមួយនឹងការអនុម័តវិធានផ្ទៃក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ «អាចត្រូវបានប្រើប្រាស់នៅពេលបញ្ហាដែលមិនបានចែងក្នុងវិធានផ្ទៃក្នុងកើតឡើង» ។ នៅពេលដែល «មិនមានភាពច្បាស់លាស់ទាក់ទងនឹងការបកស្រាយពន្យល់ ឬទាក់ទងនឹងបែបបទ» នៃវិធានទាំងនេះ តុលាការ «អាចស្វែងរកការណែនាំនៅក្នុងវិធាននីតិវិធីដែលបង្កើតឡើងនៅកម្រិតអន្តរជាតិ» ។*

*វិធានផ្ទៃក្នុងបានផ្តល់អំណាចដល់សហចៅក្រមស៊ើបអង្កេតក្នុងការចេញដីកាកោះ និង «ចាត់វិធានការទៅលើជនណាដែលអាចបង្ហាញការពិត» ហើយដែលជននោះមានសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯងដែលជាសាក្សីក៏បាន ។ អង្គជំនុំជម្រះនិងអង្គជំនុំជម្រះតុលាការកំពូលមានអំណាចស្រដៀងគ្នា ។ អង្គភាពទាំងពីរមិនមានអំណាចចេញដីកា ប៉ុន្តែអង្គភាពទាំងពីរនេះអាចធ្វើបែបនេះបានដោយប្រើអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន ។*

វិធានផ្ទៃក្នុងបានកំណត់និយមន័យទៅលើដីកាកោះថា «ការបង្គាប់ដល់បុគ្គលណាម្នាក់ឲ្យចូលបង្ហាញខ្លួននៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា» ។ នៅពេលទទួលបានដីកាកោះ សាក្សីត្រូវតែបង្ហាញខ្លួន ។ «ក្នុងករណីមានការបដិសេធមិនបង្ហាញខ្លួនសហចៅក្រមស៊ើបអង្កេតអាចចេញដីកាមួយដើម្បីស្នើឲ្យនគបាលយុត្តិធម៌បង្ខំសាក្សីនោះឲ្យមកបង្ហាញខ្លួន» ។

ទាំងវិធានផ្ទៃក្នុងនិងក្រមនីតិវិធីព្រហ្មទណ្ឌមានអំណាចកោះហៅសាក្សីគ្រប់រូបដោយមិនមានការលើកលែងឡើយ ។ ទោះបីជាយ៉ាងណាក៏ដោយ វាគួរឲ្យកត់សម្គាល់ថា តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បាននិយាយថា «មិនគួរមានការចេញដីកាដោយមិនចាំបាច់ទេ ពីព្រោះក្នុងករណីដែលដីកានោះមានជាប់ពាក់ព័ន្ធនឹងការបង្ខំដោយអំណាច វាអាចបណ្តាលឲ្យជាប់ពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌ» ។

ខណៈពេលដែលតុលាការគួរតែពឹងផ្អែកទៅលើការប្រើប្រាស់ដីកាកោះ វាមានសារសំខាន់ក្នុងការទាញយកព័ត៌មានដែលមានសារសំខាន់ទាក់ទងនឹងសំណុំរឿងដើម្បីធានាថា ចុងចោទមានមធ្យោបាយដ៏មានប្រសិទ្ធភាពដើម្បីប្រមូលព័ត៌មានដែលចាំបាច់សម្រាប់ការពារក្តីឲ្យមានប្រសិទ្ធភាព ។ ប៉ុន្តែ គួរតែចៀសវាងការប្រើប្រាស់ដីកាកោះដែលអាចប្រែក្លាយទៅជាយន្តការដែលជាផ្នែកមួយនៃយុត្តិសាស្ត្ររបស់តុលាការ ។

តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន បានយល់ស្របថា ដីកាកោះមិនគួរយកមកប្រើប្រាស់ញឹកញាប់ទេ ។ ជាងនេះទៅទៀត ចៅក្រមជំនុំជម្រះតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនបានបង្ហាញទស្សនៈថា យុត្តិសាស្ត្របង្ខំ «មិនគួរយកមកប្រើប្រាស់គ្រប់ពេលទេពីព្រោះការចេញដីកាកោះប៉ះពាល់ដល់ផលប្រយោជន៍សន្តិភាព ច្បាប់និងដីកា ព្រមទាំងស្ថិរភាពនៅក្នុងប្រទេសនិងស្ថាប័នដែលស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ ។

ចៅក្រមនៃតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន មិនយល់ស្របនឹងយុត្តិសាស្ត្រនេះទេ ។ ចាស៊ីស រ៉ូបឺតសុន បាននិយាយថា «ការព្រួយបារម្ភរបស់តុលាការអន្តរជាតិក្នុងការប្រើប្រាស់ដីកាដើម្បីទាញយកសក្ខីកម្មប្រហែលជាបណ្តាលមកពីការមិនរាប់បញ្ចូលភ័ស្តុតាងដែលថាអ្នកដទៃក៏ធ្វើដូច្នោះដែរនៅនូរ៉ែមប៊ឺក ការប៉ុនប៉ងការពារការវាយប្រហារដោយពាក្យសម្តីដ៏គួរឲ្យអាម៉ាស់ និងធ្ងន់ធ្ងរទៅលើមេដឹកនាំនយោបាយដ៏ជោគជ័យ និងភាពមិនច្បាស់លាស់ថាតើប្រទេសនោះគោរពដីកាដែរឬទេ ។ នៅក្នុងទស្សនៈរបស់លោក អំណាចចេញដីការបស់តុលាការអន្តរជាតិ «គួរតែយកមកប្រើប្រាស់នៅពេលណាដែលចាំបាច់ដើម្បីសម្រេចឲ្យបាននូវការកាត់សេចក្តីដ៏យុត្តិធម៌» ។

នៅក្នុងការកំណត់ថាតើវាសមស្របឬទេក្នុងការបង្ខំឲ្យផ្តល់សក្ខីកម្ម ចៅក្រមតុលាការអន្តរជាតិត្រូវពិនិត្យមើលថាតើសាក្សីត្រូវបានការពារដោយអភ័យឯកសិទ្ធិនៃច្បាប់និងមានលក្ខណៈសមស្របនឹងទទួលដីកាដែរឬទេ ។ លក្ខណៈវិនិច្ឆ័យទាំងអស់នេះនឹងត្រូវបានពិភាក្សាដូចខាងក្រោម ។

### ៣) តើមន្ត្រីជាន់ខ្ពស់កម្ពុជា ឬសម្តេចមានអភ័យឯកសិទ្ធិក្នុងការមិនផ្តល់សក្ខីកម្មដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរឬទេ?

ទាំងកិច្ចព្រមព្រៀងនិងច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬវិធានផ្ទៃក្នុងមិនបានផ្តល់សិទ្ធិពិសេស ឬអភ័យឯកសិទ្ធិដល់ជនណាម្នាក់ទេ លើកលែងតែបុគ្គលិកតុលាការនិងមេធាវីការពារក្តី ។ ដូច្នេះ វាមានសារសំខាន់ក្នុងការពិចារណាថាតើមន្ត្រីជាន់ខ្ពស់កម្ពុជា និងសម្តេច សីហនុ មានអភ័យឯកសិទ្ធិដោយអនុលោមតាមច្បាប់កម្ពុជា ឬអន្តរជាតិដែរឬទេ ។

ជាបឋម វាមានសារសំខាន់ក្នុងការកំណត់ចរិតលក្ខណៈច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងនាមជាតុលាការជាតិ ឬតុលាការអន្តរជាតិ ឬក្នុងនាមជាតុលាការមួយដែលនៅចន្លោះរវាងតុលាការទាំងពីរដើម្បីកំណត់វិសាលភាពនៃអំណាចរបស់តុលាការ ។ ដូចដែលបានលើកឡើងដោយលោកសាស្ត្រាចារ្យ សេន នៅក្នុងបរិបទនៃការចេញដីកាចាប់ខ្លួនគណៈប្រធានរដ្ឋ ភាពស្របច្បាប់នៃដំណើរការ «ពឹងផ្អែកទៅលើអំណាចរបស់តុលាការនិងចរិតលក្ខណៈនិងមូលដ្ឋានច្បាប់ដែលត្រូវបានបង្កើតឡើង» ។ ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺជាតុលាការកម្ពុជា អង្គជំនុំជម្រះត្រូវតែប្រកាន់ខ្ជាប់នូវច្បាប់កម្ពុជា ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើអង្គជំនុំ

ជម្រះគឺជាតុលាការអន្តរជាតិ អង្គជំនុំជម្រះគ្រាន់តែប្រតិបត្តិការងារដោយត្រូវគិតទៅដល់ច្បាប់កម្ពុជាដើម្បីឲ្យស្របទៅទំនៀមទម្លាប់នៃច្បាប់អន្តរជាតិប៉ុណ្ណោះ ។

### ក) ចរិតលក្ខណៈរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលជាតុលាការចម្រុះ

មិនដូចជាតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ឬតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនមែនបង្កើតឡើងដោយអង្គការសហប្រជាជាតិ ឬដោយកិច្ចព្រមព្រៀងអន្តរជាតិទេ ។ ប៉ុន្តែអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានបង្កើតឡើងដោយច្បាប់ក្នុងស្រុកកម្ពុជាដោយអនុលោមទៅតាមកិច្ចព្រមព្រៀងឆ្នាំ២០០៣ រវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជាដែលបានបង្កើត «មូលដ្ឋានច្បាប់និងគោលការណ៍និងបែបបទនៃកិច្ចសហប្រតិបត្តិការ» ។ កិច្ចព្រមព្រៀងត្រូវបានអនុម័តដោយស្ថាប័ននីតិបញ្ញត្តិកម្ពុជានិងអនុវត្តន៍ដោយស្ថាប័ននោះតាមរយៈច្បាប់ឆ្នាំ២០០៤ (ច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា) ។ យោងទៅតាមកិច្ចព្រមព្រៀង អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានបង្កើតឡើង «ដោយមានជំនួយពីអន្តរជាតិនិងរចនាសម្ព័ន្ធតុលាការកម្ពុជាដែលមានស្រាប់សម្រាប់កាត់ទោសឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ» ។ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ អ្នកនាំពាក្យរបស់សម្តេច សីហនុ បានសង្កត់ធ្ងន់ថា នៅក្រោមច្បាប់កម្ពុជា សម្តេចមានអភ័យឯកសិទ្ធិ ពីព្រោះ «អង្គជំនុំជម្រះស្ថិតនៅក្រោមកិច្ចព្រមព្រៀងច្បាប់កម្ពុជា ហើយមិនអាចទុកច្បាប់នេះចោលបានទេពីព្រោះច្បាប់នេះត្រូវបានចរចាម្តងទៀតជាមួយអង្គការសហប្រជាជាតិ» ។

ទោះបីជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺជាផ្នែកមួយនៃប្រព័ន្ធតុលាការកម្ពុជាក៏ដោយ ក៏វាមានលក្ខណៈជាតុលាការអន្តរជាតិខ្លះដែរ ។ ឧបនាយករដ្ឋមន្ត្រី សុខ អាន បានផ្តល់ចរិតលក្ខណៈដល់អង្គជំនុំជម្រះនេះថាជា «តុលាការជាតិដែលមានលក្ខណៈអន្តរជាតិ» ។ លោកបានធ្វើកំណត់សម្គាល់ថា អង្គជំនុំជម្រះគឺជា «តុលាការកូនកាត់ឬតុលាការចម្រុះមួយដែលមានទីតាំងនៅក្នុងស្រុក ប៉ុន្តែមានទំនាក់ទំនងជាមួយទាំងច្បាប់ជាតិនិងអន្តរជាតិ ហើយបុគ្គលិក ព្រះរាជអាជ្ញា ចៅក្រមជាតិនិងអន្តរជាតិនឹងទទួលថវិកាពីជាតិនិងអន្តរជាតិ» ។ អង្គបុរេជំនុំជម្រះរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបាននិយាយថា អង្គជំនុំជម្រះគឺជា «តុលាការអន្តរជាតិពិសេសមួយ» ពីព្រោះអង្គជំនុំជម្រះគឺជា «អង្គភាពឯករាជ្យមួយដែលមានរចនាសម្ព័ន្ធតុលាការកម្ពុជា» ។ ប៉ុន្តែ មកដល់បច្ចុប្បន្ន រាល់សវនាការរបស់អង្គជំនុំជម្រះមិនទាន់បានកំណត់ឬធ្វើសេចក្តីសម្រេចឲ្យច្បាស់លាស់ទៅលើលក្ខណៈច្បាប់របស់តុលាការទេ ។

ដោយសារតែភាពមិនច្បាស់លាស់ទាក់ទងនឹងច្បាប់ជាក់លាក់របស់អង្គជំនុំជម្រះ និង លក្ខណៈអន្តរជាតិរបស់អង្គជំនុំជម្រះ អភ័យឯកសិទ្ធិនៅក្រោមច្បាប់កម្ពុជានិងអន្តរជាតិនឹងត្រូវបានពិភាក្សាដូចខាងក្រោម ៖

### ១) អភ័យឯកសិទ្ធិនៅក្រោមច្បាប់កម្ពុជា

#### ១) ច្បាប់ដែលបង្កើតឡើងសម្រាប់ព្រះមហាក្សត្រ

រដ្ឋធម្មនុញ្ញកម្ពុជាបានចែងថា «ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាគ្រងរាជសម្បត្តិ ប៉ុន្តែមិនកាន់អំណាចឡើយ ។ ព្រះមហាក្សត្រគឺជាប្រមុខរដ្ឋអស់មួយជីវិត ។ ព្រះមហាក្សត្រមិនអាចមាននរណារំលោភបំពានបានទេ» ។ សម្តេច សីហនុ បានចូលនិវត្តន៍នៅឆ្នាំ២០០៤ ហើយបុត្ររបស់ព្រះអង្គ ព្រះអង្គម្ចាស់ សីហមុនី គ្រប់គ្រងរាជបល្ល័ង្កបន្ត ។ នៅខែតុលាឆ្នាំដដែល រដ្ឋសភាកម្ពុជាបានអនុម័ត «ច្បាប់ស្តីពីព្រះបរមងារនិងព្រះរាជបុព្វសិទ្ធិរបស់អតីតព្រះមហាក្សត្រនិងមហាក្សត្រីនៃព្រះរាជាណាចក្រកម្ពុជា» ដែលក្នុងនោះបានផ្តល់ងារដល់ព្រះអង្គថាជា «ព្រះមហាវីរក្សត្រ» ។

អ្នកដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយគ្រួសារព្រះរាជវង្សជឿជាក់ថា លក្ខណៈនៃព្រះបរមងារបានធ្វើឲ្យសម្តេច សីហនុ ទទួលបានអភ័យឯកសិទ្ធិដោយអនុលោមតាមរដ្ឋធម្មនុញ្ញ ខណៈពេលដែលព្រះអង្គគឺជាព្រះមហាក្សត្រ ។ ជាឧទាហរណ៍ លោក កែ គឹមសែ អតីតប្រធានខុទ្ទការល័យរបស់ព្រះមហាក្សត្រដែលចូលនិវត្តន៍បានមានប្រសាសន៍ថា «ការហៅព្រះបិតារបស់ព្រះមហា

ក្សត្រនៃប្រទេសទៅតុលាការអាចនឹងរំលោភរដ្ឋធម្មនុញ្ញនិងច្បាប់ដែលបានផ្ដល់ព្រះបរមងារនិងព្រះរាជបុព្វសិទ្ធិដល់ព្រះអង្គ» ។ នេះក៏ជាការយល់ឃើញរបស់រាជរដ្ឋាភិបាលកម្ពុជាដែលនឹងយកច្បាប់នេះនិងរដ្ឋធម្មនុញ្ញមកប្រើនៅពេលដែលអង្គការក្រៅរដ្ឋាភិបាលមានការគាំទ្រពីសហរដ្ឋអាមេរិកស្នើឲ្យដកអភ័យឯកសិទ្ធិនិងចាប់ផ្ដើមស៊ើបអង្កេតព្រះអង្គ ។ ផ្ទុយទៅវិញ គណៈកម្មការសិទ្ធិមនុស្សនៅអាស៊ីបានប្រឆាំងថា ៖

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា មិនឲ្យមានការរំលោភបំពានទៅលើអភ័យឯកសិទ្ធិនិងចោទប្រកាន់ព្រះមហាក្សត្រ ប៉ុន្តែមិនមែនអ្នករាល់គ្នាទេ ។ សភាក៏មិនមិនអាចរំលោភបំពានដល់អតីតព្រះមហាក្សត្រ សីហនុ បានដែរ ។

ជាងនេះទៀត «អ្នកពិនិត្យច្បាប់» ដែលមិនបញ្ចេញឈ្មោះបានបង្ហាញពីយោបល់របស់ខ្លួនថា «តាមការពិត ការហៅអតីតព្រះមហាក្សត្រមកតុលាការមិនមែនជាការរំលោភទៅលើរដ្ឋធម្មនុញ្ញទេ ទោះបីជាការហៅនោះអាចប្រឈមមុខនឹងការមិនពេញចិត្តក៏ដោយ» ។

ប្រសិនបើព្រះមហាក្សត្រដែលចូលនិវត្តន៍មានរដ្ឋធម្មនុញ្ញការពារស្មើនឹងព្រះមហាក្សត្រនោះនឹងមានចម្ងល់ថាតើ «ការមិនឲ្យមានជនណាម្នាក់រំលោភបំពាន» បានរួមបញ្ចូលទាំងការការពារមិនឲ្យព្រះអង្គម្ចាស់ផ្ដល់សក្ខីកម្មដល់តុលាការដែរឬទេ ។ ទាំងរដ្ឋធម្មនុញ្ញនិងច្បាប់ក្នុងស្រុកកម្ពុជាមិនបានផ្ដល់និយមន័យនៃពាក្យថា «មិនឲ្យជនណារំលោភបំពាន» ទេ ។ អនុសញ្ញាវីយែនស្ដីពីទំនាក់ទំនងការទូតដែលទទួលស្គាល់ការមិនអាចរំលោភបំពានភ្នាក់ងារការទូត មិនត្រឹមតែហាមប្រាមមិនឲ្យមានការឃុំឃាំងឬចាប់ខ្លួនភ្នាក់ងារការទូតប៉ុណ្ណោះ ថែមទាំងចែងថា អ្នកទាំងនោះមិនមានកាតព្វកិច្ចផ្ដល់ភ័ស្តុតាងក្នុងនាមជាសាក្សីឡើយ ។ អាស្រ័យហេតុនេះ វាហាក់ដូចជាថាអត្ថន័យនៃពាក្យ «មិនឲ្យជនណារំលោភបំពាន» នឹងមិនរាប់បញ្ចូលកាតព្វកិច្ចក្នុងការផ្ដល់សក្ខីកម្មឡើយ ។

វាហាក់ដូចជាទស្សនៈទូទៅរបស់រដ្ឋាភិបាលនិងគ្រួសាររាជវង្ស ។ ដោយផ្ដល់អត្ថាធិប្បាយទាក់ទងនឹងវិសាលភាពនៃអភ័យឯកសិទ្ធិរបស់ព្រះមហាក្សត្រដែលចូលនិវត្តន៍ អនុប្រធានសភា ងួន ញិល បានអះអាងថា ព្រះមហាក្សត្រដែលចូលនិវត្តន៍ «មិនអាចត្រូវបានកោះហៅមកតុលាការបានឡើយ» ។ ស្រដៀងគ្នានេះដែរ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ មានព្រះរាជបន្ទូលថា ព្រះអង្គម្ចាស់ដែលចូលនិវត្តន៍ «មិនអាចត្រូវបានបង្ខិតបង្ខំឲ្យផ្ដល់សក្ខីកម្មទេ» ។ ព្រះអង្គក៏មានព្រះរាជបន្ទូលទៀតថា ទ្រង់មិនច្បាស់ថាតើ «នៅក្រោមច្បាប់កម្ពុជាអ្នកស៊ើបអង្កេតអាចសួរចម្លើយគណៈប្រធានរដ្ឋបានដែរឬទេ» ។ ដើម្បីបំបាត់ចម្ងល់នេះ ក្រុមប្រឹក្សាធម្មនុញ្ញគួរតែចេញសេចក្ដីថ្លែងការណ៍ជាសាធារណៈទាក់ទងនឹងប្រធានបទនេះ គឺនិយាយពីផលប៉ះពាល់ដល់មាត្រា៧នៃរដ្ឋធម្មនុញ្ញ និងច្បាប់ឆ្នាំ២០០៤ដែលចែងអំពីព្រះបរមងារនិងព្រះរាជបុព្វសិទ្ធិរបស់អតីតព្រះមហាក្សត្រនិងមហាក្សត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានលក្ខណៈជាតុលាការកម្ពុជាក្នុងស្រុក រាល់សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញគួរតែត្រូវបានរាប់បញ្ចូល ។ ដោយសារតែសវនាការអង្គបុរេបានរកឃើញថា អង្គជំនុំជម្រះមិនមែនជាតុលាការកម្ពុជាធម្មតា ប៉ុន្តែជា «តុលាការអន្តរជាតិពិសេស» ទោះបីជានៅក្រោមច្បាប់កម្ពុជាដែលថា សម្ដេច សីហនុ មានអភ័យឯកសិទ្ធិពេញលេញក៏ដោយ ក៏វាចាំបាច់ត្រូវតែបញ្ជាក់ថា ព្រះអង្គម្ចាស់មានអភ័យឯកសិទ្ធិនៅក្រោមច្បាប់អន្តរជាតិដែរ ។

### ២) ការការពារមន្ត្រីកម្ពុជាជាន់ខ្ពស់នៅក្រោមច្បាប់កម្ពុជា

រដ្ឋធម្មនុញ្ញកម្ពុជាបានផ្ដល់អភ័យឯកសិទ្ធិដល់សមាជិកសភានិងព្រឹទ្ធសភាដោយមិនឲ្យមានការឃុំឃាំងនិងការចាប់ខ្លួនដោយបទល្មើស ដរាបណាអភ័យឯកសិទ្ធិនោះត្រូវបានដកចេញ ។ មាត្រា៨០នៃរដ្ឋធម្មនុញ្ញកម្ពុជាបានចែងថា «ការចោទប្រកាន់ ការចាប់ខ្លួន ឬការឃុំខ្លួនសមាជិកសភាអាចធ្វើទៅបាន លុះត្រាតែមានការអនុញ្ញាតដោយសភា» ។ ស្រដៀងគ្នានេះដែរ មាត្រា ១០៤ បានផ្ដល់ការការពារដូចគ្នាដល់សមាជិកព្រឹទ្ធសភា ប៉ុន្តែអភ័យឯកសិទ្ធិនេះក៏អាចត្រូវបានដកដោយព្រឹទ្ធសភាដែរ ។

ទាក់ទងនឹងសមាជិករាជរដ្ឋាភិបាល រដ្ឋធម្មនុញ្ញបានទទួលស្គាល់លទ្ធភាពនៃការប្រព្រឹត្តបទឧក្រិដ្ឋឬបទល្មើសដែលអ្នកទាំងនោះអាចប្រព្រឹត្តនៅពេលបំពេញភារកិច្ច» ។ សភាត្រូវតែបោះឆ្នោតដើម្បីដាក់ពាក្យបណ្ដឹងប្រឆាំងនឹងអ្នកទាំងនោះក្នុងករណីដែល

អ្នកទាំងនោះប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរនៅពេលបំពេញភារកិច្ច ។

មិនដូចជាសម្តេចទេ មន្ត្រីជាន់ខ្ពស់មិនមាន «អភ័យឯកសិទ្ធិដែលមិនឲ្យជនណារំលោភបំពានបានឡើយ» ប៉ុន្តែអ្នកទាំងនោះមានអភ័យឯកសិទ្ធិមិនឲ្យមានការឃុំខ្លួននិងចាប់ខ្លួន ប៉ុន្តែអភ័យឯកសិទ្ធិនោះអាចត្រូវបានដកចេញបាន ។ វាហាក់ដូចជាថា ទាំងរដ្ឋធម្មនុញ្ញនិងច្បាប់កម្ពុជាមិនបានផ្តល់អភ័យឯកសិទ្ធិដល់មន្ត្រីរដ្ឋាភិបាល ដោយមិនឲ្យអ្នកទាំងនោះផ្តល់សក្ខីកម្មទាំងនៅក្នុងតុលាការអន្តរជាតិ និងតុលាការកម្ពុជាក្នុងស្រុក ។

ទោះបីជាយ៉ាងណាក៏ដោយ តុលាការកម្ពុជាប្រហែលជាអាចលើកលែងដោយមិនឲ្យមន្ត្រីទាំងនោះចូលរួមក្នុងដំណើរការទេ ដោយសារតែតួនាទីជាន់ខ្ពស់របស់មន្ត្រីទាំងនោះ ។ ចៅក្រម អាថូនៃតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនបានសំអាងទៅលើករណីបារាំងមួយដែលតុលាការបានរកឃើញថា ប្រធានាធិបតីហ្សាក់ហ្ស៊ីរ៉ាក់ មិនមានកាតព្វកិច្ចបង្ហាញខ្លួនជាសាក្សីនៅដំណាក់កាលអង្គបុរេកាត់សេចក្តីទេ ពីព្រោះ «កាតព្វកិច្ចត្រូវដើរស្របជាមួយយុត្តិសាស្ត្រនៃការបង្គាប់បញ្ជា» ។ ស្រដៀងគ្នានេះដែរ តុលាការកំពូលនៃតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនបានរកឃើញថា «គណៈប្រធានរដ្ឋបម្រុងមានអភ័យឯកសិទ្ធិមិនចូលរួមក្នុងតុលាការជាតិក៏ដូចជាតុលាការជាតិនៃប្រទេសទីបី ។ ទោះបីជាយ៉ាងណាក៏ដោយ ទាក់ទងនឹងអភ័យឯកសិទ្ធិរបស់សម្តេចដែលបានពិភាក្សានៅខាងលើ ទោះបីជាមន្ត្រីទាំងនោះមានអភ័យឯកសិទ្ធិនៅក្រោមច្បាប់កម្ពុជាក៏ដោយ ក៏អភ័យឯកសិទ្ធិនោះប្រហែលជាមិនយកមកអនុវត្តនៅក្នុងតុលាការអន្តរជាតិដូចជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរ ។

### ក) លទ្ធភាពដែលអាចប្រើប្រាស់អភ័យឯកសិទ្ធិផ្ទាល់ខ្លួននៅក្រោមច្បាប់អន្តរជាតិ

ច្បាប់អន្តរជាតិបានបង្កើតថា មន្ត្រីជាន់ខ្ពស់មួយចំនួនមានអភ័យឯកសិទ្ធិពេញលេញទាក់ទងនឹងយុត្តាធិការរបស់បរទេស ។ អភ័យឯកសិទ្ធិផ្ទាល់ខ្លួនបានផ្តល់ឲ្យ «អ្នកដែលមានឋានៈជាមន្ត្រីរដ្ឋាភិបាល ហើយអភ័យឯកសិទ្ធិនោះនឹងយកមកដំណើរការជានីតិវិធី» ។

តុលាការយុត្តិធម៌អន្តរជាតិបាននិយាយថា «ច្បាប់អន្តរជាតិបានចែងថា មន្ត្រីជាន់ខ្ពស់មួយចំនួនរបស់ប្រទេស ដូចជាគណៈប្រធានរដ្ឋ អ្នកដឹកនាំរដ្ឋាភិបាល និងរដ្ឋមន្ត្រីក្រសួងការបរទេសមានអភ័យឯកសិទ្ធិពីយុត្តាធិការរបស់ប្រទេសដទៃ រួមទាំងយុត្តាធិការព្រហ្មទណ្ឌនិងយុត្តាធិការស៊ីវិល ។ អភ័យឯកសិទ្ធិមិនមែនសម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួនរបស់មន្ត្រីទេ ប៉ុន្តែដើម្បីធានាថាមន្ត្រីនោះអាចបំពេញភារកិច្ចដែលខ្លួនគ្រប់គ្រង ។ ដូច្នេះ វិសាលភាពនៃអភ័យឯកសិទ្ធិដែលមន្ត្រីមានគឺពឹងផ្អែកទៅលើមុខងារដែលមន្ត្រីនោះមាន ។ ចំពោះមន្ត្រីក្រសួងការបរទេសដែលតែងតែធ្វើដំណើរទៅមកនិងដឹកនាំទំនាក់ទំនងបរទេសដោយមានអំណាចពេញលេញតំណាងឲ្យប្រទេស តុលាការយុត្តិធម៌អន្តរជាតិយល់ឃើញថា «នៅអំឡុងពេលកាន់តំណែងដែលមន្ត្រីនោះបំពេញភារកិច្ចនៅបរទេស មន្ត្រីនោះមានអភ័យឯកសិទ្ធិពេញលេញពីយុត្តាធិការព្រហ្មទណ្ឌ ។

ច្បាប់អន្តរជាតិមិនបានផ្តល់អភ័យឯកសិទ្ធិដល់មន្ត្រីជាន់ខ្ពស់ពីការចោទប្រកាន់នៅក្នុងប្រទេសរបស់ខ្លួនឡើយ ។ ដូច្នេះមន្ត្រីទាំងនេះអាចត្រូវបានកាត់ទោសនៅក្នុងតុលាការក្នុងស្រុកដោយអនុលោមទៅតាមវិធានច្បាប់ក្នុងស្រុក ។ ជាងនេះទៅទៀត មន្ត្រីជាន់ខ្ពស់ដូចជា អ្នកដឹកនាំប្រទេសឬអតីតមន្ត្រីក្រសួងការបរទេសអាចត្រូវប្រឈមមុខនឹងដំណើរការនីតិវិធីព្រហ្មទណ្ឌនៅតុលាការអន្តរជាតិមួយចំនួនដែលមានយុត្តាធិការនោះ ។ យោងទៅតាមអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៅតុលាការពិសេសសេរ៉ាឡេអូន ៖

*ភាពខុសគ្នារវាងតុលាការជាតិនិងអន្តរជាតិអាចនឹងកើតមានឡើងដោយសារតែគោលការណ៍អធិបតេយ្យភាពរបស់ប្រទេសមួយមិនអាចសម្រេចទៅលើការដឹកនាំរបស់ប្រទេសដទៃបាន ។ គោលការណ៍អភ័យឯកសិទ្ធិរបស់ប្រទេសមួយកើតចេញពីភាពស្មើគ្នានៃអធិបតេយ្យភាពរបស់ប្រទេសនោះ ដូច្នេះវាមិនមានទំនាក់ទំនងនឹងតុលាការព្រហ្មទណ្ឌអន្តរជាតិដែលមិនមែនជាផ្នែកណាមួយនៃប្រទេសនោះឡើយ ហើយដែលគ្រាន់តែទទួលអំណាចពីសហគមន៍អន្តរជាតិប៉ុណ្ណោះ ។*

ទោះបីជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនបានរួមបញ្ចូលច្បាប់កម្ពុជាស្តីអំពីអភ័យឯកសិទ្ធិ ប៉ុន្តែមន្ត្រីជាន់ខ្ពស់

កម្ពុជានិងសម្តេចសីហនុមិនមានអភ័យឯកសិទ្ធិមិនទទួលការចោទប្រកាន់ពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទេបើយោងទៅតាមច្បាប់អន្តរជាតិ ។ ទោះបីជាយ៉ាងណាក៏ដោយ វាមិនច្បាស់ថាតើអ្នកទាំងនេះមិនមានអភ័យឯកសិទ្ធិមិនផ្តល់សក្ខីកម្មទេ ។

អង្គជំនុំជម្រះនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានរកឃើញថា មន្ត្រីរដ្ឋាភិបាលគ្មានអភ័យឯកសិទ្ធិមិនទទួលដីកាកោះឲ្យមកផ្តល់សក្ខីកម្មទេ ហើយអាចនឹងទទួលការបង្ខំឲ្យចូលរួមក្នុងការផ្តល់បទសម្ភាសន៍មុនពេលផ្តល់សក្ខីកម្មទៀត ។ ប៉ុន្តែ តុលាការទាំងពីរនេះមិនធ្លាប់បានចេញដីកាកោះហៅមន្ត្រីជាន់ខ្ពស់ណាម្នាក់ឡើយ ។ នៅក្នុងការពិភាក្សាដែលមិនមានសារសំខាន់ដល់ការធ្វើសេចក្តីសម្រេចរបស់តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ចៅក្រមពីររូបនៃតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាអូនបានយល់ស្របគ្នា ប៉ុន្តែចៅក្រមមួយរូបទៀតជំទាស់ ។ ចៅក្រម ថមសុន បាននិយាយថា ៖

តាមច្បាប់អន្តរជាតិស្តីអំពីជនដៃដល់ដែលប្រព្រឹត្តបទល្មើសអន្តរជាតិ ប្រសិនបើករណីពីមុនៗមិនមានការផ្តល់អភ័យឯកសិទ្ធិដល់ប្រមុខរដ្ឋ ឬរដ្ឋាភិបាលឬមន្ត្រីរដ្ឋាភិបាលមិនទទួលការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌអន្តរជាតិទេ នោះច្បាប់អន្តរជាតិមិនអាចផ្តល់អភ័យឯកសិទ្ធិដល់អ្នកទាំងនោះមិនឲ្យធ្វើជាសាក្សីផ្តល់សក្ខីកម្មនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិទេ ។

ម្យ៉ាងវិញទៀត អាយជូ ចៅក្រមអង្គជំនុំជម្រះដែលយល់ស្របថា ប្រមុខរដ្ឋមិនគួរត្រូវបានការពារពីការចោទប្រកាន់អំពីបទល្មើសនៅក្រោមច្បាប់អន្តរជាតិដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ គឺមិនបានគិតដល់ថាប្រមុខរដ្ឋអាចនឹងត្រូវតុលាការអន្តរជាតិតម្រូវឲ្យផ្តល់សក្ខីកម្មទេ ។ នេះដោយសារតែ «ការមិនបានគិត»ទៅដល់ភាពបរាជ័យក្នុងការចេញដីកាកោះដែលមិនមានជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មអន្តរជាតិ ហើយលោកគិតថា តុលាការព្រហ្មទណ្ឌអន្តរជាតិមិនមានយុត្តាធិការចោទប្រកាន់ប្រមុខរដ្ឋដោយបទល្មើសទូទៅឡើយ ។

### ឃ) សេចក្តីសន្និដ្ឋាន

មានភាពមិនច្បាស់លាស់ជាច្រើនទាក់ទងនឹងសម្តេចសីហនុ និងមន្ត្រីរដ្ឋាភិបាលកម្ពុជាជាន់ខ្ពស់មួយចំនួន ។ វាមានភាពមិនច្បាស់លាស់ថាអ្នកទាំងនោះមានអភ័យឯកសិទ្ធិមិនផ្តល់សក្ខីកម្មបើយោងទៅតាមច្បាប់កម្ពុជា ប៉ុន្តែប្រសិនបើអ្នកទាំងនោះមានអភ័យឯកសិទ្ធិ នោះវាក៏មិនអាចយកមកប្រើប្រាស់នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានដែរ ។ លក្ខណៈជាក់លាក់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលជា «តុលាការអន្តរជាតិ» មិនទាន់ត្រូវបានបញ្ជាក់ទេ ហើយទំនាក់ច្បាប់កម្ពុជាក៏មិនទាន់ត្រូវបានបញ្ជាក់នៅឡើយដែរ ។ ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនមានកាតព្វកិច្ចទទួលស្គាល់អភ័យឯកសិទ្ធិណាមួយតាមច្បាប់ក្នុងស្រុកខណៈពេលដែលសម្តេចនិងមន្ត្រីជាន់ខ្ពស់មិនគួរទទួលការចោទប្រកាន់ដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នោះវានៅតែមិនមានភាពច្បាស់លាស់ថាតើអ្នកទាំងនោះមានអភ័យឯកសិទ្ធិមិនផ្តល់សក្ខីកម្មដែរឬទេ ។

ទោះបីជាតុលាការអន្តរជាតិមិនទាន់បានចេញដីកាណាមួយទាក់ទងនឹងអភ័យឯកសិទ្ធិរបស់មន្ត្រីជាន់ខ្ពស់ក៏ដោយ ប៉ុន្តែតុលាការបានពិចារណាថាតើសក្ខីកម្មរបស់មន្ត្រីទាំងនោះនឹងស្របទៅតាមតម្រូវការច្បាប់សម្រាប់ចេញដីកាកោះដែរឬយ៉ាងណា ។ ចំពោះគ្រប់ករណីអ្នកទាំងនោះអាចធ្វើការកំណត់ខ្លួនឯងដោយពិចារណាទៅលើថា តើសក្ខីកម្មរបស់មន្ត្រីជាន់ខ្ពស់ទាំងនេះមានប្រយោជន៍ដល់សំណុំរឿងដែរឬទេ ហើយថាតើត្រូវតែមានការបង្ខំឲ្យមកផ្តល់សក្ខីកម្មដែរ ឬទេ ។

### ៦) តើវាមានសារសំខាន់និងស្របច្បាប់ដែរឬទេក្នុងការកោះហៅព្រះមហាក្សត្រដែលចូលនិវត្តន៍ ឬមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់?

នៅតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន នៅក្នុងសំណុំរឿងពីរមានការស្នើឲ្យកោះហៅប្រធានាធិបតេយ្យនៃប្រទេសសេរ៉ាឡេអូន អាមេត តេចាន កាបាស ។ វិធានរបស់តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនបានចែងថាៈ

នៅពេលដែលមានការស្នើពីភាគីណាមួយឬការដាក់សារណា ចៅក្រមឬអង្គជំនុំជម្រះត្រូវតែចេញដីកាផ្សេងៗ និងបញ្ជូនដីកាក្នុងគោលបំណងដើម្បីស៊ើបអង្កេតឬសម្រាប់រៀបចំសវនាការកាត់ក្តី ។

តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាក៏ប្រើប្រាស់បទដ្ឋានដូចគ្នានេះដែរ ប៉ុន្តែលក្ខខណ្ឌរបស់តុលាការទាំងពីរនេះគួរឲ្យចាប់អារម្មណ៍ជាងអ្វីដែលបានចែងនៅក្នុងវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺវាបានផ្តល់អំណាចដល់សហចៅក្រមស៊ើបអង្កេតក្នុងការកោះហៅនិងយក «សក្ខីកម្មពីជនណាដែលអាចបង្ហាញការពិត» ។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏អង្គជំនុំជម្រះគួរតែពិនិត្យទៅលើការវិភាគរបស់តុលាការពិសេសនៅប្រទេសសេរ៉ាឡេអូននិងកត្តាដែលតុលាការនេះពិចារណាក្នុងការកំណត់ភាពត្រឹមត្រូវនៃការបង្ខំឲ្យមានការផ្តល់សក្ខីកម្មដែរ ។

យោងទៅតាមយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី អង្គជំនុំជម្រះនៃតុលាការពិសេសនៅប្រទេសសេរ៉ាឡេអូនបានរកឃើញថា វិធាន៥៤មានជាប់ពាក់ព័ន្ធនឹងការសាកល្បងពីរជំហាន : ការកំណត់ ១) ថាតើ «អ្នកដាក់សំណុំរឿងធ្លាប់បានបង្ហាញពីមូលហេតុសមហេតុផលថាសាក្សីដែលជាប់ពាក់ព័ន្ធអាចផ្តល់ព័ត៌មានដែលអាចជួយដល់សំណុំរឿងដោយមានបង្ហាញយ៉ាងច្បាស់អំពីបញ្ហាទាក់ទងនឹងសវនាការនៅពេលខាងមុខ ២) ថាតើ «ការប្រើប្រាស់ដីកាមានសារសំខាន់សម្រាប់ការស៊ើបអង្កេត ឬសម្រាប់ការរៀបចំ ឬការដឹកនាំសំណុំរឿង និងថាតើព័ត៌មាននេះអាចទទួលបានតាមរយៈមធ្យោបាយផ្សេងៗឬទេ» ។ «ប្រសិនបើអ្នកដាក់ពាក្យសុំមិនអាចយកព័ត៌មានពីសាក្សីដែលមានជាប់ពាក់ព័ន្ធ នោះត្រូវតែមានការពិចារណាតាមមធ្យោបាយផ្សេងទៀត» ។

## ក) តើសក្ខីកម្មដែលបានស្វែងរកអាចផ្តល់ការពិតដែរឬទេ?

ការចេញដីកាកោះដែលស្របតាមបទដ្ឋានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចធ្វើឲ្យមានការផ្តល់ការពិត ។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូននឹងប្រើប្រាស់បទដ្ឋានខ្ពស់ជាងនេះប្រសិនបើសក្ខីកម្ម «អាចផ្តល់ផលប្រយោជន៍ដល់សំណុំរឿងដោយមានការបង្ហាញពីបញ្ហាច្បាស់លាស់សម្រាប់សវនាការនៅពេលខាងមុខ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបាននិយាយថា នៅក្រោមបទដ្ឋាន អ្នកដាក់សំណុំរឿងត្រូវតែបញ្ជាក់ពីព័ត៌មានជាក់លាក់ដែលចង់បានពីសាក្សីនិងត្រូវតែបង្ហាញពីទំនាក់ទំនងរវាងព័ត៌មាននិងករណីប្រឆាំងនឹងជនត្រូវចោទ ។ នៅក្នុងការកំណត់ថាព័ត៌មាននឹងជួយដល់អ្នកដាក់សំណុំរឿងដោយចេញដីកាកោះ តុលាការត្រូវពិចារណាពីតួនាទីរបស់សាក្សីដែលមានជាប់ពាក់ព័ន្ធនឹងព្រឹត្តិការណ៍ទំនាក់ទំនងរវាងជននោះនឹងជនត្រូវចោទដែលជាប់ពាក់ព័ន្ធនឹងការចោទប្រកាន់ហេតុផលដែលគិតថាជននោះមានជាប់ពាក់ព័ន្ធនឹងព្រឹត្តការណ៍ទាំងនោះនិងរាល់ការអះអាងរបស់ជននោះទៅកាន់អ្នកចោទប្រកាន់ឬទៅកាន់អ្នកដែលមានជាប់ពាក់ព័ន្ធនឹងព្រឹត្តិការណ៍នោះ ។

ករណីន័រមែនរបស់តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន តុលាការបានពិនិត្យទៅលើតួនាទីរបស់ប្រធានាធិបតីកាបាស ដែលមានតួនាទីជាប្រធានាធិបតីនៅអំឡុង ពេលជម្លោះប្រដាប់អាវុធរបស់ប្រទេសសេរ៉ាឡេអូន ។ លោកត្រូវបានចោទប្រកាន់ថាបាន «បញ្ជា ឧបត្ថម្ភដោយសម្ភារៈ និង ទំនាក់ទំនងជាមួយសមាជិកផ្សេងៗរបស់អ្នកដឹកនាំកងកម្លាំងការពារជនស៊ីវិលដែលបានស្នើសុំសក្ខីកម្មរបស់លោក ។ តុលាការយល់ឃើញថា ជនត្រូវចោទខកខានមិនបានបញ្ជាក់ពីភាពជាក់លាក់ដែលថាសក្ខីកម្មរបស់ជននោះមានជាប់ពាក់ព័ន្ធការចោទប្រកាន់ ឬជួយដល់សំណុំរឿង ។

ស្រដៀងគ្នានេះដែរ ចំពោះសក្ខីកម្មរបស់លោកប្រធានាធិបតីស្តីពីការសន្ទនារបស់លោកជាមួយជនត្រូវចោទទាក់ទងនឹងសកម្មភាពនិងទីកន្លែងដែលមាននៅក្នុងការចោទប្រកាន់ អង្គជំនុំជម្រះយល់ឃើញថាមិនមានព័ត៌មានជាក់លាក់ដែលបញ្ជាក់ថាសក្ខីកម្មនេះអាចជួយដល់ជនត្រូវចោទចំពោះការចោទប្រកាន់ទេ ។ ចំពោះភ័ស្តុតាងដែលលោកប្រធានាធិបតីមានទាក់ទងនឹងការចូលរួមរបស់ជនត្រូវចោទនៅក្នុងគម្រោងដើម្បីស្តាររដ្ឋាភិបាលរបស់លោកឡើងវិញ អង្គជំនុំជម្រះបានអះអាងថា លោកប្រធានាធិបតីមិនបានផ្តល់ការបកស្រាយដ៏មានប្រសិទ្ធភាពថាតើសក្ខីកម្មបែបនេះនឹងមានឥទ្ធិពលដល់ការរកឃើញរបស់តុលាការអំពីធាតុផ្សំនៃឧក្រិដ្ឋកម្ម ឬទម្រង់នៃការទទួលខុសត្រូវដោយរបៀបណាទេ ។

ក្រោយមក នៅក្នុងសេចក្តីសម្រេចលើករណី សេសាយ

និងអ្នកផ្សេងទៀត អង្គជំនុំជម្រះបានរកឃើញថា សក្ខីកម្មរបស់អតីតប្រធានាធិបតី កាបាស អាចជួយដល់ជនត្រូវចោទពីព្រោះមានករណីជាក់លាក់ពីរគឺ ៖ ១) ជនត្រូវចោទ «ព្យាយាមធ្វើការការពារអ្នករក្សាសន្តិភាពបេសកម្មអង្គការសហប្រជាជាតិនៅប្រទេសសេរ៉ាឡេអូនដែលត្រូវបានឃុំឃាំងនិងអនុវត្តឡើងវិញនូវដំណើរការបញ្ឈប់ការប្រើអាវុធ ២)ជនត្រូវចោទ «មិនបានទទួលបញ្ជាឲ្យធ្វើការវាយប្រហារ ឬជួយធ្វើការវាយប្រហារប្រឆាំងនឹងអ្នករក្សាសន្តិភាពបេសកកម្មអង្គការសហប្រជាជាតិនៅប្រទេសសេរ៉ាឡេអូនទេ ប៉ុន្តែបានអនុវត្តដោយខ្លួនឯង ។

សេចក្តីសម្រេចមិនបានបញ្ជាក់ថាហេតុអ្វីបានជាលទ្ធផលនៅក្នុងករណីនេះមានលក្ខណៈផ្សេងគ្នាទៅវិញ ។ ចៅក្រម អាយថូ បានបង្ហាញពីទស្សនៈរបស់លោកថា ដោយសារតែករណី ន័រមែន មេធាវីការពារក្តីមិនបានទាមទារសក្ខីកម្មដោយផ្ទាល់ដែលអាចមានផលប៉ះពាល់ដល់ការសម្រេចថាមានទោសឬក៏អត់ទេ ប៉ុន្តែនៅក្នុងករណីនេះមេធាវីការពារក្តីបានស្វែងរកព័ត៌មានដែលអាចជួយប្រឆាំងដល់ការចោទប្រកាន់ ។ លោកគិតថា ការស្នើរបស់ន័រមែន ដែលធ្វើឡើងតែឯងគឺដើម្បីបង្ហាញពីកំហឹងប្រឆាំងនឹងកាបាស ដែលបានធ្វើឲ្យអ្នកទាំងនោះទទួលការចោទប្រកាន់បំបាក់មុខនិងសើចំអកលោក ព្រមទាំងធ្វើឲ្យលោកមានជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនៅក្នុងជម្លោះនៅសេរ៉ាឡេអូន ។

ក្រុមការពារក្តី នួន ជា ដែលបានព្យាយាមស្វែងរកឱកាសដើម្បីសួរទៅកាន់សម្តេចបាននិយាយថា «វាពិបាកនឹងនិយាយថាមានតែបុគ្គលម្នាក់ដែលអាចបង្កើតរបបកម្ពុជាប្រជាធិបតេយ្យ ។ មេធាវីទាំងនេះបានលើកឡើងពីតួនាទីរបស់សម្តេចដែលជាប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ វត្តមានរបស់ព្រះអង្គនៅក្នុងប្រទេសកម្ពុជាក្នុងរបបខ្មែរក្រហមនិងព័ត៌មានសម្ងាត់របស់ព្រះអង្គប្រហែលជាមានទំនាក់ទំនងជាមួយមេដឹកនាំជាន់ខ្ពស់និងឋានានុក្រមនៅក្នុងរបបនោះ ។ ជាងនេះទៅទៀត «សម្តេច សីហនុ ជាមនុស្សតែម្នាក់ដែលអាចផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការចោទប្រកាន់ដែលទាក់ទងនឹងរចនាសម្ព័ន្ធអំណាចកម្ពុជាប្រជាធិបតេយ្យ» ។

ទាក់ទងនឹងមន្ត្រីកម្ពុជាជាន់ខ្ពស់ដែលធ្លាប់ធ្វើការជាមួយខ្មែរក្រហមតែបានចាកចេញពីតំណែងមុនការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ក្រុមការពារក្តី នួន ជា បានអះអាងថា អ្នកទាំងនេះបានត្រៀមខ្លួនជួយជាជំនួយដល់អ្នកស៊ើបអង្កេតរបស់តុលាការដោយផ្តល់ព័ត៌មានអំពីរចនាសម្ព័ន្ធអំណាចខ្មែរក្រហម ។ ការស្នើរបស់ក្រុមការពារក្តី នួន ជា នេះបានបង្ហាញពីតួនាទីចាស់របស់មន្ត្រីទាំងនេះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនិងព័ត៌មានដែលមេដឹកនាំទាំងនេះអាចមានទាក់ទងនឹងគម្រោងនៃការសម្លាប់ជាប្រព័ន្ធ ។ រដ្ឋមន្ត្រីក្រសួងព័ត៌មាន ខៀវ កាញារីទ្ធ បានឆ្លើយតបថា ៖

សំណួរនេះល្អណាស់ ។ ប្រសិនបើអ្នកទាំងនោះគឺជាកម្មាភិបាលថ្នាក់ទាប តើអ្នកទាំងនោះអាចដឹងពីប្រព័ន្ធនោះដោយរបៀបណា? ប្រសិនបើសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន មិនបានដឹងច្បាស់ថានៅក្នុងរបបនោះ នួន ជា ជាអ្នកណា តើលោកអាចធ្វើជាសាក្សីដោយរបៀបណា?

នៅក្នុងការជំទាស់នឹងសេចក្តីសម្រេចរបស់តុលាការលើករណី ន័រមែន ចៅក្រម ថមសុន បានអះអាងថា តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនគួរតែអនុម័តបទដ្ឋានដែលអាចបត់បែនច្រើនជាងនេះដើម្បីធ្វើការបន្ធូរឲ្យមានការផ្តល់សក្ខីកម្មក្នុងគោលបំណងប្រកាន់នូវគោលការណ៍យុត្តិធម៌ជាមូលដ្ឋាននិង «ធានាថា ភ័ស្តុតាងជាប់ពាក់ព័ន្ធដែលមានសារសំខាន់សម្រាប់បង្ហាញពីការពិតនឹងអាចត្រូវបានបង្ហាញដោយហេតុផលយុត្តិសាស្ត្រនៃច្បាប់ ។ យុត្តិសាស្ត្រដែលលោកយល់ស្របស្រដៀងទៅនឹងវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលថាសហចៅក្រមស៊ើបអង្កេតនឹងធ្វើការពិចារណាថាតើការចេញដីកាកោះអាចធ្វើឲ្យមានការផ្តល់ការពិតដែរឬទេ ។ នៅក្នុងទស្សនៈរបស់ចៅក្រម ថមសុន លឿនពេកក្នុងការពិចារណាថាតើភ័ស្តុតាងដែលផ្តល់ដោយសាក្សីអាចត្រូវឬខុសពីអ្វីដែលអ្នកដាក់សំណុំរឿងចង់បានខណៈពេលដែលវាដូចទៅនឹងអ្វីដែលបានរៀបចំ ។ ប៉ុន្តែលោកជឿថាភ័ស្តុតាងដែលមានទើបអាចតម្រូវឲ្យបង្ហាញថាព័ត៌មានដែលត្រូវបានគេស្វែងរកមានសារសំខាន់សម្រាប់ការស៊ើបអង្កេតឬសម្រាប់សវនាការ ។

ការយល់ឃើញបន្ថែមទៅលើបទដ្ឋានរបស់អង្គជំនុំជម្រះប្រហែលជាត្រូវបានបង្ហាញដោយការពិភាក្សារបស់ចៅក្រម រ៉ូបឺតសុន នៅក្នុងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន

ករណីបណ្តឹងឧទ្ធរណ៍ជំទាស់ដែលទាក់ទងនឹងសម្ភារៈ ភ័ស្តុតាងដែលអាចបង្ហាញឲ្យឃើញនូវអ្វីដែលបានកើតឡើងពិត ។ ទោះបីជាលោកមានទស្សនៈដូចនឹងចៅក្រម ថមសុន ដែលថាតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនគួរតែប្រើប្រាស់យុត្តិសាស្ត្រដែលអាចបត់បែនច្រើនជាងនេះក្នុងការចេញដីកាកោះ ប៉ុន្តែលោកយល់ឃើញថា ៖

វាមិនមែនជាតួនាទីរបស់តុលាការឧក្រិដ្ឋកម្មសង្គ្រាមទេ ។ ការអនុវត្តដែលចំណាយពេលដ៏យូរនោះត្រូវតែបន្សល់ទុកឲ្យអ្នកប្រវត្តិសាស្ត្រនិងគណៈកម្មការស្វែងរកការពិត ។ តុលាការគ្រាន់តែស្វែងរកនូវអ្វីដែលពាក់ព័ន្ធនឹងសកម្មភាពជាក់លាក់ដែលនឹងត្រូវយកមកចោទប្រកាន់ចុងចោទ និងពិនិត្យថាតើភ័ស្តុតាងចោទប្រកាន់អាចធ្វើមិនឲ្យមានការសង្ស័យដែរឬទេ ។ ព្រះរាជអាជ្ញាដែលធ្វើការចោទប្រកាន់ជានិច្ចកាលតែងតែបង្កើតកំហុស ប៉ុន្តែនៅពេលនេះមេធាវីការពារក្តីគឺជាអ្នកមានកំហុសក្នុងការគិតថាតុលាការអាចដោះស្រាយភ័ស្តុតាងដែលទទួលបានដែលមានជាប់ពាក់ព័ន្ធតែប៉ុណ្ណោះ ពីព្រោះវាបង្ហាញពីពន្លឺខ្លះនៃជម្លោះ ។

ដោយគិតទៅដល់ការដាស់តឿនរបស់ចៅក្រម រ៉ូប៊ីតសុន តួនាទីរបស់សាក្សី និងអ្នកដែលមានការជាប់ពាក់ព័ន្ធជាមួយ នួន ជា និងជនសង្ស័យផ្សេងទៀតបង្ហាញថា សក្ខីកម្មរបស់សម្តេចប្រហែលជាអាចបង្ហាញពីការពិតទាក់ទងនឹងការចោទប្រកាន់របស់ នួន ជា ។ ទោះបីជាយ៉ាងណាក៏ដោយ វាមិនច្បាស់ថាយើងអាចធ្វើបែបនេះជាមួយមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ដែលជាកម្មាភិបាលខ្មែរក្រហមថ្នាក់កណ្តាលមិនមានការជាប់ពាក់ព័ន្ធ ឬដឹងពីការសម្រេច ឬគោលនយោបាយដែលធ្វើឡើងដោយមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យទេ ។

## ២) តើដីកាកោះមានសារសំខាន់ដែរឬទេ?

នៅក្នុងការសម្រេចថាដីកាបង្គាប់មានសារសំខាន់ដូចដែលតម្រូវតាមលក្ខន្តិកៈ តុលាការអន្តរជាតិតម្រូវឲ្យអ្នកការពារក្តីបង្ហាញថា ភ័ស្តុតាងពាក់ព័ន្ធនឹងសំណុំរឿង «មិនអាចទទួលបានដោយមិនមានអន្តរាគមន៍ពីតុលាការ» ។ នេះពាក់ព័ន្ធនឹងសេចក្តីសម្រេចពីរ ៖ តើសាក្សីនឹងផ្តល់សក្ខីកម្មដោយស្ម័គ្រចិត្ត? ហើយតើព័ត៌មានអាចយកចេញពីប្រភពផ្សេងបានដែរឬទេ?

## ១) តើមន្ត្រីរដ្ឋាភិបាលកម្ពុជាជាន់ខ្ពស់ ឬព្រះមហាវីរក្សត្រនឹងទទួលសំណើរមកផ្តល់សក្ខីកម្មដោយស្ម័គ្រចិត្តដែលឬទេ?

តុលាការអន្តរជាតិតម្រូវថាអ្នកការពារក្តីដែលស្វែងរកសក្ខីកម្ម «ដំបូងត្រូវតែបង្ហាញថាខ្លួនបានព្យាយាមធ្វើឲ្យមានការសហការពីភាគីដែលជាប់ពាក់ព័ន្ធ ប៉ុន្តែមិនបានសម្រេច» ។

១២ឆ្នាំតាំងពីរដ្ឋាភិបាលកម្ពុជាស្នើសុំជំនួយអន្តរជាតិដំបូងដើម្បីបង្កើតតុលាការខ្មែរក្រហម សម្តេច សីហនុ បានបង្ហាញជាច្រើនលើកច្រើនសាថាព្រះអង្គនឹងផ្តល់សក្ខីកម្មទាក់ទងនឹងបទពិសោធន៍របស់ព្រះអង្គនៅអំឡុងរបបខ្មែរក្រហម ។ អ្នកចរចាដំបូងជាមួយអង្គការសហប្រជាជាតិដែលពាក់ព័ន្ធនឹងកិច្ចការតុលាការបានផ្តល់របាយការណ៍ថា ៖

សម្តេច សីហនុ បានផ្តល់ការគាំទ្រយ៉ាងពេញទំហឹងទាក់ទងនឹងបញ្ហាខ្មែរក្រហមដែលបានលើកឡើងនៅក្នុងរបាយការណ៍សភាជាតិ ដោយបង្ហាញថាប្រសិនបើការផ្តួចផ្តើមគំនិតនេះមិនបន្តនោះនិទ្ទណ្ឌភាពនៅក្នុងប្រទេសកម្ពុជានឹងមានការបញ្ចប់ ។ ព្រះអង្គបានបន្ថែមទៀតថា ព្រះអង្គផ្ទាល់នឹងទទួលការកោះហៅរបស់តុលាការដើម្បីបង្ហាញពីទំនាក់ទំនងរបស់ព្រះអង្គជាមួយនឹងរបបខ្មែរក្រហម ។ ទ្រង់បានមានព្រះបន្ទូលថា «នេះគឺជាភារកិច្ចរបស់ខ្ញុំព្រះអង្គ» ។

នៅឆ្នាំ១៩៩៩ សម្តេចមានព្រះបន្ទូលថា «ទ្រង់នឹងបោះបង់ភាពជារាជវង្សនិងអភ័យឯកសិទ្ធិដែលមាននៅក្នុងរដ្ឋធម្មនុញ្ញ ហើយថែមទាំងសុខចិត្តជាប់ពន្ធនាគារផង» ប្រសិនបើសាលាក្តីខ្មែរក្រហមចង់ជំនុំជម្រះ ។ ជាងនេះទៅទៀត «ទោះបីជាចៅក្រមមិនកោះហៅខ្ញុំព្រះអង្គ ក៏ខ្ញុំព្រះអង្គនឹងបង្ហាញខ្លួននៅមុខតុលាការដែរ» ។ នៅឆ្នាំ២០០៤ សម្តេចបានចេញសេចក្តីសម្រេចដោយលើកឡើងពីសុឆន្ទៈក្នុងការចង់ផ្តល់សក្ខីកម្មនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ «ខ្ញុំព្រះអង្គនឹងផ្តល់សក្ខីកម្មនៅតុលាការមិនត្រឹមតែម្តងទេ គឺរាល់ពេលដែលតុលាការបើកសវនាការសួរចម្លើយ ខ្ញុំព្រះអង្គនឹងផ្តលសក្ខីកម្មរាល់ថ្ងៃ រាល់សប្តាហ៍ រាល់ខែ រាល់ឆ្នាំ នៅពេលដែលខ្ញុំព្រះអង្គមានជីវិតនៅរស់» ។ ព្រះអង្គក៏បានស្នើថា អគ្គមហេសីរបស់ព្រះអង្គម្ចាស់ក្សត្រី នរោត្តម មនីនាថ ក៏នឹងទទួលការអនុញ្ញាតឲ្យឡើងផ្តល់សក្ខីកម្មដែរពីព្រោះមហេសី

របស់ខ្ញុំព្រះអង្គចងចាំកាលបរិច្ឆេទបានល្អនិងដឹងពី «ស្ថានភាពរស់នៅ» របស់ព្រះអង្គ ។ នៅចុងឆ្នាំ២០០៦ មានការដកស្រង់ព្រះរាជបន្ទូលរបស់ព្រះអង្គថា «ខ្ញុំព្រះអង្គមិនខ្វះភាពក្លាហានទៅផ្តល់ចម្លើយនៅតុលាការទេ» ។

ទោះបីជាយ៉ាងណាក៏ដោយ ការបង្ហាញពីការគាំទ្ររបស់សម្តេចចំពោះដំណើរការរបស់អង្គជំនុំជម្រះត្រូវបានរំខានដល់ការមិនពេញចិត្តរបស់តុលាការ និងការខ្វះសុឆន្ទៈក្នុងការចូលរួម ។ ជាក់ស្តែង ចាប់តាំងពីអង្គការសហប្រជាជាតិបដិសេធមិនទៅព្រះបរមរាជវាំងតាមការស្នើរបស់ព្រះអង្គនៅឆ្នាំ២០០៧ សម្តេចបានមានព្រះបន្ទូលថា ទ្រង់នឹងមិនសហការទេ ។ ក្រោយមកមានការផ្តល់របាយការណ៍ថា អតីតព្រះមហាក្សត្រមានព្រះបន្ទូលថា «ទ្រង់បានប្រាប់មន្ត្រីទាំងនោះថា កិច្ចប្រជុំគឺជាឱកាសតែមួយគត់ដែលអាចឲ្យតុលាការទទួលបានសក្ខីកម្មរបស់ព្រះអង្គ» ។ ថ្មីៗនេះនៅឆ្នាំ២០០៩ ជំនួយការអតីតព្រះមហាក្សត្របាននិយាយថា ទ្រង់នឹងបដិសេធមិនសហការ «ទោះបីជាតុលាការបានកោះហៅព្រះអង្គមកផ្តល់សក្ខីកម្មក៏ដោយ» ។

ទោះបីជាសម្តេចចង់ផ្តល់សក្ខីកម្ម រដ្ឋាភិបាលប្រហែលជាមិនចង់ឲ្យទ្រង់ធ្វើដូច្នោះទេ ។ មន្ត្រីក្រសួងព័ត៌មាន លោក ខៀវ កាញារីទ្ធ បានមានប្រសាសន៍ថា រដ្ឋាភិបាលមិនចង់ឲ្យព្រះមហាក្សត្រដែលចូលនិវត្តន៍ត្រូវបានកោះហៅទេ ពីព្រោះវាអាចមានផលប៉ះពាល់ដល់តួនាទីរបស់ព្រះអង្គដែលជានិមិត្តរូបរបស់ប្រទេសជាតិទាំងមូល ។

មិនមានព័ត៌មានធ្វើឡើងជាសាធារណៈថានាយករដ្ឋមន្ត្រី និងមន្ត្រីមួយចំនួននឹងមកផ្តល់សក្ខីកម្មឡើយ ។ ទោះបីជាសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ជាអ្នកស្នើជំនួយពីអង្គការសហប្រជាជាតិ ដើម្បីបង្កើតសាលាក្តីខ្មែរក្រហមដែលមានរដ្ឋាភិបាលរបស់លោកជាអ្នកចរចាអំពីការបង្កើតនេះក៏ដោយ ក៏ការគាំទ្រជាសាធារណៈចំពោះតុលាការមិនដែលមានលក្ខណៈរឹងមាំខ្លាំងដែរ ។ ថ្មីៗនេះលោកបានបង្ហាញថា លោកមិនយល់ទាស់ទេប្រសិនបើតុលាការបិទទ្វារ ហើយបានប្រឆាំងនឹងតុលាការដែលធ្វើការស៊ើបអង្កេតបន្ថែមទៅលើជនសង្ស័យ៥រូបទៀត ។ ទោះបីជាយ៉ាងណាក៏ដោយ យើងមិនច្បាស់ថាលោកនិងមន្ត្រីរដ្ឋាភិបាលផ្សេងទៀតនឹងបដិសេធមិនផ្តល់សក្ខីកម្មដែរឬយ៉ាងណាទេប្រសិនបើតុលាការធ្វើការស្នើដល់អ្នកទាំងនេះ ។

យោងទៅតាមភាពមិនច្បាស់លាស់ទាក់ទងនឹងការមកផ្តល់សក្ខីកម្មរបស់ព្រះមហាក្សត្រដែលចូលនិវត្តន៍និងមន្ត្រីរដ្ឋាភិបាលប្រសិនបើអ្នកទាំងនេះទទួលការស្នើពីតុលាការ ការវាយតម្លៃថាអ្នកទាំងនោះនឹងមកផ្តល់សក្ខីកម្មគឺជាដំណាក់កាលដំបូងដែលអង្គជំនុំជម្រះត្រូវពិចារណាមុនពេលចេញដីកាកោះ ។

### ២) តើព័ត៌មានដែលចង់បានអាចទទួលបានតាមរយៈប្រភពផ្សេងដែរឬទេ?

តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនដែលយោងទៅតាមយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបាននិយាយថា «ការចេញដីកាកោះមិនមែនធ្វើឲ្យមានភាពងាយស្រួលទេ ហើយប្រសិនបើការរកភ័ស្តុតាងអាចធ្វើបានតាមមធ្យោបាយផ្សេង នោះយើងមិនគួរចេញដីកាកោះទេ ។

នៅក្នុងករណី នរមែន ជនត្រូវចោទបានអះអាងថា ក្នុងនាមជាប្រធានាធិបតីរបស់ប្រទេសសេរ៉ាឡេអូន កាបាស គឺជា «មេដឹកនាំជាន់ខ្ពស់នៃកងកម្លាំងការពារជនស៊ីវិល» ដូច្នេះលោកគួរតែមានភ័ស្តុតាងសំខាន់ទាក់ទងនឹងការបង្គាប់បញ្ជារបស់ខ្លួនរួមទាំងតួនាទីរបស់អ្នកនៅក្រោមបង្គាប់ និងខ្សែចង្វាក់នៃការបង្គាប់បញ្ជា ។ ទោះបីជាយ៉ាងណាក៏ដោយ តុលាការបានធ្វើការសម្រេចចិត្តដោយវិភាគតែបន្តិចបន្តួចទៅលើព័ត៌មានដែលទទួលបានតាមមធ្យោបាយផ្សេង ។ នៅក្នុងបណ្តឹងឧទ្ធរណ៍ សាលាឧទ្ធរណ៍នៃតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនបានយល់ស្របនឹងសាលាដំបូងដែលថា «អ្នកប្តឹងឧទ្ធរណ៍មិនបានពន្យល់ថាហេតុអ្វីបានជាការអង្កេតផ្ទាល់របស់លោកប្រធានាធិបតីទាក់ទងនឹងឧក្រិដ្ឋកម្មមានលក្ខណៈពិសេស» ។

ក្នុងការជំទាស់នឹងសេចក្តីសម្រេចរបស់តុលាការ ចៅក្រមថមសុន បានអះអាងថាចំពោះការ សម្រេចថា «តើអ្វីដែលបានកើតឡើងនៅកម្រិតខ្ពស់ជាងគេ» មានតែប្រធានាធិបតីដែលអាចផ្តល់ព័ត៌មានទាំងនោះ ។ នៅក្នុងការជំទាស់នឹងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ ចាសស៊ីស រ៉ូបើតសុន បានអះអាងថា

ភ័ស្តុតាងដែលយកមកពីទាហានដែលស្ម័គ្រចិត្តផ្តល់មិនមានតម្លៃដូចជាភ័ស្តុតាងដែលយកមកពីមេបញ្ជាការទេ ពីព្រោះតាមនិយមន័យ សក្ខីកម្មរបស់មេបញ្ជាការគួរឲ្យជឿជាក់ជាង ។ អាស្រ័យហេតុនេះលោកបានស្នើថា ដោយមិនពិចារណាថាតើភ័ស្តុតាងអាចយកមកតាមមធ្យោបាយផ្សេងឬក៏អត់ តុលាការគួរតែពិចារណាថាតើសក្ខីកម្មដែលបានស្នើអាចជាភ័ស្តុតាងល្អបំផុតដែលអាចតុលាការអាចទទួលយកបានដែរឬទេ» ។

ផ្ទុយពីតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនដែលធ្លាប់មានការព្រួយបារម្ភជាខ្លាំងថា ជនត្រូវចោទ ន័រមែន ដែលអាចបំបាក់មុខប្រធានាធិបតី កាបាស តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានចេញដីកាឲ្យអតីតមេបញ្ជាការតំបន់និងអ្នកអង្កេតយោធារបស់បេសកកម្មផ្តល់ជំនួយដល់អង្គការសហប្រជាជាតិនៅក្នុងប្រទេសរ៉្វាន់ដា និងនាយសេនាធិការកងទ័ពនៅហ្គាណាឲ្យមកផ្តល់សក្ខីកម្មបន្ទាប់ពីរកឃើញថាសក្ខីកម្មមានជាប់ពាក់ព័ន្ធនឹងការអង្កេតផ្ទាល់ខ្លួន ។ ដោយមានតួនាទីជាមន្ត្រីនៃបេសកម្មផ្តល់ជំនួយដល់អង្គការសហប្រជាជាតិនៅក្នុងប្រទេសរ៉្វាន់ដា និងធ្លាប់ជួបប្រជុំជាមួយជនត្រូវចោទ មន្ត្រីនេះអាច «មានឱកាសធ្វើការអង្កេតទៅលើព្រឹត្តិការណ៍ទាក់ទងនឹងសំណុំរឿង» ដូច្នេះព័ត៌មានដែលមន្ត្រីនោះផ្តល់អាចមានការជាប់ពាក់ព័ន្ធ និង «មិនអាចរកបានតាមមធ្យោបាយផ្សេង» ។

សម្តេច សីហនុ ទំនងជាធ្លាប់មានការអង្កេតទៅលើព្រឹត្តិការណ៍ដែលជាប់ពាក់ព័ន្ធនឹងសំណុំរឿង នួន ជា និងអ្នកដទៃទៀត ។ ទោះបីជាយើងមិនអាចយកព័ត៌មានពីសម្តេច ប៉ុន្តែតុលាការអាចយកព័ត៌មានពីអ្នកដទៃដែលអាចផ្តល់សក្ខីកម្មស្រដៀងគ្នា ។ ម្យ៉ាងវិញទៀត នាយករដ្ឋមន្ត្រីនិងមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ផ្សេងទៀតមិនទំនងជាមានព័ត៌មានទាក់ទងនឹងព្រឹត្តការណ៍ដែលយើងមិនអាចយកមកពីប្រភពផ្សេងទេ ។

### ក) សេចក្តីសន្និដ្ឋាន

ព្រះមហាវរក្សត្រតាំងពីដើមមកបានគាំទ្រអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយកាលពីមុនទ្រង់បានបង្ហាញពីការស្ម័គ្រចិត្តមកផ្តល់សក្ខីកម្មប្រសិនបើទ្រង់ត្រូវបានកោះហៅ ។ ប្រសិនបើអង្គជំនុំម្រះស្នើសុំជំនួយពីព្រះអង្គ ព្រះអង្គអាចនឹងប្រាប់រឿងរ៉ាវរបស់ព្រះអង្គដល់អង្គជំនុំជម្រះ ។ សក្ខីកម្មរបស់ព្រះអង្គអាចធ្វើឲ្យអង្គជំនុំជម្រះស្វែងរកការពិតទាក់ទងនឹងព្រឹត្តិការណ៍ឧក្រិដ្ឋកម្មដែលចោទប្រកាន់ទៅលើ នួន ជា និងអ្នកដទៃទៀត ។ ខណៈពេល ដែលសម្តេចមានព្រះសុខភាពមិនសូវល្អ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាគួរតែតម្រូវថា «ប្រសិនបើសាក្សីមានជំងឺឬមិនអាចធ្វើដំណើរ ចៅក្រមស៊ើបអង្កេតនិងក្រឡាបញ្ជីគួរតែទៅផ្ទះឬកន្លែងដែលសាក្សីរស់នៅដើម្បីយកសក្ខីកម្មពីសាក្សី» ។ អង្គជំនុំជម្រះគួរតែអនុម័តនីតិវិធីបែបនេះ ។

យើងមិនដឹងថាតើអង្គជំនុំជម្រះបានស្នើឲ្យសម្តេចនាយករដ្ឋមន្ត្រី និងមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ផ្សេងទៀតមកផ្តល់សក្ខីកម្មដែរឬទេ ប្រសិនបើសក្ខីកម្មរបស់អ្នកទាំងនោះត្រូវបានរកឃើញថាមានជាប់ពាក់ព័ន្ធនឹងសំណុំរឿង នោះអង្គជំនុំជម្រះគួរតែអនុវត្តដំហានដំបូងនេះមុននឹងចេញដីកាកោះ ។ ទោះបីជាយ៉ាងណាក៏ដោយ ដោយផ្អែកទៅលើយុត្តិសាស្ត្រអន្តរជាតិ វាមិនមានលក្ខណៈច្បាស់លាស់ថាសក្ខីកម្មរបស់អ្នកទាំងនោះមានសារសំខាន់ចំពោះដំណើរការនីតិវិធីឬមានការជាប់ពាក់ព័ន្ធដោយផ្ទាល់ទៅលើបទល្មើសដែលចោទប្រកាន់ទៅលើជនត្រូវចោទ ។

**អាន ហាញឌុល**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ៖

ផ្ទះលេខ៦៦ វិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន ក្រុងភ្នំពេញ
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
*Email: dccam@online.com.kh*
*Home page: www.dccam.org;*
*www.cambodiatribunal.org*

# ការទទួលបាននូវយុត្តិធម៌ និងការផ្សះផ្សាជាតិនៅកម្ពុជា ក្រោយអំពើប្រល័យពូជសាសន៍

***(តពីលេខមុន)***

*ខ្មែរក្រហមបានបែងចែកប្រជាជនជា «ប្រជាជនថ្មី» និង «ប្រជាជនមូលដ្ឋាន ឬប្រជាជនចាស់» ដែលនេះជាវណ្ណៈថ្មីសន្មត ដោយយោងតាមមុខងាររបស់អ្នកទាំងនោះនៅមុនពេលខ្មែរក្រហមចូលកាន់អំណាចនៅក្នុងឆ្នាំ១៩៧៥ ។ ប្រជាជនចាស់សំដៅចំពោះប្រជាជនដែលរស់នៅតាមទីជនបទក្រោមការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជា មុនពេលចូលកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយប្រជាជនថ្មី ឬស្គាល់ថាជាប្រជាជន ១៧មេសា ដែលសំដៅចំពោះប្រជាជនដែលត្រូវជម្លៀសចេញពីទីក្រុងនិងទីប្រជុំជននានានៅថ្ងៃ១៧មេសា ឆ្នាំ១៩៧៥ ទោះបីជាមានប្រជាជនខ្លះបានរស់នៅតាមទីជនបទ ប៉ុន្តែប្តូរមកនៅទីក្រុងដោយសារគេចពីការទម្លាក់គ្រាប់បែកក៏ដោយ ។ ការបែងចែកវណ្ណៈនេះបំផ្លាញភាពជាមនុស្សដែលត្រូវបានចាត់ទុកថាអ្នកជិះជាន់នឹងត្រូវចាត់ទុកថាមិនមែនជាមនុស្សទេ ។ ប្រជាជនទាំងនេះក៏ត្រូវចាត់ទុកជាសត្រូវមួយដែររបស់បក្សកុម្មុយនីស្តកម្ពុជា ដែលក្នុងនោះមានសត្រូវខាងក្នុងនិងសត្រូវខាងក្រៅ ។ សត្រូវខាងក្នុងគឺ «ប្រជាជនថ្មី» ដែលគេបានចាត់ទុកជាអ្នកមូលធននិយម ឬសក្តិភូមិនិយមឬជាមនុស្សដែលមិនមែនជាជនជាតិខ្មែរសុទ្ធសាធ ដែលរួមទាំងមន្ត្រីរបស់រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ ប្រជាជនភាគតិច ដូចជាចាម វៀតណាម និងអ្នកមាន ឈាមជ័រកាត់ចិន អ្នករៀនសូត្រនិងជនក្បត់ជាតិផង ។ សត្រូវខាងក្រៅសំដៅអាមេរិក និងអ្នកគាំទ្រអាមេរិកដូចជា សៀម និងប្រទេសសង្គមនិយមមួយចំនួនទៀត ដូចជាវៀតណាម និងសហភាពសូវៀត ដែលខ្មែរក្រហមយល់ថា ប្រទេសទាំងនេះប៉ុនប៉ងឈ្លានពានប្រទេសកម្ពុជា ដើម្បីដាក់អាណានិគម ។ សត្រូវទាំងនេះកាន់តែបង្កភាពភិតភ័យដល់ការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា ក៏ដូចជាផលប៉ះពាល់មកលើកម្ពុជាចំពោះឥទ្ធិពលបរទេសដែរ គឺការគ្រប់គ្រងរបស់អាណានិគមរបស់បារាំងមកលើកម្ពុជានិងឥទ្ធិពលនយោបាយក្នុងការជួយកម្ពុជាឲ្យរួចផុតពីអាណានិគមបារាំង ។*

*សត្រូវទាំងឡាយដែលបានរៀបរាប់នៅខាងលើត្រូវបានខ្មែរក្រហមសម្លាប់ដោយលក្ខណៈជាខ្សែសង្វាក់ រួមទាំងវិស័យសាសនាទៀតផង ។ ដើម្បីបំផ្លាញចោលឲ្យអស់នូវឫសគល់អតីតកាលដែលជាផ្នែកមួយនៃការតស៊ូបដិវត្តន៍របស់បក្សកុម្មុយនីស្តកម្ពុជា ដើម្បីបង្កើតនូវកុម្មុយនីស្តស្អាតស្អំមុនគេបង្អស់នោះខ្មែរក្រហមបានលុបបំបាត់ចោលនូវសាសនានិងហាមឃាត់ដល់ការគោរពសាសនាទៀតផង ។ សាសនាព្រះពុទ្ធដែលធ្លាប់ជាធនធានមូលដ្ឋាននៃអត្តសញ្ញាណខ្មែរនោះបែរជាមើលឃើញជាការគំរាមកំហែងចំពោះការតស៊ូបដិវត្តន៍សម្រាប់ប្រជាជនដូចគ្នាទៅវិញ ពីព្រោះវាត្រូវបានចាត់ទុកជាការធ្វើឲ្យចម្រើន និងបង្កឲ្យមានការវិវត្តនៅក្នុងសង្គមរបស់ប្រជាជន ។ ជនរងគ្រោះឈ្មោះ សែន ខស្នាន បានរំឭកថា «បក្សកុម្មុយនីស្តកម្ពុជាបាននិយាយថាសាសនាគឺជាអំពើក្បត់នឹងបដិវត្តន៍ ប្រឆាំងនឹងនយោបាយលេនីន និងជានយោបាយសក្តិភូមិនិយម ។ ដូច្នេះ វាមិនល្អប្រសើរទេ ត្រូវលុបបំបាត់ចោល» ។ អ្នកជំនាញសាសនាព្រះពុទ្ធ ចាន់ធូ ប៊ូ បានរៀបរាប់ពីផលប៉ះពាល់នៃខ្មែរក្រហមមកលើព្រះពុទ្ធសាសនាថា «ព្រះពុទ្ធសាសនាត្រូវបានរំលាយចោលគ្រាន់តែក្នុងរយៈពេលមួយឆ្នាំប៉ុណ្ណោះ» ។ ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ព្រះសង្ឃដែលក្នុងនោះមាន កុង សួរ ត្រូវបានបង្ខំឲ្យដោះស្បង់ចីវរចេញ វត្តអារាមត្រូវបានបំផ្លាញចោលពុទ្ធបដិមាកត្រូវបានវាយកម្ទេច ហើយព្រះសង្ឃចំនួន២,៦៨០អង្គដែលគង់នៅទីអារ៉ាមសរុបចំនួន ៣,០០០នោះ គឺមានតែព្រះសង្ឃចំនួន៧០អង្គប៉ុណ្ណោះ ដែលអាចរួចរស់ជីវិតនៅឆ្នាំ១៩៧៩» ។*

*ខ្មែរក្រហមត្រូវបានគេនិយាយថាបានប្រព្រឹត្តឧក្រិដ្ឋកម្មមកលើប្រជាជនខ្លួនឯង ព្រោះប្រជាជនខ្មែរជាច្រើនត្រូវបានបក្សកុម្មុយនីស្តកម្ពុជាចាត់ទុកថាជាសត្រូវរហូតដល់ធ្លាក់ចូលក្នុងសភាពមួយដែលខ្មែរបានសម្លាប់ប្រជាជនខ្មែរដូចគ្នា ។ ឧក្រិដ្ឋកម្ម*

ដែលប្រព្រឹត្តឡើងដោយខ្មែរក្រហមមានការចាប់មនុស្សមកសម្លាប់រហូតដល់ការស៊ីសាច់មនុស្សយ៉ាងឃោរឃៅទៀតផង ។ កម្មាភិបាលខ្មែរក្រហមមួយចំនួនបានយកថ្លើមជនរងគ្រោះមកបរិភោគជាញឹកញាប់ ហើយចាត់ទុកការធ្វើទារុណកម្មនៅគុកទួលស្លែងជាការជួយបន្ថយការចងចាំរបស់ជនរងគ្រោះ ។ កម្មាភិបាលក្មេងៗដែលត្រូវគេបញ្ចុះបញ្ចូលមនោគមន៍វិជ្ជាហើយនោះបានដាក់ឲ្យរស់នៅផ្សេងពីឪពុកម្តាយ ហើយអប់រំថា «មានតែអង្គការមួយប៉ុណ្ណោះជាពុកម៉ែ» ។ ក្មេងៗជាច្រើនដែលដល់អាយុចូលសាលារៀនត្រូវបានគេលួងលោមនិងបង្ខំឲ្យចូលយោធា «បដិវត្តន៍ខ្មែរក្រហម» និងបង្ខឹកឲ្យធ្វើតាមបញ្ជាដ៏ព្រៃផ្សៃ ។ «អង្គការ» បានក្លាយជាពាក្យមួយរំឭកដល់ភាពភ័យខ្លាចនិងមិនមានសុវត្ថិភាពដល់ជីវិតមនុស្ស ដោយសារអង្គការត្រូវគេនិយាយថាជា «ភ្នែកម្នាស់» ដែលអាចឃើញរាល់អ្វីៗទាំងអស់ដែលមនុស្សគ្រប់រូបបានធ្វើ ។ នេះជាការយល់ឃើញអំពីភាពតក់ស្លុតចេញពីការដឹកនាំដ៏ឆ្គួតលេលារបស់បក្សកុម្មុយនីស្តកម្ពុជា ។ ជាញឹកញាប់ មានមនុស្សជាច្រើនបាន «បាត់ខ្លួន» ដោយការនិយាយថា «ឲ្យទៅនៅកន្លែងថ្មី» ឬ «ទៅធ្វើការកន្លែងផ្សេង» នៅពេលដែលខ្មែរក្រហមសង្ស័យជនណាម្នាក់ថាក្បត់នឹងអង្គការ សូម្បីតែជាការលួចយករបស់បន្តិចបន្តួចឬធ្លាប់មានតួនាទីណាមួយនៅក្នុងរបបមុនៗ មុនពេលខ្មែរក្រហមចូលកាន់អំណាចក៏ដោយ ។

ពុំមាននរណាម្នាក់មានសុវត្ថិភាពឡើយ សូម្បីតែកម្មាភិបាលខ្មែរក្រហមខ្លួនឯងក៏ដោយ ។ កងសន្តិសុខកុមារដែលយាមការពារនៅមន្ទីរស-២១ ក៏មានការភ័យខ្លាចចំពោះអាយុជីវិតរបស់ខ្លួន ដូចជាប្រជាជនរស់នៅតាមសហករណ៍ដែរ ។ ប្រាក់ ខន អតីតជាអ្នកយាមនិងជាអ្នកធ្វើទារុណកម្មអ្នកទោសនៅមន្ទីរស-២១ បានប្រាប់អំពីថ្នាក់លើរបស់ខ្មែរក្រហម ដែលបង្ខិតបង្ខំរាល់កិច្ចការទាំងអស់និងអារម្មណ៍ភ័យខ្លាចថាខ្ញុំមិនបានធ្វើការងារល្អនិងប្រឹងប្រែងគ្រប់គ្រាន់ ពីព្រោះ «ខ្ញុំខ្លាចត្រូវគេចោទថាជាសត្រូវផ្ទៃក្នុង... វាក្លាយជាស្ថានការណ៍គួរឲ្យភ័យខ្លាចណាស់ នៅពេលអ្នកធ្វើការជាមួយខ្ញុំចេះតែបាត់ខ្លួនរាល់ថ្ងៃ» ។ អ្នកយាមនៅមន្ទីរស-២១ម្នាក់ត្រូវគេសម្លាប់សូម្បីតែស្រែកថា «ភ្លើងឆេះផ្ទះ» នៅពេលគាត់កំពុងលង់លក់ក៏ដោយ ។ នេះបង្ហាញកាន់តែច្បាស់អំពីស្ថានការណ៍ចម្លែកនៃការប្រព្រឹត្តបទឧក្រិដ្ឋ ៖ អ្នកប្រព្រឹត្តបទឧក្រិដ្ឋជំនួសមុខឲ្យខ្មែរក្រហមគឺបានប្រថុយប្រថាននឹងជីវិតរបស់ខ្លួន ដោយកម្មាភិបាលទាំងនោះជារឿយៗត្រូវសម្លាប់ជនរងគ្រោះដើម្បីរក្សាជីវិតខ្លួនឯង ។ នេះគឺជាករណីមួយនៅក្នុងបទសម្ភាសន៍របស់លោក អាឡិច ហ៊ិនតុន ឈ្មោះ ឡូ ដែលធ្លាប់ធ្វើការនៅមន្ទីរស-២១ ។ គាត់បាននិយាយថា គាត់បានសម្លាប់មនុស្សពីរបីនាក់ «ដូច្នេះអ្នកដទៃមិនចោទថា ខ្ញុំចិត្តមិនដាច់...នៅពេលដែលចៅហ្វាយខ្ញុំប្រើឲ្យធ្វើដូច្នេះ ប្រសិនបើខ្ញុំមិនធ្វើ...ខ្ញុំមិនអាចបដិសេធបានទេ» ។ ដូចដែលកម្មាភិបាលខ្មែរក្រហមម្នាក់ទៀតបាននិយាយថា «បើយើងមិនវាយវៀតណាម គេសម្លាប់យើងដោយសារយើងមិនវាយជាមួយវៀតណាម» ។

របបខ្មែរក្រហមបន្តធ្វើអំពើឃោរឃៅនៅក្នុងប្រទេសដោយបង្កើតសង្គមមួយដែលមានតែការងារឥតស្រាកស្រាន្តកន្ទុះជីវជាតិ ការបង្អត់អាហារ ជំងឺ ការបែកបាក់គ្រួសារ ការបាត់បង់សាសនាព្រះពុទ្ធ ការបំបិទសិទ្ធិ ភាពឃោរឃៅ ភាពតក់ស្លុតនិងការស្លាប់រហូតដល់ខែមករា ឆ្នាំ១៩៧៩ នៅពេលដែលកងទ័ពវៀតណាមចូលមកកម្ពុជា ហើយបក្សកុម្មុយនីស្តកម្ពុជាក៏បានគេចខ្លួនបាត់ ។ នៅភ្នំពេញ វៀតណាមបានបង្កើតនូវរបបថ្មីមួយហៅថា សាធារណរដ្ឋប្រជាមានិតកម្ពុជាដែលគ្រប់គ្រងកម្ពុជារហូតដល់ឆ្នាំ១៩៨៩ ពេលវៀតណាមដកកងទ័ពចេញពីកម្ពុជា ។ ពេលនោះហើយដែលកម្ពុជាចាប់ផ្តើមជីវិតឡើងវិញ ប៉ុន្តែនេះជាការយល់ឃើញដែលពិបាកនឹងយកមកពិចារណាណាស់ នៅពេលដែលការស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្ហាញថាប្រជាជនកម្ពុជាចំនួន៨៩.៤២ភាគរយបានបាត់បង់សាច់ញាតិនៅក្នុងរបបខ្មែរក្រហម ។ យោក ឆាំង យុ នាយក មជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រៀបធៀបទៅនឹងកែវដែលបែកមួយដោយពន្យល់ថា គាត់និងជនរងគ្រោះដទៃទៀតគឺជា «មនុស្សដែលប៉ះពាល់ជំងឺផ្លូវចិត្តរស់នៅក្នុងសង្គមដែលបែកបាក់មួយ» ដូច្នេះ «ទោះបីជាផ្សារភ្ជាប់ឡើងវិញ...ក៏មិនអាចល្អដូចដើមវិញដែរ» ។ បន្ទាប់ពីការរំដោះរបស់វៀតណាម ប្រជាជនកម្ពុជាត្រូវប្រឈមមុខនឹងការបាត់បង់សាច់ញាតិនិងការប៉ះពាល់ផ្នែកផ្លូវចិត្ត ដោយបានឆ្លងកាត់ការរស់នៅប្រកបដោយការភ័យខ្លាច ហើយភាគ

ច្រើនបន្ទាស់នៅក្នុងភូមិជាមួយនឹងកម្មាភិបាលខ្មែរក្រហមទៀតផង ។ នៅតាមសហគមន៍ក្នុងស្រុកក៏ត្រូវប្រឈមមុខនឹងការជំរុញឲ្យមានការផ្សះផ្សានិងការស្តាបនាឡើងវិញនូវសាសនាព្រះពុទ្ធនិងជីវិតរស់នៅតាមស្រុកស្រែចម្ការ ។ ប្រជាជនកម្ពុជាទូទៅត្រូវប្រឈមមុខនឹងការស្លាប់ យ៉ាងហោចណាស់ចំនួនពីរលាននាក់និងការបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធជាច្រើនទៀត ។ ក្នុងនោះដែរ លោក អាឡិច ហ៊ីនតុន បានប្រាប់ថា «ការបំផ្លិចបំផ្លាញនូវទំនៀមទម្លាប់នៃការរស់នៅនិងការឲ្យតម្លៃនៅក្នុងសង្គមនៅក្នុងរបបខ្មែរក្រហម នោះប្រៀបបាននឹងការបាត់បង់នូវមូលដ្ឋានសំខាន់និងទំនៀមទម្លាប់សម្រាប់គ្រប់គ្រងសង្គមឲ្យល្អប្រសើរនិងបានបន្សល់ទុកនូវមនុស្សនិងសង្គមកម្ពុជាដោយគ្មានការរៀបចំឲ្យបានត្រឹមត្រូវ ដើម្បីដោះស្រាយរាល់ភាពតានតឹងនិងកង្វល់ទាំងឡាយឡើយ ។

**ការកំណត់និយមន័យនៃយុត្តិធម៌ និងការផ្សះផ្សា**

ដោយពិនិត្យទៅលើការប្រព្រឹត្តនូវបទឧក្រិដ្ឋដ៏ចម្លែកនិងយោរយៅ ជាពិសេសឧក្រិដ្ឋកម្មផ្សេងៗទៀតដែលប្រព្រឹត្តដោយខ្មែរក្រហម ការនាំមកនូវយុត្តិធម៌ដល់ជនរងគ្រោះ និងការផ្សះផ្សានៅក្នុងសង្គមកម្ពុជាគឺជាការពុះពារដ៏ធំមួយដែលមិនថាអ្នករស់រានមានជីវិតទេ គឺគិតថាវាមើលទៅមានការលំបាក ។ យុត្តិធម៌និងការផ្សះផ្សាត្រូវបានពន្យារពេលយ៉ាងយូរដោយសារភាពស្មុគស្មាញផ្នែកនយោបាយជាតិនិងអន្តរជាតិដែលប៉ះពាល់ដល់ប្រយោជន៍ប្រជាជនខ្មែរទាំងមូល ។ ប្រជាជនកម្ពុជានៅទូទាំងប្រទេសនៅតែទទួលរងនូវការឈឺចាប់និងខ្វះទៀតមិនទាន់សះស្បើយពីរបួសផ្លូវចិត្តនៃការរស់នៅក្រោមរបបកម្ពុជាធិបតេយ្យនៅឡើយ រដ្ឋាភិបាលនិងប្រព័ន្ធយុត្តិធម៌ត្រូវលិចបាត់ក្នុងសភាពពុករលួយ ។ ការស្រាវជ្រាវមួយដែលធ្វើឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្ស បានរកឃើញថា អ្នកដែលឆ្លើយតបនៅក្នុងការស្រាវជ្រាវនេះមិនមានទំនុកចិត្តចំពោះប្រព័ន្ធយុត្តិធម៌ក្នុងស្រុកទេពោលគឺតិចជាងពាក់កណ្តាលនៃអ្នកឆ្លើយតបទាំងនេះ (៤៤ភាគរយ) យល់ស្របថាប្រព័ន្ធយុត្តិធម៌កម្ពុជាគឺធ្វើឡើងដើម្បីបម្រើដល់មនុស្សគ្រប់រូប ហើយមាន៨២ភាគរយនិយាយថាការទៅចូលរួមក្នុងសវនាការតម្រូវឲ្យមានការចំណាយថវិកាច្រើន និងត្រូវមានការសូកប៉ាន់ដល់ចៅក្រម ឬប៉ូលិស(ដែលមាន៧៧ភាគរយនៃអ្នកឆ្លើយតប) ។ អន្តរជាតិយល់ថា កម្ពុជាបានធ្លាក់ចូលក្នុងនយោបាយសង្គ្រាមត្រជាក់ដ៏ស្មុគស្មាញ ហើយបច្ចុប្បន្ននៅតែជួបភាពស្មុគស្មាញក្នុងការបង្កើតនូវច្បាប់អន្តរជាតិដែលធ្លាប់មានរួចមកហើយ និងការដាក់ច្បាប់ទាំងនេះឲ្យអនុវត្ត ។ នៅពេលដែលវៀតណាមបានវាយរំលំខ្មែរក្រហមចេញពីអំណាចនោះ អង្គការសហប្រជាជាតិដែលជាអ្នកជ្រើសរើសតំណាងប្រទេសឲ្យឈរឈ្មោះនៅក្នុងសភាអន្តរជាតិបានបោះឆ្នោតឲ្យបក្សកុម្មុយនីស្តកម្ពុជានៃរបបកម្ពុជាប្រជាធិបតេយ្យបន្តកាន់កាប់កៅអីនៅសភាអន្តរជាតិដដែលដោយមានសន្លឹកឆ្នោត៦ទល់នឹង៣ ។ មន្ត្រីជាន់ខ្ពស់សហរដ្ឋអាមេរិកមួយរូបបានពន្យល់អំពីមូលហេតុនៃការសម្រេចចំពោះការគាំទ្របក្សកុម្មុយនីស្តកម្ពុជានេះថា «ការសម្រេចគឺស្ថិតនៅត្រង់សីលធម៌ឬច្បាប់អន្តរជាតិ ។ ការថ្លឹងថ្លែងនេះគឺលម្អៀងទៅលើច្បាប់ដើម្បីជាសុវត្ថិភាពដល់យើង» ។

យុត្តិធម៌សម្រាប់ជនរងគ្រោះអាចមានពីរប្រភេទផ្សេងគ្នាគឺ យុត្តិធម៌តាមផ្លូវច្បាប់ និងយុត្តិធម៌ក្រៅប្រព័ន្ធតុលាការ ។ យុត្តិធម៌តាមផ្លូវច្បាប់យកចិត្តទុកដាក់ចំពោះបញ្ហាច្បាប់ និងទម្រង់នៃការយល់ឃើញអំពីយុត្តិធម៌ ដោយការបង្ហាញដល់ជនរងគ្រោះឲ្យឃើញពីការពិន័យចំពោះកំហុសរបស់ជនដៃដល់ ។ យុត្តិធម៌ក្រៅប្រព័ន្ធតុលាការសង្កត់ធ្ងន់លើផ្លូវអារម្មណ៍ដែលទទួលបានយុត្តិធម៌ដែលកើតឡើងនៅក្នុងដំណើរការណ៍នៃការសុំខមាទោសនិងការផ្សះផ្សា ។ យុត្តិធម៌ក្រៅប្រព័ន្ធតុលាការនេះគឺ «យកជនរងគ្រោះជាគោលដៅសំខាន់ដោយផ្តល់ឱកាសឲ្យជនរងគ្រោះនិយាយរឿងរ៉ាវទាំងអស់ មុនពេលការសម្រេចវិនិច្ឆ័យទោស ។ បុគ្គលដែលធ្វើការវិនិច្ឆ័យចាំបាច់មិនមានភាពលម្អៀង ស្មោះត្រង់និងមានការតាំងចិត្ត» ។ យុត្តិធម៌ទាំងពីរប្រភេទនេះបង្ហាញអំពីធាតុពីរផ្សេងគ្នាក្នុងការផ្តល់យុត្តិធម៌ដល់ជនរងគ្រោះនៃរបបខ្មែរក្រហម ដោយបង្ហាញអំពីភាពចាំបាច់ទាំងផ្នែកច្បាប់និងការផ្សះផ្សាផ្លូវចិត្តចំពោះជនរងគ្រោះទាំងអស់ ។ យុត្តិធម៌ទាំងពីរនេះក៏មានទំនាក់ទំនងនឹងគ្នាយ៉ាងជិតស្និទ្ធ ប៉ុន្តែការស្វែងរកយុត្តិធម៌មួយអាចនឹងប៉ះពាល់ដល់ការស្វែងរកយុត្តិធម៌មួយទៀតដែរ ។

លក្ខខណ្ឌនេះ ពិតជាត្រឹមត្រូវចំពោះយុត្តិធម៌តាមផ្លូវច្បាប់

ដែលថាការធ្វើឲ្យមានកំហុសត្រូវតែកាត់ទោសដើម្បីរក្សាភាពអហិង្សាក្នុងសង្គមដែលមានកាតព្វកិច្ចក្នុងការផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ និងកំណត់រកជនដៃដល់ដើម្បីឲ្យទទួលខុសត្រូវតាមច្បាប់ចំពោះទង្វើរបស់ខ្លួន ។ ការយល់ឃើញបែបនេះបង្កការលំបាកដល់ភាពជាក់ស្តែងនៃការផ្តល់ «យុត្តិធម៌ក្រៅប្រព័ន្ធតុលាការ» ក្រោមហេតុផលពីរយ៉ាង ។ ទីមួយ វាសង្កត់ធ្ងន់លើការដាក់ទោសជនដៃដល់ ប៉ុន្តែ «មិនបានកំណត់ថាត្រូវកាត់ទោសដល់អ្នកនៅក្រោមបន្ទាប់យ៉ាងណាឡើយ» បញ្ហានេះហើយដែលរារាំងចំពោះការផ្សះផ្សាពីព្រោះជនដៃដល់ជាច្រើនដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មនៅក្នុងសម័យខ្មែរក្រហមក៏ត្រូវរងគ្រោះដោយសារអ្នកគ្រប់គ្រងរបស់ខ្លួនដែរ ហើយជនដៃដល់ទាំងនេះប្រព្រឹត្តបទឧក្រិដ្ឋនេះឡើងដោយសារការភ័យខ្លាចបាត់បង់ជីវិតប៉ុណ្ណោះ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងការសម្រេចចិត្តរបស់រដ្ឋាភិបាលសម្តេច ហ៊ុន សែន អាចដោះស្រាយបញ្ហានេះមួយភាគធំដោយកាត់ទោសតែថ្នាក់ដឹកនាំខ្មែរក្រហមប៉ុណ្ណោះ ។ លក្ខខណ្ឌនេះជួយសម្រួលដល់ការផ្សះផ្សាដោយមិនបានកំណត់ថាជនដៃដល់មានកំហុស ឬមិនមានកំហុសទេ ប៉ុន្តែទទួលយកភាពមិនច្បាស់លាស់ថា ស ឬ ខ្មៅ ជាភាពមិនច្បាស់លាស់នៃការប្រព្រឹត្តអំពើឧក្រិដ្ឋទាំងនោះ ។ ការស្រាវជ្រាវនៅសាកលវិទ្យាល័យ Berkeley ក៏បានបង្ហាញដែរថា «៦៧ភាគរយនៃអ្នកឆ្លើយតបជឿជាក់ថាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានជួយដល់ការផ្សះផ្សាជាតិដែរ» ដោយបានជួយបន្ថយការព្រួយបារម្ភអំពីការរារាំងការផ្សះផ្សាជាតិដោយសារតុលាការនេះ ។

ទីពីរ ដូចដែលលោក ម៉ាច អាំស៊ុត រៀបរាប់នៅក្នុង «យុត្តិធម៌ក្រៅប្រព័ន្ធតុលាការ ការអត់ឱនផ្នែកនយោបាយ និងលទ្ធភាពនៃការផ្សះផ្សាផ្នែកនយោបាយ» ថា «ដោយសារយុត្តិធម៌តាមផ្លូវច្បាប់កំណត់យកយុត្តិធម៌ជាលក្ខខណ្ឌដំបូងនៅក្នុងការផ្សះផ្សាជាតិនោះ វាធ្វើឲ្យខ្វះខាតនូវឱកាសក្នុងការលើកលែងទោស» ។ ដូច្នេះហើយការយកចិត្តទុកដាក់ចំពោះការដាក់ទោសអ្នកដែលបានប្រព្រឹត្តកំហុស យុត្តិធម៌តាមផ្លូវច្បាប់មិនបានយកចិត្តទុកដាក់ចំពោះជនរងគ្រោះនិងការស្តាបនាឡើងវិញនូវទំនាក់ទំនងសហគមន៍ឡើយ» ហើយក៏មិនខ្វល់ខ្វាយអំពីទំនាក់ទំនងសង្គមចំពោះជនរងគ្រោះទាំងឡាយដែលមានបំណងចង់ដើរចេញពីអតីតកាល ដើម្បីឆ្ពោះទៅរកអនាគតកាលនិងឃើញជនដៃដល់ទទួលកំហុស ដើម្បីទទួលបាននូវយុត្តិធម៌មួយ ។

ដូចដែលលោក ម៉ាច អាំស៊ុត បានរៀបរាប់ថា យុត្តិធម៌តាមរយៈការផ្សះផ្សា «សង្កត់ធ្ងន់ទៅលើការស្តារទំនាក់ទំនងឡើងវិញតាមរយៈការផ្សះផ្សាតាមការនិយាយការពិត ការសុំអភ័យទោស និងឈានទៅរកការលើកលែងទោស» ។ ដូចនេះការផ្សះផ្សាបានចាក់ឫសគល់យ៉ាងជ្រៅទៅក្នុងគំនិតលើកលែងទោសឲ្យគ្នាទៅវិញទៅមកដែលនេះធម្មតាមានឃើញតែក្នុងជំបូន្មានសាសនាប៉ុណ្ណោះ ហើយត្រូវបានគេចាត់ទុកជា «វិស័យថ្មីមួយក្នុងការសិក្សា» ។ លោក អាឡិច ហ៊ីនតុន បានទទួលស្គាល់ពីសារសំខាន់នៃការលើកលែងទោសដែលមានទំនាក់ទំនងជាមួយការផ្សះផ្សាជាច្រើនកម្រិតផ្សេងៗគ្នា ដោយលោកបានសរសេរថា «ការលើកលែងទោសគឺជាសញ្ញាណមួយដ៏សំខាន់នៅពេលដែលមនុស្សបានចាប់ផ្តើមស្វែងយល់អំពីអត្ថន័យនៃការផ្សះផ្សា និងការបង្រួបបង្រួមជាតិ ហើយរិះរកមធ្យោបាយដើម្បីសម្រេចបានគោលដៅទាំងនេះ» ។ នៅក្នុងការសិក្សាអំពីការលើកលែងទោសរបស់មជ្ឈ-មណ្ឌលឯកសារកម្ពុជា លោក អេង កុកថាយ ដែលជានាយកស្រាវជ្រាវ និងជានាយករងរបស់មជ្ឈមណ្ឌលបានទទួលយកនូវនិយមន័យនៃការលើកលែងទោសរបស់លោក អ៊ីនរ៉ាយថា «ការស្ម័គ្រចិត្តលះបង់កំហឹង ការមើលងាយមើលថោក និងអាកប្បកិរិយាអាក្រក់ទៅលើបុគ្គលដែលធ្វើឲ្យយើងទទួលរងអំពើអយុត្តិធម៌តែបែរជាផ្តល់នូវសេចក្តីមេត្តា សន្តោសប្រណី រហូតដល់សេចក្តីស្រឡាញ់ចំពោះបុគ្គលដែលពុំសមនឹងទទួល» ។ និយមន័យនេះស្របទៅតាមការរៀបរាប់របស់លោក អេមស្ទូតស៍ ក្នុងការសង្កត់ធ្ងន់ថា យុត្តិធម៌តាមរយៈការផ្សះផ្សាគឺជា «ការបោះបង់កត្តាផ្ទាល់ខ្លួនមួយចំនួនដែលរាំងស្ទះដល់ការអភិវឌ្ឍសង្គម ដូចជាកំហឹង ការពិបាកចិត្ត និង គំនុំជាដើម» ។

ដោយសារតែការលើកលែងទោសមានសារសំខាន់ជាខ្លាំងក្នុងដំណើរការ និងលក្ខខណ្ឌនៃការផ្សះផ្សា យើងគប្បីសិក្សាអំពីវិស័យដែលទ្រទ្រង់ការលើកលែងទោស ។ ក្នុងខណៈពេលដែលលោក អេង កុកថាយ បានរៀបរាប់អំពីទម្រង់ផ្សេងៗគ្នា

នៃការលើកលែងទោស និងអ្នកដែលនឹងផ្តល់ការលើកលែងទោសដល់ជនដៃដល់ លោក អេមស្ទូគស៍ បានញែកកត្តាទាំង៥ ដែលជំរុញឲ្យមានការលើកលែងទោសដើម្បីផ្តល់ភាពងាយស្រួលក្នុងការវិភាគរកវិធីសាស្ត្រដែលមានប្រសិទ្ធភាពបំផុតក្នុងការផ្តល់យុត្តិធម៌អន្តរកាលក្នុងមជ្ឈដ្ឋានកម្ពុជា ។ កត្តាទីមួយគឺការទទួលស្គាល់ការពិត ពោលគឺជនដៃដល់ត្រូវតែទទួលស្គាល់នូវរាល់អំពើរបស់ខ្លួន ។ កត្តាទីពីរគឺការបង្ហាញវិប្បដិសារី និង ការសោក-ស្តាយរបស់ជនដៃដល់ ។ លោក អេមស្ទូគស៍ បានពន្យល់ថា នេះតម្រូវឲ្យមានវត្តមានរបស់វិប្បដិសារី និងការដាក់ចិត្តកែខ្លួនឧទាហរណ៍ពេលដែលជនដៃដល់សន្យាថានឹងមិនប្រព្រឹត្តម្តងទៀត ។ កត្តាទីបីគឺការលះបង់គំនុំពីសំណាក់ជនរងគ្រោះ ។ កត្តាទីបួនគឺការយោគយល់គ្នាទៅវិញទៅមកដោយជនរងគ្រោះ និងជនដៃដល់ត្រូវតែមានការសន្តោសប្រណី និងការយោគយល់គ្នាទៅវិញទៅមក ហើយចាត់ទុកគ្នាជាមនុស្សដូចគ្នា ហើយគោរពគ្នាទៅវិញទៅមក ។ កត្តាចុងក្រោយគឺការសម្រាលទោសកំហុសតាមរយៈការកាត់បន្ថយទណ្ឌកម្ម ដោយសារជនរងគ្រោះទទួលយកវិប្បសារីរបស់ជនដៃដល់ ។ ថ្វីដ្បិតតែយុត្តិធម៌បែបការកាត់ទោសអាចសម្រេចបានកត្តាពីរដំបូង តែកត្តាបីចុងក្រោយនេះមានទំនាក់ទំនងយ៉ាងស្អិតរមួតជាមួយយុត្តិធម៌តាមរយៈផ្សះផ្សា ហើយមានសារសំខាន់យ៉ាងខ្លាំងក្នុងការបង្កើតការផ្សះផ្សា ។ យ៉ាងណាមិញ លោក លីនគុន បានពន្យល់ថា ការកាត់ទោសអាចផ្តល់ការផ្សះផ្សាទៅដល់សហគមន៍ដែលទទួលរងគ្រោះបានដែរ ។

ការផ្សះផ្សាកើតឡើងនៅក្នុងកម្រិតទាំងបីដែលមានទំនាក់ទំនងរវាងគ្នានឹងគ្នា គឺ កម្រិតថ្នាក់ជាតិ សហគមន៍ និង បុគ្គល ។ ថ្វីដ្បិតតែការផ្សះផ្សាជាបុគ្គល សហគមន៍ និងថ្នាក់ជាតិហាក់ដូចជាមានលក្ខណៈខុសស្រឡះពីគ្នា ប៉ុន្តែគំនិតជាទូទៅរបស់ប្រជាជនកម្ពុជាបានបង្ហាញឲ្យឃើញថា ទម្រង់នៃការផ្សះផ្សានីមួយៗពុំអាចសម្រេចទៅបានដោយគ្មានការចូលរួមរវាងគ្នាទៅវិញទៅមកទេ ។ សម្រាប់ប្រជាជនកម្ពុជា ការផ្សះផ្សា «គឺទទួលយករឿងអតីត ការចងចាំ និងអារម្មណ៍អវិជ្ជមានរបស់ខ្លួនឯង ប្រឹងប្រែងដើម្បីរស់នៅក្នុងនាមជាបុគ្គលផង និងជាសមាជិកម្នាក់ក្នុងសង្គមតែមួយផង ហើយបន្ទាប់មកសហការគ្នាដើម្បីសម្រេចបានអនាគតរួមមួយ» ។ ដូចនេះ ថ្វីដ្បិតតែបុគ្គលម្នាក់ៗត្រូវទទួលយករឿងអតីតរបស់ខ្លួនរួមរស់ជាមួយគ្នាក្នុងសហគមន៍ និងប្រទេសជាតិទាំងមូលប្រកបដោយសាមគ្គីភាព ហើយព្យាយាមកសាងអនាគតមួយរួមគ្នា តែដំហានទាំងនេះសុទ្ធតែត្រូវការផ្សះផ្សាក្នុងកម្រិតផ្សេងៗទៀតហើយមូលដ្ឋានគ្រឹះគឺស្ថិតនៅកម្រិតបុគ្គល ។ អនាគតនៃការផ្សះផ្សានៅប្រទេសកម្ពុជាមានភាពស្មុគស្មាញដោយសារតែមជ្ឈដ្ឋានសង្គម ព្រោះថា «ការផ្សះផ្សាក្នុងប្រទេសកម្ពុជាទាមទារឲ្យមានការចូលរួមរវាងបុគ្គលគ្រប់រូបនៅក្នុងគ្រួសារ និងសហគមន៍មិនថាជាអ្នករស់នៅតាមជនបទឬទីក្រុងដែលមានទំនាក់ទំនងនឹងគ្នាតិចបំផុត អ្នកធ្លាប់បម្រើជាកងពលនៅខាងសត្រូវ ជនរងគ្រោះ ជនដៃដល់មិនថាជាអ្នកចូលរួមដោយស្ម័គ្រចិត្ត អ្នកត្រូវបានគេបង្ខំឲ្យប្រព្រឹត្ត ឬអ្នកដែលឈរឱបដៃមើលដោយស្ងៀមស្ងាត់នោះទេ ។

ដោយសារតែខ្មែរក្រហមបានប្រព្រឹត្តអំពើរំលោភសិទ្ធិមនុស្សតាមលក្ខណៈជាប្រព័ន្ធ យុត្តិធម៌ទាំងឡាយដែលអាចផ្តល់ឲ្យដល់ជនរងគ្រោះអាចចាត់ទុកត្រឹមតែជាយុត្តិធម៌អន្តរកាលប៉ុណ្ណោះដែលជា «យុត្តិធម៌ជួយធ្វើកំណែទម្រង់សង្គមមួយក្រោយពីបានឆ្លងកាត់អំឡុងពេលមួយដែលមានការរំលោភសិទ្ធិមនុស្សកើតឡើងយ៉ាងទូលំទូលាយ» ។ មជ្ឈមណ្ឌលអន្តរជាតិដើម្បីយុត្តិធម៌អន្តរកាលបានឲ្យនិយមន័យ យុត្តិធម៌អន្តរកាលដោយកំណត់ថា យុត្តិធម៌ប្រភេទនេះមានគោលដៅស្វែងរក «ការទទួលស្គាល់សាវតារជនរងគ្រោះ ហើយនិងជំរុញឲ្យមានសន្តិភាព ការផ្សះផ្សានិងប្រជាធិបតេយ្យអាចសម្រេចបានយ៉ាងជោគជ័យ» ។ មជ្ឈមណ្ឌលអន្តរជាតិដើម្បីយុត្តិធម៌អន្តរកាលបានលើកឡើងនូវកិច្ចផ្តួចផ្តើម៦យ៉ាងដែលអាចបម្រើជាដំណោះស្រាយមូលដ្ឋានដើម្បីឈានទៅរកយុត្តិធម៌អន្តរកាល ដែលក្នុងនោះមាន៥ចំណុចមានលក្ខណៈសមស្របនឹងស្ថានភាពរបស់ប្រទេសកម្ពុជា ។ កិច្ចផ្តួចផ្តើមទាំងនោះរួមមាន ការកាត់ទោសចំពោះឧក្រិដ្ឋកម្ម គណៈកម្មការស្វែងរកការពិត ការរៀបចំកម្មវិធីសំណង កំណែទម្រង់ប្រព័ន្ធសន្តិសុខ និងកិច្ចប្រឹងប្រែងក្នុងការកត់ត្រាប្រវត្តិសាស្ត្រដើម្បីការចងចាំ ។

## ការព្យាយាមដើម្បីស្វែងរកយុត្តិធម៌នៅប្រទេសកម្ពុជា

កិច្ចផ្តួចផ្តើមមួយចំនួនដែលបានលើកឡើងខាងលើត្រូវ

បានសាកល្បងក្នុងប្រទេសកម្ពុជារួចមកហើយ ប៉ុន្តែមិនបានទទួលប្រសិទ្ធភាពដូចដែលបានរំពឹងទុកនោះទេ ។ នេះបណ្តាលមកពីជម្លោះរវាងផលប្រយោជន៍របស់សកម្មជនក្នុងប្រទេស និងសកម្មជនអន្តរជាតិដែលបានផ្តោតអារម្មណ៍លើកិច្ចការផ្ទៃក្នុងរបស់កម្ពុជាអស់ជាងបីទសវត្សរ៍មកហើយ នេះបានបង្កើតជាចំណោទនយោបាយដ៏ស្មុគស្មាញមួយដែលពុំទាន់អាចដោះស្រាយបាន ។ ឧទាហរណ៍ជាក់ស្តែង នៅខែសីហា ឆ្នាំ១៩៧៩ រដ្ឋាភិបាលរដ្ឋកម្ពុជាដែលមានការគាំទ្រពីប្រទេសវៀតណាមបានបង្កើត តុលាការបដិវត្តន៍ប្រជាជន ដើម្បីកាត់ទោស ប៉ុល ពត និង អៀង សារី ពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ ។ តុលាការមានសមាជិកក្រុមប្រឹក្សាតុលាការចំនួន១០រូប ហើយបានកាត់ទោសមេដឹកនាំខ្មែរក្រហមទាំងពីររូបនេះដោយកំបាំងមុខ និងបានស្តាប់សក្ខីកម្មអំពីបទឧក្រិដ្ឋដ៏ជាក់ស្តែងនិងរន្ធត់ ។ ប៉ុន្តែ ទោះបីជាតុលាការបានសម្រេចកាត់ទោសប្រហារជីវិត ប៉ុល ពត និង អៀង សារី ដោយសារឧក្រិដ្ឋកម្មដែលជនទាំងពីរបានប្រព្រឹត្តក៏ដោយ ក៏ការកាត់ទោសរបស់តុលាការនេះពុំត្រូវបានសហគមន៍អន្តរជាតិទទួលស្គាល់ទេ ។ លើសពីនេះទៅទៀត ដោយសារតែនៅពេលនោះ អៀង សារី នៅមានតួនាទីជាតំណាងពេញសិទ្ធិនៃរបបកម្ពុជាប្រជាធិបតេយ្យដែលមជ្ឈដ្ឋានអន្តរជាតិទទួលស្គាល់នៅឡើយ ដូច្នេះតុលាការនោះត្រូវបានគេចាត់ទុកជា «ឆាកសម្តែងកាត់ក្តី» មួយដែលធ្វើឲ្យគេមានអារម្មណ៍ថាផ្តល់នូវ «យុត្តិធម៌ថ្នាក់ទាបបែបនយោបាយ» ។ លើសពីនេះទៅទៀត ការចោទប្រកាន់អំពីភាពខ្វះយុត្តិធម៌ក្នុងការកាត់ក្តីបានធ្វើឲ្យភាពស្របច្បាប់នៃតុលាការនេះធ្លាក់ចុះមួយកម្រិតថែមទៀត ។ លោក ម៉ាក់ហ្គីរេ ធ្លាប់បានរំឭកនៅក្នុង «ការប្រឈមមុខនឹងសេចក្តីស្លាប់នៅកម្ពុជា» ថា សេចក្តីថ្លែងការណ៍ដំបូងរបស់មេធាវីការពារក្តីរបស់លោក ប៉ុល ពត និង អៀង សារី «បានធ្វើការការពារតិចតួចបំផុត តែបែរជាពោរពេញទៅដោយសម្តីអត្តនោម័តដែលគេបានដឹងឮដោយប្រយោល» ។ នេះបានបានបញ្ជាក់ថា តុលាការក្នុងស្រុករបស់រដ្ឋាភិបាលមិនត្រឹមតែមិនមានប្រសិទ្ធភាពក្នុងការជំរុញឲ្យមានការផ្សះផ្សាប៉ុណ្ណោះ តែថែមទាំងគ្រាន់តែចង់ឲ្យប្រជាជនទាំងអស់ «អភ័យទោស ហើយបំភ្លេច» រឿងអតីតកាលដោយពុំបានផ្តល់យុត្តិធម៌គ្រប់គ្រាន់ដល់ជនរងគ្រោះ ព្រោះជនដៃដល់ពុំបានទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មរបស់ពួកគេទាល់តែសោះ ។

កិច្ចខំប្រឹងប្រែងដែលគ្មានសុឆន្ទៈ និងមិនមានប្រសិទ្ធភាពរបស់រដ្ឋាភិបាលកម្ពុជាក្នុងការស្វែងរកយុត្តិធម៌ដល់ប្រជាជនបានបង្ហាញថា បញ្ហានិទ្ទណ្ឌភាពបានក្លាយជាឧបសគ្គចម្បងក្នុងការជំរុញឲ្យមានការផ្សះផ្សាទាំងបីកម្រិត ។ របាយការណ៍របស់អង្គការឃ្លាំមើលសិទ្ធិមនុស្សបានធ្វើកំណត់សម្គាល់ថា «បញ្ហានេះរាប់បញ្ចូលតាំងពីភាពបរាជ័យក្នុងការកាត់ទោសមេដឹកនាំខ្មែរក្រហមដូចជា អៀង សារី និង កែ ពក ដែលជាប់ទាក់ទងនឹងការសម្លាប់ប្រជាជនខ្មែររាប់លាននាក់ក្នុងទសវត្សរ៍៧០ រហូតដល់បទឧក្រិដ្ឋរាប់រយករណីដែលប្រព្រឹត្តឡើងដោយរដ្ឋាភិបាលបច្ចុប្បន្ន» ។

នេះបានបង្ហាញឲ្យឃើញថាវប្បធម៌និទ្ទណ្ឌភាពរបស់កម្ពុជាបានចាក់ឫសគល់ចូលយ៉ាងជ្រៅក្នុងប្រទេសនេះអស់រាប់សិបឆ្នាំទៅហើយ លើសពីនេះទៅទៀត បញ្ហានេះបានកើតឡើងក្នុងជួររាជរដ្ឋាភិបាលទៀតផង ។ ការអនុញ្ញាតឲ្យជនដៃដល់គេចផុតពីការកាត់ទោសជារឿងមួយធ្ងន់ធ្ងរជាទីបំផុត ដោយលោក អ៊ិចឆេសិន បានបញ្ជាក់ថា «ជំងឺនិទ្ទណ្ឌភាពបានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើទស្សនវិស័យរបស់ប្រជាជនកម្ពុជាក្នុងជីវភាពប្រចាំថ្ងៃ ហើយបានបណ្តាលឲ្យមានផលអាក្រក់ចំពោះការសម្របតាមសង្គមរបស់យុវជន» ។ បញ្ហានិទ្ទណ្ឌភាពនេះមិនត្រឹមតែជាឧបសគ្គចម្បងក្នុងការស្វែងរកយុត្តិធម៌ដល់ប្រទេសកម្ពុជាក្នុងនាពេលបីទសវត្សរ៍ចុងក្រោយប៉ុណ្ណោះ តែវាកាន់តែមានភាពធ្ងន់ធ្ងរជាងមុនដោយសារតែការចូលរួមរបស់សកម្មជនអន្តរជាតិ ។

ជាក់ស្តែង ថ្វីត្បិតតែមេដឹកនាំខ្មែរក្រហមបានប្រព្រឹត្តអំពើដ៏សាហាវឃោរឃៅក៏ដោយ ក៏អ្នកទាំងនោះមិនបាច់ទទួលខុសត្រូវចំពោះបទឧក្រិដ្ឋរបស់គេដែរ ព្រោះថាពួកគេទទួលបានការគាំទ្រ និងទទួលស្គាល់ពីសំណាក់អន្តរជាតិដោយត្រូវបានចាត់ទុកជា «រដ្ឋាភិបាលភៀសខ្លួនរបស់កម្ពុជាប្រជាធិបតេយ្យ និងជាអ្នកតំណាងពេញសិទ្ធិរបស់ខ្មែរក្រហម ហើយមានវត្តមាននៅក្នុងមហាសន្និបាតរបស់អង្គការសហប្រជាជាតិរហូតដល់ឆ្នាំ១៩៩១» ។ ដោយហេតុថាមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាត្រូវបានទទួលស្គាល់ដោយអង្គការសហប្រជាជាតិ ហើយជាប្រមុខរដ្ឋ «ពេញសិទ្ធិ» នៃប្រទេស

កម្ពុជា ដូចនេះសហគមន៍អន្តរជាតិទទួលយកពាក្យសម្តីក្រុមអ្នកទាំងនោះ ។ សហគមន៍អន្តរជាតិមិនត្រឹមតែមិននាំមេដឹកនាំមកកាត់ទោសពីបទប្រល័យពូជសាសន៍នោះទេ ថែមទាំងនៅក្នុងសន្និសីទកម្ពុជាអន្តរជាតិនៅទីក្រុងស្តុកខម មានប្រទេសអឺរ៉ុបមួយចំនួនតូចបានទទួលយកសេចក្តីអះអាងរបស់ អៀង សារី (រដ្ឋមន្ត្រីការបរទេសកម្ពុជាប្រជាធិបតេយ្យ) ទៀតផង ថាយួនទើបជាអ្នកដែលត្រូវទទួលខុសត្រូវចំពោះការស្លាប់របស់ប្រជាជនខ្មែរជាងមួយលាននាក់ ។

នៅចុងទសវត្សរ៍៨០ មានភាគីបួនបានចូលរួមក្នុងជម្លោះរបស់ប្រទេសកម្ពុជា ហើយភាគីខ្លះបានចងសម្ព័ន្ធគ្នាទៀតផង ។ ភាគីទាំងនោះរួមមាន ៖ សាធារណរដ្ឋប្រជាមានិតកម្ពុជាដែលគាំទ្រដោយប្រទេសវៀតណាម រណសិរ្សរួបរួមជាតិសម្រាប់ឯករាជ្យភាព អព្យាក្រឹត សន្តិភាព និងសហប្រតិបត្តិការក្នុងប្រទេសកម្ពុជា (ហ៊្វុនស៊ិនប៉ិច) ខ្មែរក្រហម រួមជាមួយរណសិរ្សរំដោះប្រជាពលរដ្ឋខ្មែរ ។ សន្ធិសញ្ញាទីក្រុងប៉ារីសដែលបានចុះហត្ថលេខានៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ បានផ្តល់យុត្តាធិការដល់អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា (អ៊ុនតាក់) ដើម្បីឃ្លាំមើលការអនុវត្តបទឈប់បាញ់ និងរៀបចំការបោះឆ្នោតបែបប្រជាធិបតេយ្យក្នុងប្រទេសកម្ពុជា ។ តាមប្រសាសន៍របស់លោក ហ៊ីនតុន ថ្វីដ្បិតតែសន្ធិសញ្ញាក្រុងប៉ារីសត្រូវបានបង្កើតឡើងដើម្បីបញ្ឈប់ឥទ្ធិពលអន្តរជាតិក្នុងប្រទេសនេះក៏ដោយ តែតាមកម្លាំងជំរុញនៅពីក្រោយហេតុការណ៍នេះគឺសម្ពាធមកពីសំណាក់អន្តរជាតិ មិនមែនដោយសារភាគីជម្លោះក្នុងស្រុកទាំងនោះចង់ស្វែងរកដំណោះស្រាយដើម្បីផ្សះផ្សាជាតិដោយខ្លួនឯងនោះទេ ។

ពេលនោះ ការស្វែងរកយុត្តិធម៌ជូនប្រជាជនកម្ពុជាស្ទើរតែជារឿងដែលមិនអាចប្រព្រឹត្តទៅបាន ។ លុះដល់ឆ្នាំ១៩៩៧ មហាសន្និបាតនៃអង្គការសហប្រជាជាតិទើបឯកភាពថា បទឧក្រិដ្ឋប្រល័យពូជសាសន៍ពិតជាបានកើតឡើងនៅក្នុងកម្ពុជាក្នុងទសវត្សរ៍៧០មែន ។ ការពិភាក្សាស្តីអំពីវិធីស្វែងរកយុត្តិធម៌ត្រូវបានលើកឡើងទាំងក្នុងលំដាប់ថ្នាក់ជាតិនិងអន្តរជាតិ ។ លោក ថូម៉ាស ហាមាប៊ើក្គ ដែលជាអ្នកតំណាងពិសេសសម្រាប់អគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជានាពេលនោះ បានលើកឡើងនូវគំនិតបង្កើតតុលាការបម្រុះ ព្រោះគាត់គិតថា «អ្នកជំនាញនៅក្នុងអង្គការសហប្រជាជាតិគប្បីផ្តល់ជំនួយដល់កម្ពុជាក្នុងការព្រាងច្បាប់ដែលសមស្របតាមបទដ្ឋានអន្តរជាតិ» ។ គំនិតនេះត្រូវបានទទួលយកថ្វីដ្បិតតែមានមន្ទិលសង្ស័យរបស់សមាជិកមួយចំនួនក្នុងជួរគណបក្សកាន់អំណាច ជាពិសេសសម្តេច ហ៊ុន សែន ដែលជានាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាបានប្រឆាំងទៅនឹងគំនិតនេះជាខ្លាំងក៏ដោយ ព្រោះគាត់គិតថានេះ «ប៉ះពាល់ដល់អធិបតេយ្យភាពរបស់កម្ពុជា» លើសពីនេះទៀត គោលបំណងរបស់កម្ពុជា «គប្បីជួយដល់ការស្តារប្រទេសជាតិឡើងវិញ តែមិនមែនកកូរកកាយឲ្យមានជម្លោះសាជាថ្មីនោះទេ» ។

បញ្ហាអំពើពុករលួយដែលកើតមានឡើងនៅកម្ពុជាត្រូវបានលើកឡើងជាពិសេសនៅពេលធ្វើការពិភាក្សាអំពីទម្រង់នៃតុលាការបម្រុះនេះ ។ ថ្វីដ្បិតតែមជ្ឈដ្ឋានក្នុងប្រទេស និងប្រទេសចិនបានដាក់សម្ពាធឲ្យបញ្ឈប់ការពិភាក្សានេះ សម្តេច ហ៊ុន សែន មិនមានភាពស្មោះត្រង់នៅក្នុងការដោះស្រាយរវាងសម្ពាធដែលមកពីភាគីទាំងពីរខាងលើ និងសហគមន៍អន្តរជាតិនោះទេ ។ នៅក្នុងកិច្ចប្រជុំគណៈកម្មាធិការមជ្ឈមបក្សប្រជាជនកម្ពុជាដែលជាគណបក្សកាន់អំណាចក្នុងខែកុម្ភៈ ឆ្នាំ២០០០ សម្តេច ហ៊ុន សែន បាន «ធានាម្តងហើយម្តងទៀតនៅចំពោះមុខសមាជិកជាន់ខ្ពស់ក្នុងបក្សថា មិនបាច់ព្រួយបារម្ភអំពីការកាត់ទោសនោះទេ ពីព្រោះគាត់បានផ្អាកដំណើរការនៃការចរចាចំនួនបីឆ្នាំ ហើយនឹងបន្តបង្អាក់បែបនេះរហូតដល់ពេលដែលជនជាប់ចោទសំខាន់ៗទាំងអស់ធ្វើមរណភាព» ។ អ្វីដែលសកម្មជនអន្តរជាតិដទៃទៀតចូលរួមក្នុងការចរចាតែមិនបានដឹង គឺប្រទេសចិនដែលជា «សម្ព័ន្ធមិត្តនិងបរិវាររបស់ខ្មែរក្រហមដែលបានទទួលស្គាល់អស់រយៈពេលរាប់សិបឆ្នាំ» បានបន្ថែមផ្តល់នូវជំនួយទៅភាគីដល់សម្តេច ហ៊ុន សែន ។ ជំនួយនេះធ្វើឡើងក្នុងបំណងដាក់សម្ពាធទៅលើសម្តេចនាយករដ្ឋមន្ត្រីដើម្បីឲ្យគាត់បង្អាក់ និងបង្វែរទិសដៅការកាត់ក្តី ។ ដូចនេះ សម្តេច ហ៊ុន សែន ត្រូវប្រឈមមុខនឹងកាលៈទេសៈពិបាកទាំងសងខាងព្រោះថាទោះបីជាគាត់យល់ព្រមទទួលសំណើរបស់អង្គការសហប្រជាជាតិដោយបើកចំហ ក៏ប្រទេសចិននៅតែមានសិទ្ធិបដិសេធចំពោះដំណោះស្រាយដែលផ្តល់ដោយតុលាការមួយនេះដែរ ។

ទោះជាយ៉ាងនេះក្តី នៅទីបញ្ចប់ គម្រោងដើម្បីនាំយក

មេដឹកនាំខ្មែរក្រហមមកកាត់ទោសត្រូវបានបង្កើតឡើង ។ កិច្ចព្រមព្រៀងមួយត្រូវបានធ្វើឡើងរវាងរដ្ឋាភិបាលដែលដឹកនាំដោយសម្តេច ហ៊ុន សែន និងអង្គការសហប្រជាជាតិក្រោយពីសហរដ្ឋអាមេរិកបានបង្ហាញនូវសំណើថ្មីមួយដែលអនុញ្ញាតឲ្យចៅក្រមខ្មែរមានសិទ្ធិភាគច្រើនក្នុងការសម្រេចចិត្ត ។ ថ្វីដ្បិតតែរដ្ឋសភាកម្ពុជាបានអនុម័តការព្រាងច្បាប់មួយដើម្បីធ្វើសច្ចានុម័តលើសំណើថ្មីនេះនៅថ្ងៃទី២ ខែមករា ឆ្នាំ២០០១ក៏ដោយ តែភាពតានតឹងរវាងរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិនៅតែមាន ។ ក្រោយពីកិច្ចប្រជុំគណៈរដ្ឋមន្ត្រីមួយសម្តេច ហ៊ុន សែន បានប្រកាសថា គាត់សង្ឃឹមថាអង្គការសហប្រជាជាតិអាចនៅឲ្យឆ្ងាយពីកិច្ចការផ្ទៃក្នុងរបស់កម្ពុជា ហើយ «ទុកឲ្យខ្មែរដោះស្រាយបញ្ហានេះដោយខ្លួនឯង» ។ អាកប្បកិរិយានេះបានបណ្តាលឲ្យសហគមន៍អន្តរជាតិមានចម្ងល់ថាតើសម្តេច ហ៊ុន សែន មានបំណង «ជំរុញឲ្យមានការកាត់ក្តីមួយដែលស្ថិតក្រោមការគ្រប់គ្រងយ៉ាងតឹងរ៉ឹងដើម្បីរក្សាកេរឈ្មោះខ្លួនឯងមុនពេលបោះឆ្នោតឃុំសង្កាត់ក្នុងឆ្នាំ២០០២ និងការបោះឆ្នោតសកលក្នុងឆ្នាំ២០០៣ ។ ហេតុដូចនេះហើយអង្គការសហប្រជាជាតិបានបង្ហាញនូវការព្រួយបារម្ភអំពី «ឯករាជ្យភាពមិនលម្អៀង និងវត្ថុវិស័យភាព» នៃតុលាការនេះ ហើយបញ្ឈប់ការចរចាជាមួយរដ្ឋាភិបាលកម្ពុជា ។ ថ្វីដ្បិតតែតុលាការចម្រុះត្រូវបានបោះបង់ចោល តែការចរចាររវាងសកម្មជនទាំងពីរ បានចាប់ផ្តើមសាជាថ្មីក្នុងខែធ្នូ ឆ្នាំ២០០២ ហើយកិច្ចព្រមព្រៀងចុងក្រោយត្រូវបានសម្រេចបានក្នុងថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៣ ។

### អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)

### អ.វ.ត.ក និង យុត្តិធម៌

កិច្ចព្រមព្រៀងថ្មីនេះបានបញ្ជាក់ជាលម្អិតក្នុងការចូលរួមរបស់សហគមន៍អន្តរជាតិ និងអង្គការសហប្រជាជាតិក្នុងការផ្តល់ជំនួយដល់ការកាត់ក្តីដែលនឹងរៀបចំឡើងក្នុងប្រព័ន្ធតុលាការកម្ពុជា ។ តុលាការនេះត្រូវបានដាក់ឈ្មោះថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រាប់ការកាត់ទោសបទឧក្រិដ្ឋដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យហៅកាត់អង្គជំនុំជម្រះវិសាមញ្ញ ឬ អ.វ.ត.ក ហើយធ្វើការកាត់ក្តីនៅក្នុងបន្ទប់សវនាការដ៏ធំមួយស្ថិតនៅក្នុងខណ្ឌដង្កោ ជាយក្រុងនៃរាជធានីភ្នំពេញ ។ យុត្តាធិការលើកម្មវត្ថុនៃបណ្តឹងរបស់អ.វ.ត.ក រួមមានអំពើប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើសន្ធិសញ្ញាទីក្រុងហ្សឺណែវក្នុងឆ្នាំ១៩៤៩ និងបទល្មើសផ្សេងៗទៀត ។ តុលាការនេះអាចកាត់ទោសចំពោះតែបទឧក្រិដ្ឋដែលបានប្រព្រឹត្តក្នុងប្រទេសកម្ពុជាក្នុងអំឡុងថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៩ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ហើយកំណត់ផ្តន្ទាទោសតែត្រឹមមេដឹកនាំជាន់ខ្ពស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះ «ដែលជាអ្នកដែលបានរៀបចំផែនការ ឬដាក់បញ្ជារួមជាមួយក្រុមជនដែលមានទំនួលខុសត្រូវខ្ពស់បំផុតចំពោះបទឧក្រិដ្ឋធ្ងន់ធ្ងរ» ។ តុលាការថែមទាំងមានបន្ទុកក្នុង «ការកំណត់ថាបុគ្គលណាជាមេដឹកនាំថ្នាក់ខ្ពស់ ហើយនរណាទទួលខុសត្រូវខ្ពស់បំផុតចំពោះបទឧក្រិដ្ឋដែលខ្មែរក្រហមបានប្រព្រឹត្តទៀតផង» ។

ការរៀបចំទម្រង់នៃតុលាការចម្រុះនេះមានគោលបំណងដើម្បីសម្របសម្រួលរវាងបំណងរបស់សហគមន៍អន្តរជាតិដែលចង់បង្កើនបទដ្ឋានច្បាប់អន្តរជាតិ និងរបស់កម្ពុជាដែលចង់មានម្ចាស់ការក្នុងការកាត់ទោសជនដៃដល់ទាំងនោះ ។ ដោយសារតែប្រព័ន្ធតុលាការនៅកម្ពុជាមានភាពខ្វះខាតក្នុងការបណ្តុះបណ្តាលខាងហិរញ្ញវត្ថុ និង ការវិវឌ្ឍ ការសម្របសម្រួលនេះអាចផ្តល់គុណប្រយោជន៍ដល់កម្ពុជាដោយចូលរួមជាជំនួយក្នុងការបង្កើតក្រមនីតិវិធីមានភាពសុក្រឹតតាមបទដ្ឋានអន្តរជាតិ ហើយលោកថាយយើ ក៏បានកត់សម្គាល់ផងដែរថា «ការពង្រឹងក្រមនីតិវិធីរបស់កម្ពុជាអាចមានឥទ្ធិពលហួសពីអ្វីដែលយើងបានគិតទុក គឺវាអាចបង្កើនទំនុកចិត្តរបស់អ្នកវិនិយោគអន្តរជាតិ ហើយនឹងជំរុញដល់ការអភិវឌ្ឍក្នុងវិស័យសេដ្ឋកិច្ច នេះក៏ជាអ្វីដែលកម្ពុជាចង់បានដែរ» ហេតុដូចនេះហើយតុលាការចម្រុះអាចធានានូវអធិបតេយ្យភាពរបស់ប្រទេសកម្ពុជាដែលធ្លាប់មានប្រវត្តិសាស្ត្រទទួលការគ្រប់គ្រង និង ឥទ្ធិពលពីប្រទេសដទៃ ក្នុងពេលតែមួយនេះដែរការចូលរួមរបស់ចៅក្រមនិងសុភាចារបុរសជាតិបរទេស «អាចជួយអភិវឌ្ឍប្រព័ន្ធតុលាការ ហើយនឹងធ្វើឲ្យការកាត់ក្តីនៅក្នុងប្រទេសនេះក្នុងថ្ងៃអនាគតអាចកាន់តែសមស្របតាមបទដ្ឋានអន្តរជាតិ» ។ លើសពីនេះទៅទៀត ការកាត់ទោសដែលធ្វើឡើងក្នុងប្រទេសនឹងត្រូវបានផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

ក្នុងស្រុក ហើយនឹងបង្កើនឥទ្ធិពលនៃការកាត់ក្តីនេះដោយសារមានការដឹងឮពីសំណាក់មហាជន ។ ទស្សនៈខាងលើនេះទទួលបានការគាំទ្រដោយការចុះសម្ភាសន៍ជាមួយបងប្អូនកសិករដែលរស់នៅតាមជនបទដាច់ស្រយាលមួយចំនួន ដោយកសិករជាច្រើនបានឆ្លើយតបថាធ្លាប់បានឮអំពីការកាត់ទោសខ្មែរក្រហមតាមវិទ្យុ ។

**អង្គជុំនំជម្រះនេះបែងចែកជាពីរកម្រិត** ៖ អង្គជុំនំជម្រះសាលាដំបូងដែលជាអ្នកចេញសាលក្រម និងអង្គបុរេជំនុំជម្រះដែលជាអ្នកទទួលដោះស្រាយបណ្តឹងឧទ្ធរណ៍ ។ អង្គជុំនំជម្រះសាលាដំបូងមានចៅក្រមប្រាំរូប ក្នុងនោះមានបីរូបជាចៅក្រមខ្មែរ និងពីររូបទៀតជាចៅក្រមអន្តរជាតិ ។ រីឯអង្គបុរេជំនុំជម្រះមានចៅក្រមប្រាំពីររូប ក្នុងនោះបួនរូបជាចៅក្រមខ្មែរ និងបីរូបជាចៅក្រមអន្តរជាតិ ។ ការសម្រេចផ្តន្ទាទោសមួយអាចធ្វើឡើងលុះត្រាតែតាមរយៈ «មតិភាគច្រើនលើសលុប» របស់ចៅក្រម ពោលគឺតម្រូវឲ្យមានការយល់ស្របពីចៅក្រមបួនរូបក្នុងចំណោមចៅក្រមប្រាំរូបនៃអង្គជុំនុំជម្រះសាលាដំបូងដើម្បីចេញសាលក្រម និងចៅក្រមប្រាំរូបក្នុងចំណោមចៅក្រមប្រាំពីររូបនៃអង្គបុរេជំនុំជម្រះដើម្បីវិនិច្ឆ័យបណ្តឹងឧទ្ធរណ៍ ។

នៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរជាលើកដំបូងក្នុងខែកក្កដា ឆ្នាំ២០០៧ កាំង ហ្កេកអ៊ាវ ហៅ (ឌុច) និង អៀង ធីរិទ្ធ ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ រីឯ នួន ជា, អៀង សារី, និង ខៀវ សំផន ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ។ នៅចុងឆ្នាំ២០០៧ ជនសង្ស័យទាំងប្រាំរូបត្រូវបានឃាត់ខ្លួនដាក់នៅក្នុង «មន្ទីរឃុំឃាំងបណ្តោះអាសន្ននៅនៃអ.វ.ត.ក.» ។ ទណ្ឌកម្មធ្ងន់ធ្ងរបំផុតដែលអង្គជុំនុំជម្រះនេះអាចដាក់ទោសគឺទោសដាក់គុកមួយជីវិត រីឯទោសស្រាលបំផុតគឺការដាក់គុករយៈពេលប្រាំឆ្នាំ ។ ទោសប្រហារជីវិតមិនត្រូវបានអនុវត្តនៅក្នុងអង្គជុំនំជម្រះនេះទេ ដោយសារតែតុលាការត្រូវគោរពទៅតាមយុត្តាធិការរបស់ប្រព័ន្ធយុត្តិធម៌នៃប្រទេសកម្ពុជាដែលចាត់ទុកទោសប្រហារជាអំពើមួយល្មើសនឹងច្បាប់រដ្ឋធម្មនុញ្ញ ។ ការកាត់ក្តីទាំងអស់សុទ្ធតែបើកចំហសម្រាប់សាធារណជន លើកលែងតែចំពោះអ្នកមានអាយុក្រោម ១៨ឆ្នាំ ឬ «ក្នុងករណីពិសេសដែលចៅក្រមសម្រេចថាមិនអាចមានវត្តមានរបស់សាធារណជនដើម្បីការពារអត្តសញ្ញាណរបស់សាក្សី ឬជនរងគ្រោះ» ។ ថ្វីដ្បិតតែតុលាការនេះមានគោលបំណងចម្បងស្វែងរកយុត្តិធម៌ជូនប្រជាជនកម្ពុជាក៏ដោយ ក៏គេបានរួមបញ្ចូលនូវគោលបំណងអប់រំអ្នកជំនាន់ក្រោយដើម្បីការពារកុំឲ្យមានអំពើបែបនេះកើតឡើងទៀតក្នុងពេលអនាគតដែរ ហើយពង្រឹងបទដ្ឋានច្បាប់ក្នុងប្រទេសកម្ពុជាដោយការកាត់ក្តីប្រកបដោយយុត្តិធម៌ និងតម្លាភាព ។ គោលបំណងបន្ទាប់បន្សំទាំងនេះត្រូវបានបង្កើតឡើងដោយសារតែមានជំនឿថា «តាមរយៈការគាំទ្រ និងសិក្សាអំពីយុត្តិធម៌ យើងអាចចូលរួមចំណែកក្នុងការស្តារសង្គមយើងឡើងវិញ» ។ ប៉ុន្តែគោលបំណងបន្ទាប់បន្សំរបស់ អ.វ.ត.ក. ទទួលការចោទប្រកាន់ច្រើនជាងគោលដៅស្វែងរកយុត្តិធម៌ទៅទៀត ។ សំណួរទីមួយដែលគេត្រូវចោទសួរថាតើ អ.វ.ត.ក. បានធ្វើកិច្ចការអ្វីខ្លះដើម្បីអប់រំយុវវ័យ ដោយហេតុថាជាក់ស្តែងកិច្ចផ្តួចផ្តើមភាគច្រើនហាក់ដូចជាត្រូវបានធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដូចជាការផ្តល់សៀវភៅមេរៀនអំពីកម្ពុជាប្រជាធិបតេយ្យសម្រាប់បង្រៀនដល់សិស្សានុសិស្សនៅតាមសាលានានាជាដើម ។ នៅក្នុងការសម្ភាសអំពីរបៀបដែលសិស្សស្វែងយល់អំពី ប៉ុល ពត សិស្សវិទ្យាល័យមានអាយុ២០ឆ្នាំម្នាក់ឈ្មោះ ស្រេង ស្រឿន បានឆ្លើយប្រាប់យ៉ាងស្រពេចស្រពិលថា គ្រូរបស់គាត់ធ្លាប់ប្រាប់គាត់ខ្លះអំពីរបបខ្មែរក្រហម ហើយគាត់ធ្លាប់ដឹងខ្លះទៀតពីអ្នកក្នុងភូមិជាមួយគ្នា តែគាត់មិនធ្លាប់បានរៀនអំពីរឿងនេះនៅក្នុងកម្មវិធីសិក្សារបស់សាលារៀនឡើយ ។ ទោះបីជា អ.វ.ត.ក. មិនបានធ្វើការផ្សព្វផ្សាយទូលំទូលាយមែន តែការកាត់ក្តីនេះនៅតែមានតម្លៃអប់រំតាមរយៈការផ្តល់ជាមេរៀនសីលធម៌មួយដល់អ្នកជំនាន់ក្រោយ រួមទាំងបញ្ឈប់វដ្តនៃអំពើហិង្សា ។ ប៉ុន្តែ ការផ្តល់មេរៀនសីលធម៌នេះអាចនឹងប្រឆាំងជាមួយសុក្រឹតភាពនៃយុត្តិធម៌បែបផ្សះផ្សាវិញ ដូចដែលលោកលីនតុន បានសង្កត់ធ្ងន់ថា «ពេលដែលការកាត់ទោសត្រូវបានប្រើប្រាស់ជាវេទិកាសម្រាប់លើកកម្ពស់សីលធម៌ ឬការអប់រំ នោះដំណើរការនេះនឹងលែងមានមុខងារក្នុងការវិនិច្ឆ័យទោសកំហុសទៀតហើយ» ។ **(នៅមានត)**

**ម៉ារីឌីត ឌីន និង ណាតាហ្សា បាច់**

# នួន ជា

## ប្រវត្តិរូបសង្ខេប

នួន ជា កើតនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩២៦ នៅភូមិវត្តគរ ឃុំវត្តគរ ស្រុកសង្កែ ខេត្តបាត់ដំបង។ នួន ជា បានចូលរៀនថ្នាក់វិទ្យាល័យ និងចូលរៀនច្បាប់នៅទីក្រុងបាងកក ដែលនៅទីនោះ នួន ជា បានចូលរួមក្នុងបក្សកុម្មុយនិស្តថៃ។ នៅពេលវិលត្រឡប់មកកម្ពុជាវិញនៅឆ្នាំ១៩៥០ នួន ជា បានចូលរួមក្នុងបក្សកុម្មុយនិស្តក្នុងស្រុក ហើយនៅក្នុងឆ្នាំ១៩៦០ នួន ជា បានក្លាយទៅជាសមាជិកជាន់ខ្ពស់មួយរូប ។

នួន ជា គឺជាមេដឹកនាំជាន់ខ្ពស់មួយរូបនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយបានកាន់តំណែងដ៏សំខាន់រួមមានតំណែងជាប្រធានសភាប្រជាជន និងនាយករដ្ឋមន្ត្រីស្តីទី។ នួន ជា គឺជាសមាជិកទី២ ដែលមានអំណាចបំផុតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បន្ទាប់ពី ប៉ុល ពត។ មានការជឿជាក់ថា នួន ជា ធ្លាប់ទទួលបន្ទុកគ្រប់គ្រងលើមន្ទីរសន្តិសុខរបស់កម្ពុជាប្រជាធិបតេយ្យរាប់ទាំងមន្ទីរស-២១ (ទួលស្លែង) ។ ក្រោយមរណៈភាពរបស់ ប៉ុល ពត នៅឆ្នាំ១៩៩៨ នួន ជា បានចាប់ផ្តើមការពិភាក្សាជាមួយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលជាអ្នកបញ្ចុះបញ្ចូលឲ្យ នួន ជា ចាកចេញពីខ្មែរក្រហម ។

## បទឧក្រិដ្ឋដែលចោទប្រកាន់

នៅឯអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នួន ជា ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋអន្តរជាតិធ្ងន់ធ្ងរដែលក្នុងនោះរួមមាន «អំពើប្រល័យពូជសាសន៍» «ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ» (មនុស្សឃាត, ការធ្វើទារុណកម្ម, ការដាក់ឃុំឃាំង, ការធ្វើទុក្ខបុកម្នេញ, ការសម្លាប់បំផុតពូជ, ការនិរទេស, ការជម្លៀសប្រជាពលរដ្ឋដោយបង្ខំ, ការដាក់ជាទាសករ, និងអំពើមនុស្សធម៌ដទៃទៀត) ព្រមទាំងឧក្រិដ្ឋកម្មសង្គ្រាម (ការសម្លាប់ដោយចេតនា, ការធ្វើទារុណកម្ម, ការប្រព្រឹត្តអមនុស្សធម៌, ការបង្កព្យសនកម្មធ្ងន់ធ្ងរ ឬការធ្វើឲ្យឈឺចាប់ខ្លាំងដោយចេតនាដល់រាងកាយនិងសុខភាព, ការដកហូតដោយចេតនានូវសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌, ការនិរទេស ឬជម្លៀសដោយបង្ខំ ឬការបង្ខាំងជនស៊ីវិលដោយខុសច្បាប់) ។ នួន ជា ក៏ត្រូវបានចោទប្រកាន់ថែមទៀតអំពីបទមនុស្សឃាតដោយចេតនា, ការធ្វើទារុណកម្ម, និងការធ្វើទុក្ខបុកម្នេញលើសាសនាក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ។ នួន ជា ត្រូវបានចាប់ខ្លួននៅឆ្នាំ២០០៧ ហើយត្រូវបានឃុំខ្លួនបណ្តោះអាសន្នចាប់តាំងពីពេលនោះមក ។

នួន ជា កំពុងត្រូវបានការពារដោយមេធាវីកម្ពុជាម្នាក់ឈ្មោះ សុន អរុណ ដែលមានបទពិសោធន៍ក្នុងការការពារជនកម្ពុជាដែលត្រូវបានចោទពីបទឧក្រិដ្ឋធ្ងន់ធ្ងរ ព្រមជាមួយមេធាវីអន្តរជាតិ២នាក់ផ្សេងទៀតដែលម្នាក់មកពីប្រទេសហូឡង់ដ៏ឈ្មោះ ម៉ាយខើល ផែសមែន និងម្នាក់ទៀតឈ្មោះ វិកទ័រ កូបពេ ។

សម្រាប់ព័ត៌មានបន្ថែមទាក់ទិននឹង នួន ជា សូមមើលលើចំណុចព័ត៌មានទាក់ទងនឹងសំណុំរឿង :

*www.eccc.gov.kh/ khmer/case002.aspx*

## ឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតាមគេហទំព័រ

ដើម្បីឲ្យសាធារណជនទូទៅមានលទ្ធិភាពក្នុងការតាមដានមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជា គេហទំព័រ *www.cambodiatribunal.org* ត្រូវបានបង្កើតឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងសាលាច្បាប់នៃសាកលវិទ្យាល័យណតវើស្ទើន សហរដ្ឋអាមេរិក និងក្រោមសហប្រត្តិបត្តិការជាមួយ *Illinois Holocaust Museum and Educational* Center ។ មុននិងផ្សព្វផ្សាយគេហទំព័រនេះ ត្រូវបានត្រួតពិនិត្យដោយសាស្ត្រាចារ្យច្បាប់ *David Scheffer* អតីតឯកអគ្គរដ្ឋទូតគោចរណ៍របស់សហរដ្ឋអាមេរិកទទួលបន្ទុកកិច្ចការឧក្រិដ្ឋកម្មសង្គ្រាមកាលពីជំនាន់រដ្ឋការប្រធានាធិបតី ប៊ីល គ្លីនតុន និងលោក ឆាំង យុ នាយក មជ្ឈមណ្ឌលឯកសារកម្ពុជា ។



# អៀង ធីរិទ្ធ

## ប្រវត្តិរូបសង្ខេប

អៀង ធីរិទ្ធ កើតនៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៣២ នៅសង្កាត់លេខ៥ ក្រុងភ្នំពេញ ។ អៀង ធីរិទ្ធ បានចូលរៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិនៅទីក្រុងភ្នំពេញ ហើយបន្ទាប់មកទទួលបានសញ្ញាបត្រអក្សរសាស្ត្រអង់គ្លេស នៅប្រទេសបារាំង ។ អៀង ធីរិទ្ធ បានរៀបការជាមួយ អៀង សារី នៅឆ្នាំ១៩៥១ ។ បងស្រីរបស់ខ្លួនឈ្មោះ ខៀវ ប៉ុណ្ណារី បានរៀបការជាមួយ ប៉ុល ពត ។ អៀង ធីរិទ្ធ បានវិលត្រឡប់មកប្រទេសកម្ពុជាវិញនៅឆ្នាំ១៩៥៧ ហើយធ្វើការជាគ្រូបង្រៀនភាសាអង់គ្លេស ។

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អៀង ធីរិទ្ធ គឺសមាជិកជាន់ខ្ពស់ម្នាក់នៅក្នុងជួររដ្ឋាភិបាល ហើយបានកាន់មុខតំណែងជារដ្ឋមន្ត្រីសង្គមកិច្ច និងសុខាភិបាល ។ អៀង ធីរិទ្ធ ត្រូវបានបញ្ជូនឲ្យទៅស៊ើបអង្កេត និងរាយការណ៍ពីបញ្ហាសុខាភិបាលមួយចំនួននៅភូមិភាគឧត្តរ ហើយទំនងជាបានដឹងថា ប្រជាជនកម្ពុជាជាច្រើននាក់កំពុងអត់ឃ្លានក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។ អៀង ធីរិទ្ធ ក៏ត្រូវបានចោទពីបទជាប់ពាក់ព័ន្ធនឹងការចាប់ខ្លួន និងសម្លាប់សមាជិកមកពីក្រសួងសង្គមកិច្ចនិងសុខាភិបាល ។ នៅឆ្នាំ១៩៩៦ អៀង ធីរិទ្ធ និង អៀង សារី បានចាកចេញពីខ្មែរក្រហម ។

## បទឧក្រិដ្ឋដែលចោទប្រកាន់

នៅឯអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អៀង ធីរិទ្ធ ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋអន្តរជាតិ ដែលក្នុងនោះរួមមាន «អំពើប្រល័យពូជសាសន៍» «ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ» (មនុស្សឃាត, ការដាក់ឃុំឃាំង, ការធ្វើទុក្ខបុកម្នេញ, ការសម្លាប់បំផុតពូជ និងអំពើមនុស្សធម៌ដទៃទៀត) ព្រមទាំងឧក្រិដ្ឋកម្មសង្គ្រាម ។ អៀង ធីរិទ្ធ ក៏ត្រូវបានចោទប្រកាន់ថែមទៀតពីបទមនុស្សឃាតដោយចេតនា, ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញលើសាសនាក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចាប់ខ្លួន អៀង ធីរិទ្ធ នៅឆ្នាំ២០០៧ ហើយដាក់ឃុំខ្លួនបណ្ដោះអាសន្នចាប់តាំងពីពេលនោះមក ។

អៀង ធីរិទ្ធ កំពុងត្រូវបានការពារដោយមេធាវីកម្ពុជាម្នាក់ឈ្មោះ ផាត់ ពៅស៊ាង ដែលគឺជាសាស្ត្រាចារ្យម្នាក់នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងសេដ្ឋកិច្ច ព្រមជាមួយនឹងមេធាវីអង់គ្លេសម្នាក់ឈ្មោះ ដាយអាណា អែលលីស ដែលមានបទពិសោធន៍នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិជាច្រើន ។

សម្រាប់ព័ត៌មានបន្ថែមទាក់ទិននឹង អៀង ធីរិទ្ធ សូមមើលលើចំណុចព័ត៌មានទាក់ទងនឹងសំណុំរឿង ៖

*www.eccc.gov.kh/khmer/case_iengthirith.aspx*

## ដំណើរទស្សនកិច្ចដើម្បីស្វែងយល់ពីការកាត់ទោសមេដឹកនាំខ្មែរក្រហម

មកទល់នឹងពេលបច្ចុប្បន្ន គម្រោងឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញប្រជាជនមកចូលរួមស្វែងយល់ក្នុងដំណើរការស្វែងរកយុត្តិធម៌នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចំនួនប្រមាណ៦៩០០នាក់រួចមកហើយ ។ នៅដើមឆ្នាំ២០០៩ គម្រោងឯកសាររស់បានឈានមួយជំហានទៀតក្នុងការផ្ដល់ឱកាសឲ្យប្រជាជនចូលរួមដោយផ្ទាល់នៅក្នុងដំណើរការកាត់ក្ដីមេដឹកនាំខ្មែរក្រហម ។ នៅរៀងរាល់ការបើកសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហម មជ្ឈមណ្ឌលឯកសារកម្ពុជានឹងអញ្ជើញអ្នកតំណាងមកពីស្រុកភូមិនានាទូទាំងប្រទេសមកឃ្លាំមើលដំណើរការនេះ ។ បន្ថែមពីលើការចូលរួមស្ដាប់សវនាការ អ្នកតំណាងទាំងនោះនឹងបានចូលរួមក្នុងវគ្គបំពាក់បំប៉នដើម្បីទទួលចំណេះដឹងផ្សេងៗទាក់ទងទៅនឹងទ្រង់ទ្រាយនៃតុលាការច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម តួនាទីនៃសហព្រះរាជអាជ្ញាចៅក្រម និងចៅក្រមស៊ើបអង្កេត ភាពខុសគ្នានៃទម្រង់សវនាការ ព្រមទាំងទស្សនាខ្សែភាពយន្តឯកសារទាក់ទងទៅនឹងរបបខ្មែរក្រហម ។

អាស្រ័យហេតុនេះ ប្រសិនបើអស់លោកអ្នកមានបំណងចូលរួមក្នុងកម្មវិធីអង្កេតមើលសវនាការឬដំណើរទស្សនកិច្ចដើម្បីស្វែងយល់ពីការកាត់ក្ដីមេដឹកនាំខ្មែរក្រហម សូមទាក់ទង ស៊ីរិ សាវីណា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬ ០១២ ៦៨៨ ០៤៦ ។ **សូមអរគុណ**



# អៀង សារី

## ប្រវត្តិរូបសង្ខេប

អៀង សារី កើតនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩២៥ នៅភូមិលឿងវ៉ា ឃុំលឿងវ៉ា ខេត្តត្រាវិញ ប្រទេសវៀតណាម ។ អៀង សារី បានរៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិនៅទីក្រុងភ្នំពេញ ហើយបន្ទាប់មកបានបន្តការសិក្សានៅប្រទេសបារាំង ។ អៀង សារី បានវិលត្រឡប់មកប្រទេសកម្ពុជាវិញ ហើយក្លាយទៅជាគ្រូបង្រៀនប្រវត្តិវិទ្យានៅឆ្នាំ១៩៥៧ ។ អៀង សារី ទំនងជាបានចូលរួមជាមួយខ្មែរក្រហមនៅឆ្នាំ១៩៦៣ ។

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អៀង សារី គឺសមាជិកជាន់ខ្ពស់ម្នាក់នៅក្នុងជួររដ្ឋាភិបាល ហើយបានកាន់មុខតំណែងជាឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីការបរទេស ។ អៀង សារី ត្រូវបានជឿជាក់ថាបានដើរតួយ៉ាងសំខាន់ក្នុងការបញ្ជូនសមាជិកមួយចំនួនដែលបំរើការនៅក្នុងក្រសួងការបរទេសយកទៅដាក់ឃុំឃាំងនៅមន្ទីរស-២១ (ទួលស្លែង) ដែលនៅទីនោះ ជនដែលត្រូវបានបញ្ជូនទៅទាំងអម្បាលមានបានទទួលរងនូវការសួរចម្លើយនិងការសម្លាប់ផ្តាច់ជីវិត ។

ក្រោយពេលដែលរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យដួលរលំនៅឆ្នាំ១៩៧៩ អៀង សារី ត្រូវបានកាត់ឲ្យជាប់ទោសដោយកំបាំងមុខ ពីបទ «ប្រល័យពូជសាសន៍» ហើយសម្រេចឲ្យប្រហារជីវិតដោយតុលាការប្រជាជនបដិវត្តន៍កម្ពុជា ។ នៅឆ្នាំ១៩៩៦ អៀង សារី បានចាកចេញពីខ្មែរក្រហមរួមនិងអ្នកដែលនៅក្រោមបង្គាប់របស់ខ្លួនរាប់ពាន់នាក់ដើម្បីជាថ្នូរនឹងការប្រទានការអត់ឱនទោសពីសំណាក់ព្រះមហាក្សត្រ លើការសម្រេចទោសប្រហារជីវិតនិងការសន្យាថា ខ្លួននឹងមិនត្រូវបានផ្តន្ទាទោសក្រោមច្បាប់ឆ្នាំ១៩៩៤ ដែលបានចែងថា របនាសមូនអង្គការរបស់ខ្មែរក្រហមគឺមានលក្ខណៈមិនស្របច្បាប់ ។ នៅពេលនោះ អៀង សារី បានផ្លាស់មកនៅទីក្រុងភ្នំពេញជាមួយប្រពន្ធរបស់ខ្លួនឈ្មោះ អៀង ធីរិទ្ធ ដែលនឹងត្រូវធ្វើការកាត់ទោសនៅក្នុងសំណុំរឿងលេខ០០២ ។

## បទឧក្រិដ្ឋដែលចោទប្រកាន់

នៅឯអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អៀង សារី ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋអន្តរជាតិធ្ងន់ធ្ងរដែលក្នុងនោះរួមមាន «អំពើប្រល័យពូជសាសន៍» «ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ» (មនុស្សឃាត, ការដាក់ឃុំឃាំង, ការធ្វើទុក្ខបុកម្នេញ, ការសម្លាប់បំផុតពូជ និងអំពើមនុស្សធម៌ដទៃទៀត) ព្រមទាំងឧក្រិដ្ឋកម្មសង្គ្រាម (មនុស្សឃាតដោយចេតនា, ការបង្កព្យសនកម្មធ្ងន់ធ្ងរ ឬការធ្វើឲ្យឈឺចាប់ខ្លាំង ដោយចេតនាដល់រាងកាយនិងសុខភាព, ការដកហូតដោយចេតនាពីអ្នកទោសសង្គ្រាម និងជនស៊ីវិលនូវសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌, ការនិរទេស ឬជម្លៀស ឬការបង្ខាំងជនស៊ីវិលដោយខុសច្បាប់) ។ អៀង សារី ក៏ត្រូវបានចោទប្រកាន់ថែមទៀតអំពីបទមនុស្សឃាតដោយចេតនា, ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញលើសាសនាក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចាប់ខ្លួន អៀង សារី នៅឆ្នាំ២០០៧ ហើយដាក់ឃុំខ្លួនបណ្តោះអាសន្នចាប់តាំងពីពេលនោះមក ។ អៀង សារី កំពុងត្រូវបានការពារដោយមេធាវីកម្ពុជាម្នាក់ឈ្មោះ អាង ឧត្តម ដែលមានបទពិសោធន៍ក្នុងការការពារជនកម្ពុជាដែលត្រូវបានចោទពីបទឧក្រិដ្ឋផ្សេងៗព្រមជាមួយមេធាវីអាមេរិកាំងម្នាក់ឈ្មោះ ម៉ាយខើល ខាណឺវ៉ាស ដែលមានបទពិសោធន៍ការពារក្តីឲ្យជនដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋអន្តរជាតិ ។

សម្រាប់ព័ត៌មានបន្ថែមទាក់ទិននឹង អៀង សារី សូមមើលលើចំណុចព័ត៌មានទាក់ទងនឹងសំណុំរឿង :

*www.eccc.gov.kh/khmer/case_iengsary.aspx*

### អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ *http://dccam.org/Projects/Magazines/Magazine_Searching.htm* ។ ព័ត៌មានបន្ថែម សូមទាក់ទង ញាណ សុជាតិ ទូរស័ព្ទលេខ ០១៦ ៨៧៦ ៦៩២ ឬ ០២៣ ២១១ ៨៧៥ ។

**សូមអរគុណ!**



# ខៀវ សំផន

## ប្រវត្តិរូបសង្ខេប

*ខៀវ សំផន កើតនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៣១ នៅខេត្តស្វាយរៀង។ ខៀវ សំផន បានធ្វើដំណើរទៅសិក្សានៅប្រទេសបារាំងនៅឆ្នាំ១៩៥៩ ។ នៅឆ្នាំ១៩៦២ ខៀវ សំផន ត្រូវបានតែងតាំងជារដ្ឋមន្ត្រីពាណិជ្ជកម្ម នៅក្នុងរាជការរបស់សម្តេចព្រះ នរោត្តម សីហនុ។ ដោយមានការគំរាមរកចាប់ខ្លួន ខៀវ សំផន បានរត់ទៅលាក់ខ្លួនក្នុងឆ្នាំ១៩៦៧ ហើយនៅដើមទសវត្សរ៍ឆ្នាំ១៩៧០ ខៀវ សំផន បានចូលរួមជាមួយខ្មែរក្រហម ។*

*ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន បានកាន់មុខតំណែងជាប្រមុខរដ្ឋ (ប្រធានគណៈប្រធានរដ្ឋ) ។ បន្ទាប់ពី ប៉ុល ពត បានចូលនិវត្តន៍ពីតំណែងប្រធានក្រុមខ្មែរក្រហមនៅឆ្នាំ១៩៨៧ ខៀវ សំផន បានក្លាយជាប្រធានក្រុមខ្មែរក្រហម និងតំណាងឲ្យអង្គការចាត់តាំងនៅឯសន្និសីទសន្តិភាពទីក្រុងបារីស ឆ្នាំ១៩៨៩ ។ ក្រោយពីមរណៈភាពរបស់ ប៉ុល ពត ក្នុងឆ្នាំ១៩៩៨ ខៀវ សំផន បានចាកចេញពីខ្មែរក្រហម ។*

## បទឧក្រិដ្ឋដែលចោទប្រកាន់

*នៅឯអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ខៀវ សំផន ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋអន្តរជាតិធ្ងន់ធ្ងរដែលក្នុងនោះរួមមាន «អំពើប្រល័យពូជសាសន៍» «ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ» (អំពើមនុស្សឃាត, ការដាក់ឃុំឃាំង, ការធ្វើទុក្ខបុកម្នេញ, ការសម្លាប់បំផុតពូជ និងអំពើមនុស្សធម៌ដទៃទៀត) ព្រមទាំងឧក្រិដ្ឋកម្មសង្គ្រាម (អំពើមនុស្សឃាតដោយចេតនា, ការបង្កព្យសនកម្មធ្ងន់ធ្ងរ ឬការធ្វើឲ្យឈឺចាប់ខ្លាំងដោយចេតនាដល់រាងកាយ និងសុខភាព, ការដកហូតដោយចេតនាពីអ្នកទោសសង្គ្រាម និងជនស៊ីវិលនូវសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌, ការនិរទេស ឬជម្លៀស ឬការបង្ខាំងជនស៊ីវិលដោយខុសច្បាប់) ។ ខៀវ សំផន ក៏ត្រូវបានចោទប្រកាន់ថែមទៀតពីបទមនុស្សឃាតដោយចេតនា, ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញលើសាសនា ក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចាប់ខ្លួន ខៀវ សំផន នៅឆ្នាំ២០០៧ ហើយដាក់ឃុំខ្លួនបណ្តោះអាសន្នចាប់តាំងពីពេលនោះមក ។*

*ខៀវ សំផន កំពុងត្រូវបានការពារដោយមេធាវីកម្ពុជាម្នាក់ឈ្មោះ ស សូវ៉ាន ដែលពីមុនធ្លាប់ធ្វើជាទីប្រឹក្សាច្បាប់ឲ្យរដ្ឋសភាជាតិកម្ពុជា និងជាអ្នកជំនាញនៅក្នុងក្រសួងយុត្តិធម៌ ព្រមជាមួយនឹងមេធាវីបារាំងឈ្មោះ ហ្សាក វែរហ្សែស ដែលធ្លាប់ការពារឲ្យកូនក្តីជាច្រើនដែលទទួលបទចោទពីឧក្រិដ្ឋកម្មទាក់ទិននឹងភេរវកម្ម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។*

*សម្រាប់ព័ត៌មានបន្ថែមទាក់ទិននឹង ខៀវ សំផន សូមមើលលើចំណុចព័ត៌មានទាក់ទងនឹងសំណុំរឿង :*

*www.eccc.gov.kh/khmer/case_khieusamphan.aspx*

---

***កំណត់សម្គាល់ :*** *នៅក្នុងសវនាការរបស់អង្គបុរេជំនុំជម្រះ ខៀវ សំផន បានប្រាប់តុលាការថា ខ្លួនកើតនៅឃុំរំចេក ស្រុករំដួល ខេត្តស្វាយរៀង។ ផ្ទុយទៅវិញ បើយោងតាមអ្នកស្រុករស់នៅស្រុករំដួល គឺគ្មានឃុំណាដែលដាក់ឈ្មោះថា រំចេក ឡើយ ក៏បុន្តែមានឃុំចំនួន២ ដែលមានឈ្មោះ ចេក និងស្វាយចេក ។*

### កម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

*វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរនឹងធ្វើការចាក់ផ្សាយកម្មវិធីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» ដែលនិពន្ធដោយលោក ឌី ខាំបូលី ដែលអ្នកទាំងអស់គ្នាអាចស្តាប់ថតចម្លងនិងអានសាច់រឿងដែលមាននៅក្នុងសៀវភៅនេះតាមរយៈគេហទំព័រ* http://www.voanews.com/ khmer/democratic-kampuchea.cfm *របស់វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរ ។*

**មជ្ឈមណ្ឌលឯកសារកម្ពុជា**



# រឿងពិតរបស់គ្រួសារខ្ញុំ

ខ្ញុំបាទឈ្មោះ ចេង ហុង ហៅ តុលា កើតនៅឆ្នាំ១៩៧៥ ហើយមានបងប្អូនប្រុសចំនួនបីនាក់និងមានស្រុកកំណើតនៅភូមិខ្សាយ ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង ក្នុងតំបន់៣ ស្ថិតនៅភូមិភាគពាយ័ព្យ ដែលមានឪពុកឈ្មោះ ងិន ជឿន និងម្តាយឈ្មោះ ញូង គីមអ៊ី ។ ឪពុករបស់ខ្ញុំបានទទួលមរណភាពនៅឆ្នាំ១៩៨៣ ដោយសារជួបប្រទះនឹងគ្រោះថ្នាក់ចរាចរមួយ ដោយបែងន្យនៅក្នុងដំណើរជិះនូញមួយពីទីក្រុងភ្នំពេញទៅកាន់ខេត្តបាត់ដំបង ។

ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ការប្រកបរបរកាត់ដេររបស់ឪពុកម្តាយខ្ញុំបានទទួលជោគជ័យយ៉ាងខ្លាំង ដោយសារគាត់ជាជាងកាត់ដេរសម្លៀកបំពាក់ (អាវធំ) សម្រាប់មន្ត្រីរដ្ឋាភិបាលរបស់លោកសេនាប្រមុខ លន់ នល់ ។ ហាងកាត់ដេររបស់គាត់មានឈ្មោះថា «Elite Mode» ដែលមានទីតាំងស្ថិតនៅទល់មុខផ្សារស៊ីឡូប ។ នៅចុងឆ្នាំ១៩៧៤ មន្ត្រីនានានៃរដ្ឋាភិបាលរបស់លោកសេនាប្រមុខ លន់ នល់ បានដឹងពីសភាពការណ៍មិនស្រួលនៅប្រទេសកម្ពុជាស្តីពីចលនារបស់អង្គការបដិវត្តន៍ខ្មែរក្រហមដែលបានដើរបំផុសបំផុលប្រជាជននៅតាមទីជនបទនានាឲ្យក្រោកឈរឡើងប្រឆាំងនឹងរបបរបស់លោកសេនាប្រមុខ លន់ នល់ ។ មន្ត្រីទាំងនោះចាប់ផ្តើមមកកាត់ខោអាវធំក្នុងម្នាក់ៗពីរទៅបីកំផ្លេ ត្រៀមរៀបចំខ្លួនចេញទៅក្រៅប្រទេសដើម្បីគេចចេញពីសង្គ្រាម ហើយពួកគេក៏បានបបួលឪពុករបស់ខ្ញុំទៅជាមួយដែរ ។ ប៉ុន្តែ គាត់មិនយល់ព្រមដោយគិតថា ព្រឹត្តិការណ៍នេះមិនអាចឈានដល់ដំណាក់កាលជម្លៀសប្រជាជនចេញពីក្រុង ហើយសម្លាប់មនុស្សយ៉ាងសាហាវព្រៃផ្សៃដូច្នេះទេ ។

## ការជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពអាវខ្មៅដែលមានជួតក្រមានៅលើក្បាលបានវាយដណ្តើមកាន់កាប់ទីក្រុងភ្នំពេញទាំងស្រុងក្រោមសម្រែកជ័យឃោសនិងអបអរសាទរជ័យជម្នះរបស់កងទ័ពអាវខ្មៅពីសំណាក់ប្រជាជនដែលនៅពាសពេញតាមដងវិថីសាធារណៈ ដោយនឹកស្មានថានឹងបានរស់នៅដោយសុខសន្តិភាព ក្រោមការដឹកនាំរបស់របបថ្មីមិនខាន ។ ស្រាប់តែពីរបីម៉ោងក្រោយមក កងទ័ពអាវខ្មៅបានចាប់ផ្តើមបាញ់រះទៅលើ



ចេង ហុង និង គ្រួសារ នៅឆ្នាំ១៩៨០

អាកាសដើម្បីបញ្ជាឲ្យប្រជាជនទាំងអស់ចាកចេញពីទីក្រុងដោយអះអាងថា អាមេរិកាំងនឹងមក ទម្លាក់គ្រាប់បែកឥឡូវនេះ ដូច្នេះសូមបងប្អូនប្រញាប់ចាកចេញពីទីក្រុងភ្នំពេញជាបន្ទាន់ ។ ដូចជាប្រជាជនដទៃទៀតនៅទីក្រុងភ្នំពេញដែរ ក្រុមគ្រួសារខ្ញុំបានប្រញាប់ប្រញាល់រៀបចំអីវ៉ាន់ ដែលមានដូចជា អង្ករ និងលុយចំនួន១បាវ ចាកចេញពីក្រុងភ្នំពេញនៅវេលាម៉ោង១០និង១០នាទីព្រឹក ឆ្ពោះទៅតាមផ្លូវទួល ក្រសាំងរហូតដល់វត្តសូភីក្បាលកោះ ស្រុកស្អាង ខេត្តកណ្តាល ដែលជាស្រុកកំណើតរបស់ម្តាយខ្ញុំ ។ ប៉ុន្មានម៉ោងក្រោយមក ក្រុមគ្រួសារខ្ញុំត្រូវក្រុមកងទ័ពខ្មែរក្រហមចាប់បង្ខំឲ្យឡើងឡានបិទជិតមួយគ្រឿងដែលពុំអាចមើលឃើញអ្វី



ចេង ហុង ក្នុងឆ្នាំ២០០៩

ទាំងអស់រហូតដល់ខេត្តបាត់ដំបង ដែលស្ថិតនៅក្នុងភូមិភាគពាយ័ព្យ ។ ចំណែកតាដែលជាប្អូនបង្កើតរបស់ជីតាខ្ញុំព្រមទាំងក្រុមគ្រួសាររបស់គាត់ត្រូវអង្គការដឹកជញ្ជូនតាមឡានបិទជិតដូចគ្នារហូតមកដល់ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់ ។ នៅតំបន់នោះ ប្អូនរបស់តាខ្ញុំនិងកូនៗរបស់គាត់ត្រូវកងឈ្លបយកទៅរៀនសូត្របាត់ដំណឹងរហូតដល់សព្វថ្ងៃដោយយកលេសថា លួចដំឡូងរបស់អង្គការ ។

## ជីវិតអ្នករស់នៅតំបន់៣ ភូមិភាគពាយ័ព្យ

នៅចុងឆ្នាំ១៩៧៥ ប្រជាជនខ្លះដែលរស់នៅស្រុកមោងឫស្សី ជាពិសេសអ្នក១៧មេសា ត្រូវអង្គការចាត់ឲ្យទៅរស់នៅតំបន់១ និងខ្លះទៀតទៅរស់នៅតំបន់២ ចំណែកឯក្រុមគ្រួសារខ្ញុំចាត់ឲ្យទៅរស់ នៅតំបន់៣គឺ ភូមិខ្សាយ ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង ដែលជាភូមិកំណើតរបស់គ្រួសារខ្ញុំ ។

គ្រួសារទាំងឡាយណាដែលអង្គការស្នើឲ្យទៅរស់នៅតំបន់១គឺជាមុខសញ្ញាត្រូវកម្ទេចចោលទាំងអស់ ដោយអង្គការតម្រូវឲ្យប្រុសៗទៅកាប់ព្រៃនៅភ្នំធិបតីឬភ្នំផ្តេរ ហើយពុំដែលឃើញត្រឡប់មកវិញទេ ។ ចំណែកអ្នករស់នៅតំបន់២វិញ អង្គការបានដាក់កម្មវិធីសម្លាប់ជាជំហានៗ ដោយដំបូងអង្គការដើរចែកគ្រាប់ពោត៨គ្រាប់ក្នុងមនុស្សម្នាក់ៗ បន្ទាប់មកអង្គការលើកឡើងថា «សមមិត្តទាំងអស់ត្រូវតែចេះជួយសន្សំសំចៃអង្គការ ហើយហូបតិចៗបានហើយ ព្រោះថាសមមិត្តទាំងអស់ហាក់ដូចជាពុំសូវបញ្ចេញកម្លាំងពលកម្មទេ» ។ ជាក់ស្តែង អ្នក១៧មេសាជាងប្រាំមួយរយគ្រួសារត្រូវអង្គការបញ្ជូនមករស់នៅភូមិត្រស់ ឃុំអូរតាគី ស្រុកបាត់ដំបង ខេត្តបាត់ដំបង ដោយអង្គការចែកខ្ទមតូចៗឲ្យរស់នៅពីរគ្រួសារជាមួយគ្នា ។ ចំណែកខ្ទមនីមួយៗខ័ណ្ឌដាច់ពីគ្នា ហើយមានបួនជួរសង់ទល់មុខគ្នា ។ បន្ទាប់មក មេក្រុមនិងមេកងបានបញ្ជាឲ្យប្រជាជនទៅជំរំធ្វើការដែលនេះគឺជាមូលហេតុធ្វើឲ្យឪពុកម្តាយព្រាត់កូន ជីដូនព្រាត់ចៅ ប្រពន្ធព្រាត់ប្តីជាដើម ។ ចំណែកកុមារតូចៗវិញបានក្លាយទៅជាកូនរបស់អង្គការដោយផ្តាច់មនោសញ្ចេតនាពីឪពុកម្តាយ ដោយអង្គការតម្រូវឲ្យកុមារទាំងនោះចូលរៀនសាលាក្រោមដើមឈើ ឬក្រោមផ្ទះប្រជាជន ហើយខ្លះទៀតរៀនច្រៀងបទ «យើងខ្ញុំកុមារស្រឡាញ់អង្គការឥតមានព្រំដែន» ។

ដោយឡែកនៅតំបន់៣វិញក៏មានលក្ខណៈស្រដៀងគ្នាទៅនឹងតំបន់២ដែរ គឺអង្គការបានរៀបចំផែនការបោសសម្អាតអ្នក១៧មេសាជាជំហានៗដូចគ្នា ដោយគ្រាន់តែអង្គការប្រើប្រាស់រូបភាពផ្សេងៗគ្នា ដូចជាឲ្យកងឈ្លបតាមដានប្រវត្តិរូបរបស់ប្រជាជន ធ្វើទារុណកម្ម និងបង្អត់អាហារ ឲ្យហូបមិនគ្រប់គ្រាន់ជាដើម ។ នៅទីនោះ ឪពុកខ្ញុំបានស្ម័គ្រចិត្តធ្វើជាអ្នកឡើងត្នោតទោះបីជាគាត់មិនចេះឡើង ឬធ្វើស្ករត្នោតក៏ដោយ ។ ប៉ុន្តែជាអកុសលជីតាបង្កើតខ្ញុំនិងសាច់ញាតិដទៃទៀតបានជួបប្រទះនឹងគ្រោះអត់ថ្នាំសង្កូវ និងអាហារនៅឆ្នាំ១៩៧៦ រហូតដល់ស្លាប់ ។ ទោះបីជាឪពុកខ្ញុំជួយលាក់លៀមយកទឹកត្នោតនិងស្ករត្នោតទៅឲ្យដើម្បីព្យាបាលជំងឺគាត់ក៏ដោយ ក៏មិនអាចជួយឲ្យជីតាខ្ញុំរស់រានមានជីវិតបានដែរ ។ ចំណែកការហូបចុកវិញ គឺហូបមិនបានគ្រប់គ្រាន់ទេ ដូច្នេះប្រជាជននៅតំបន់៣នេះបានដាច់ចិត្តហ៊ានលួចដំឡូង សម្លាប់សត្វ កង្កែប ឆ្មា ពស់ និងកណ្តុរមកធ្វើជាចំណីអាហារ ។ ហើយខ្លះទៀតត្រូវកងឈ្លបចាប់យកទៅធ្វើទារុណកម្មរហូតដល់ស្លាប់ ។ លើសពីនេះទៅទៀត នៅពេលឈឺគ្មាននរណាម្នាក់ហ៊ានសុំច្បាប់ឡើយ ព្រោះខ្លាចអង្គការនិយាយថាមានជំងឺសតិអារម្មណ៍ ដូចពាក្យអង្គការតែងតែនិយាយថាៈ «មិត្តគ្រុនញាក់ គ្រុនញ័រ គ្រុនគ្រាក់ទ័រ គ្រុនឡាន គ្រុនបាយបាន គ្រុនត្បូងចប» ។ នេះគឺជាពាក្យស្លោកមួយដើម្បីបំបាក់ស្មារតីរបស់អ្នកជំងឺឲ្យធ្វើការរហូតដល់ស្លាប់ ឬដើរលែងរួចជាដើម ។

**ព្រឹត្តិការណ៍ដ៏គួរឲ្យរន្ធត់នៅតំបន់៣ ភូមិភាគពាយ័ព្យ**

អំឡុងឆ្នាំ១៩៧៧ មានព្រឹត្តិការណ៍ដ៏គួឲ្យរន្ធត់ជាញឹកញាប់កើតឡើងនៅចំពោះមុខបងប្រុសនិងជីដូនរបស់ខ្ញុំ ។ នៅថ្ងៃមួយ ពេលកំពុងឈរចាំនៅមាត់ផ្លូវមើលជីដូនចេញមកពីធ្វើការវិញ ក្រែងមានអ្វីយកមកផ្ញើចៅៗខ្លះ ខ្ញុំបានឃើញយាយឆ្មបម្នាក់បីកូនដែលទើបនឹងកើតហើយស្លាប់យកទៅបណ្តែតទឹកចោលព្រោះអង្គការហាមមិនឲ្យកប់ ។ ក្រោយមកទៀត ខ្ញុំក៏បានឃើញអង្គការចាប់អ្នកលួចដំឡូងទាំងអស់យកទៅសម្លាប់ចោលដោយវាយនឹងត្បូងចប រួចអារកថែមទៀតដើម្បីបញ្ជាក់ថាអ្នកទោសទាំងនោះពិតជាបានស្លាប់មែន ។

នៅដើមឆ្នាំ១៩៧៨ អ្នកមីងខ្ញុំម្នាក់មានជំងឺជាទម្ងន់ដោយមានអាការៈស្ហេកស្គាំង ហើយខ្លួនប្រាណហើមទៀត ។ ដូច្នេះ គាត់ក៏បានមកជួបឪពុកខ្ញុំនៅកន្លែងធ្វើការដើម្បីសុំទឹកត្នោតយកមកព្យាបាលជំងឺ ប៉ុន្តែពេលត្រឡប់មកវិញ ត្រូវអង្គការដឹងហើយក៏យកគាត់ទៅព្រមាន ប៉ុន្តែត្រូវបានរួចខ្លួនមកវិញ ដោយសារឪពុកខ្ញុំទៅជួយអង្វរ ។

នៅចុងឆ្នាំ១៩៧៨ សភាពការណ៍ក្នុងប្រទេសចាប់ផ្តើមច្របូកច្របល់ ដោយសារមេដឹកនាំនៅក្នុងជួរបក្សចាប់ផ្តើមមិនទុកចិត្តគ្នាទៅវិញទៅមក ជាពិសេសរវាងកម្មាភិបាលខ្មែរក្រហមដែលទើបផ្លាស់មកពីភូមិភាគនិរតី និងអ្នកមូលដ្ឋានចាស់ រហូតដល់មានការទម្លាក់កំហុសដាក់គ្នាទៅវិញទៅមកថាក្បត់នឹងអង្គការ ឬចោទថាជាមេខ្លោងសេ.អ៊ី.អា បង្កប់ស៊ីរូងផ្ទៃក្នុង ។ ព្រឹត្តិការណ៍នេះបានធ្វើឲ្យមានការចាប់ចងប្រជាជនយកទៅសម្លាប់ជារៀងរាល់ថ្ងៃនិងធ្វើឲ្យអ្នក១៧មេសាមានអារម្មណ៍កាន់តែបាក់ស្បាតខ្លាំងឡើងៗ ។

នៅឆ្នាំ១៩៧៩ យោធាខ្មែរក្រហមបានបាក់ទ័ពរត់ខ្ចាត់ខ្ចាយ ហើយនាំគ្នារត់គេចខ្លួន ដោយសារមានអន្តរាគមន៍របស់កងទ័ពវៀតណាមដែលចូលមករំដោះប្រទេសកម្ពុជាឲ្យរួចផុតពីក្រញាំដៃរបស់ពួកបនប្រល័យពូជសាសន៍ខ្មែរក្រហម ។ ទន្ទឹមនឹងនេះ ក្រុមគ្រួសារខ្ញុំចំនួន៨នាក់បានធ្វើដំណើរចាកចេញពីខេត្តបាត់ដំបងមកកាន់ទីក្រុងភ្នំពេញដែរដោយធ្វើដំណើរដោយថ្មើរជើងអស់រយៈពេល១៨ថ្ងៃ ទើបគ្រួសារខ្ញុំបានមកដល់គោលដៅ ។

ក្នុងនាមខ្ញុំជាអ្នកអប់រំផ្នែកប្រវត្តិសាស្ត្រមួយរូប ខ្ញុំសំណូមពរឲ្យការអប់រំផ្នែកប្រវត្តិសាស្ត្រមានភាពច្បាស់លាស់និងកុំលាក់លៀមនូវរឿងអតីតកាលរបស់ខ្លួន ហើយរួមគ្នានិយាយរឿងខ្មែរក្រហមឲ្យបានស៊ីជម្រៅនិងច្បាស់លាស់ ដើម្បីឲ្យរបួសផ្លូវចិត្តដែលកប់ទុកជាយូរមកហើយបានជាសះស្បើយ និងដើម្បីកសាងប្រវត្តិសាស្ត្រដ៏ជូរចត់មួយឡើងវិញនិងមានតម្លៃជាសកល ។ លើសពីនេះទៅទៀត សូមឲ្យស្ថាប័នតុលាការដែលកំពុងតែដំណើរការកាត់ក្តីមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម មេត្តាជួយផ្តល់យុត្តិធម៌ឲ្យជនរងគ្រោះទាំងឡាយបានអស់ចិត្តផង ។

**ចេង ហុង**

# សេចក្តីប្រកាសស្វែងរកគ្រួសារ

ខ្ញុំបាទឈ្មោះ ឈុន អៀង ហៅ ទូច រស់នៅភូមិព្រែកហូរខាងកើត ឃុំព្រែកហូរ ស្រុកតាខ្មៅ ខេត្តកណ្តាល ។ ខ្ញុំសូមប្រកាសស្វែងរកបងស្រីឈ្មោះ ចេង ឈុន ហៅ ស្រេង និងប្តីឈ្មោះ ងួន អេង ហៅ តានី (វិស្វករអគ្គិសនី) និងកូនប្រុសស្រីចំនួន៥នាក់ឈ្មោះ ៖ ១) ងួន សៅយុទ្ធ អាយុប្រហែល៤២ឆ្នាំ (ប្រុស) ២) ងួន វុត្ថា អាយុប្រហែល៤០ឆ្នាំ (ប្រុស) ៣) ងួន វុត្ថាវនី អាយុប្រហែល៣៨ឆ្នាំ (ស្រី) ៤) ងួន រតនបុប្ផា អាយុប្រហែល៣៦ឆ្នាំ (ស្រី) និងកូនប្រុសម្នាក់ទៀតដែលខ្ញុំពុំបានចាំឈ្មោះ ។ ប្រសិនបើបងប្អូនណាបានឃើញ ឬស្គាល់ឈ្មោះខាងលើនេះ សូមមេត្តាទាក់ទងមកខ្ញុំបាទតាមរយៈទូរស័ព្ទលេខ ០៩២ ៣៥ ៩៣ ៣០ ឬអាសយដ្ឋានខាងលើ ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រអប់សំបុត្រលេខ១១០ ភ្នំពេញ ឬទូរស័ព្ទលេខ (៨៥៥) ០២៣ ២១១ ៨៧៥ សូមអរគុណ ។

# សេចក្តីប្រកាសរកឈ្មោះបងប្រុស និងគ្រួសារ

នាងខ្ញុំឈ្មោះ កែវ ដានី (ពុយ ដានី) និងប្តីឈ្មោះ កែវ ប៊ុនលី រស់នៅ ៧៦ *Rue Rene Laennec 67200 Strasbourg- France* មានឪពុកឈ្មោះ ពុយ ងួនជី ម្តាយឈ្មោះ ឡឹង ញាន ។ នាងខ្ញុំសូម ប្រកាសស្វែងរកបងប្រុស និងគ្រួសារឈ្មោះ ១) ពុយ តៃនី (ប្តី) ២) តៅ យីង (ប្រពន្ធ) ៣) ពុយ វិពៃ (កូន) ៤) ពុយ វពីង (កូន) ៥) ពុយ វិពត់ ឬ វិព័រ (កូន) ។

ប្រសិនបើបងប្អូនណាបានឃើញសេចក្តីប្រកាសនេះ សូមទាក់ទងមកខ្ញុំតាមរយៈអាសយដ្ឋានខាងលើ ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រអប់សំបុត្រលេខ១១០ ភ្នំពេញ ឬទូរស័ព្ទលេខ (៨៥៥) ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# សេចក្តីស្វែងរកបងប្រុស

ខ្ញុំឈ្មោះ កែវ ប៊ុនលី រស់នៅ ៧៦ *Rue Rene Laennec 67200 Strasbourg-France* សូមប្រកាសរកបងប្រុសឈ្មោះ កែវ ប៊ុនថុន ជាទាហានជំនាន់ លន់ នល់ បានទៅរៀននៅសហរដ្ឋអាមេរិកនៅឆ្នាំ១៩៧៣ រហូតឆ្នាំ១៩៧៦ ក៏បានទៅសិក្សានៅប្រទេសបារាំងទៀត រួចត្រឡប់ចូលមករស់នៅស្រុកខ្មែរវិញ ដោយជិះយន្តហោះចិន ។ រហូតមកដល់សព្វថ្ងៃនេះ គាត់បាត់ដំណឹងរហូត ។

ប្រសិនបើបងប្អូនណាបានឃើញសេចក្តីប្រកាសនេះ សូមទាក់ទងមកខ្ញុំតាមរយៈអាសយដ្ឋានខាងលើ ឬ អ៊ីមែល ៖ *keodaniel@free.fr.* សូមអរគុណ ។

# សេចក្តីប្រកាសរកប្អូនប្រុស

នាងខ្ញុំឈ្មោះ នាក់ ហោង សព្វថ្ងៃរស់នៅភូមិភ្នំតូច ឃុំស្តេចគង់ខាងត្បូង ស្រុកបន្ទាយមាស ខេត្តកំពត ឪពុកខ្ញុំឈ្មោះ សោម យេន (ស្លាប់) និងម្តាយឈ្មោះ អ៊ុន សឹម (ស្លាប់) ។ ខ្ញុំមានបងប្អូនពីរនាក់ គឺខ្ញុំនិងប្អូនប្រុសម្នាក់ទៀតឈ្មោះ នាក់ ធី (បាត់ខ្លួន) ។ ខ្ញុំសូមស្វែងរកប្អូនប្រុសឈ្មោះ នាក់ ធី ដែលបាត់ខ្លួនពេលធ្វើជានិរសារនៅព្រំដែនវៀតណាមនៅមុនឆ្នាំ១៩៧៥ ។ នៅពេលនោះ ធី ទើបតែមានអាយុប្រហែលជា១៤ឬ១៥ឆ្នាំប៉ុណ្ណោះ បានចេញពីផ្ទះទៅធ្វើជានិរសារជាមួយមីងឈ្មោះ ពៅ ជាអ្នកនាំចូល ។ ក្រោយមកខ្ញុំក៏បាត់ដំណឹង ធី រហូត ។ ប្រសិនបើប្អូនបានឃើញសេចក្តីប្រកាសនេះ ឬបងប្អូនណាស្គាល់ ឬឮដំណឹងអំពីឈ្មោះខាងលើនេះ សូមមេត្តាផ្តល់ព័ត៌មានមកនាងខ្ញុំតាមរយៈទូរស័ព្ទលេខ ០១៧ ៩២៩ ៩៦១ ឬមេភូមិភ្នំតូចឈ្មោះ មិន ឈុំ ឬទំនាក់ទំនងមកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ **សូមអរគុណ**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម

មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល : truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ៈ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។










ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវេ ស៊ុយអែត និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 122, February 2010 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.